ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីណែនាំ
# ស្តីពីការផ្តល់សេវាគាំពារមាតានិងទារក
# ក្នុងអំឡុងពេលការរាតត្បាតជាសកលនៃ
# ជំងឺកូវីដ-១៩

ឆ្នាំ ២០២០

# អារម្ភកថា

គោលបំណងសំខាន់នៃសេចក្តីណែនាំស្តីពីការផ្តល់សេវាគាំពារមាតា និងទារកក្នុងអំឡុងពេលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩នេះ គឺដើម្បីធានាថាអ្នកផ្តល់សេវាថែទាំផ្នែកសម្ភពអាចផ្តល់សេវាថែទាំសុខភាពស្ត្រីក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល ក្រោយសម្រាល ការថែទាំទារកទើបនឹងកើត កុមារ យុវវ័យ សេវាពន្យារកំណើត សេវាថែទាំការរំលូតកូនប្រកបដោយសុវត្ថិភាព អំពើហិង្សាលើស្ត្រី និងសេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ប្រកបដោយការគោរព និងការយកចិត្តទុកដាក់ ដើម្បីលើកកម្ពស់សុវត្ថិភាពរបស់ស្ត្រីក្រុមគ្រួសារនិងបុគ្គលិកសុខាភិបាលក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩។

សេចក្តីណែនាំនេះគ្រាន់តែជាឯកសារបន្ថែមទៅលើឯកសាររបស់ក្រសួងសុខាភិបាលដែលមានស្រាប់ហើយការចងក្រងសេចក្តីណែនាំនេះផ្អែកលើគោលការណ៍ណែនាំរបស់អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងអង្គការសុខភាពពិភពលោក (WHO) រួមមានការអនុវត្តនិងដំបូន្មានថ្មីៗទាក់ទងនឹងការថែទាំសុខភាពដែលត្រូវអនុវត្តនៅក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩។

សេចក្តីណែនាំនេះអាចជួយដល់ អ្នកគ្រប់គ្រង និងអ្នកផ្តល់សេវា ក្នុងការផ្តល់សេវាថែទាំសុខភាពដោយផ្ទាល់ និងពីចម្ងាយ តាមទូរស័ព្ទ ឬប្រព័ន្ធអ៊ិនធឺណេតប្រសិនបើអាចធ្វើបាន ប៉ុន្តែវាគ្រាន់តែជាជំនួយបន្ថែមទៅលើការអនុវត្តតាមពិធីសារជាតិមាតុភាពគ្មានគ្រោះថ្នាក់របស់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩តែប៉ុណ្ណោះ។

ថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

សាស្ត្រាចារ្យ **អេង ហួត**

រដ្ឋលេខាធិការ

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាលសូមសម្តែងនូវការកោតសរសើរ ចំពោះមន្ត្រីកម្មវិធីជាតិសុខភាពបន្តពូជនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកដែលបានខិតខំប្រឹងប្រែងរៀបរៀងជាសង្ខេបផ្នែកបច្ចេកទេសថ្នាក់ជាតិ នូវសេចក្តីណែនាំស្តីពីការផ្តល់សេវាគាំពារមាតានិងទារក ក្នុងអំឡុងពេលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩នេះឡើង។

សូមថ្លែងអំណរគុណដល់ក្រុមការងារបច្ចេកទេសរបស់កម្មវិធីជាតិសុខភាពបន្តពូជ ផ្នែកបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលជាតិគាំពាមាតានិងទារក នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលដែលបានសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីបច្ចេកទេសរបស់ដៃគូអភិវឌ្ឍសុខាភិបាលរួមមានអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) អង្គការសុខភាពពិភពលោក (WHO) អង្គការ GIZ គម្រោងUSAID-EQHA អង្គការCHAI ព្រមទាំងផ្តល់ជំនួយបច្ចេកទេស លើការអនុវត្តនិងដំបូន្មានរបស់អ្នកជំនាញ ផ្អែកលើការស្រាវជ្រាវបែបវិទ្យាសាស្រ្តចុងក្រោយ ដែលទាក់ទងនឹងជំងឺកូវីដ-១៩ ដើម្បីការពារសុខភាពមាតានិងទារកនៅក្នុងប្រទេសកម្ពុជា។

សូមថ្លែងអំណរគុណជាពិសេសដល់អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានជួយប្រែសម្រួលជាភាសាខ្មែរព្រមទាំងជួយឧបត្ថម្ភថវិកាគាំទ្រក្នុងការរៀបរៀងនិងការបោះពុម្ពសេចក្តីណែនាំនេះ។

# មាតិកា


អារម្ភកថា.....1

សេចក្តីថ្លែងអំណរគុណ.....2

មាតិកា.....3

សេចក្តីផ្តើម.....4

ការពិគ្រោះជំងឺ ការស្រាវជ្រាវ ការបញ្ជូននិងការការពារខ្លួន.....7

ការថែទាំផ្ទៃពោះមុនសម្រាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩.....12

ការថែទាំពេលឈឺពោះសម្រាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩.....22

ការថែទាំក្រោយសម្រាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩.....29

ការថែទាំកុមារនិងសេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជ ក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩......39

សុខភាពនិងសុវត្ថិភាពរបស់បុគ្គលិកសុខាភិបាល.....51

ឧបសម្ព័ន្ធ.....53

# សេចក្តីផ្តើម

ជំងឺកូវីដ-១៩ជាជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវថ្មីដែលបណ្តាលមកពីមេរោគថ្មីដែលមានឈ្មោះថា SAR-CoV-2 ដែលកើតឡើងនៅទីក្រុងវូហានប្រទេសចិនកាលពីខែធ្នូ ឆ្នាំ២០១៩ ហើយបានរីករាលដាលទូទាំងពិភពលោក។

ចំណុចសំខាន់បំផុតអំពីជំងឺកូវីដ-១៩នេះ ការឆ្លងភាគច្រើនអាចបណ្តាលឱ្យមានរោគសញ្ញាស្រាល ឬគ្មានរោគសញ្ញា ហើយមិនមែនមនុស្សគ្រប់រូបសុទ្ធតែមានហានិភ័យនៃជំងឺនេះទេ។ មនុស្សដែលមានអាយុកាន់តែច្រើន អ្នកដែលមានជំងឺផ្លូវដង្ហើម បេះដូង បញ្ហាមេតាបូលិកនិងភាពសុំខ្សោយ អាចមានហានិភ័យខ្ពស់ពីមធ្យមទៅធ្ងន់ធ្ងរ។

ទិន្នន័យស្តីពីជំងឺកូវីដ-១៩លើស្ត្រីមានផ្ទៃពោះនៅមានកម្រិត តាមរយៈការសិក្សាដែលបានចុះផ្សាយរហូតមកដល់ពេលនេះមិនបង្ហាញពីការកើនឡើងនូវហានិភ័យនៃជំងឺធ្ងន់ធ្ងរក្នុងពេលមានផ្ទៃពោះ ឬមានហានិភ័យខ្ពស់ចំពោះទារកទើបនឹងកើតនោះទេ។ ការឆ្លងមេរោគពីកំណើតមិនត្រូវបានគេរកឃើញទេ ហើយមេរោគមិនត្រូវបានគេរកឃើញនៅក្នុងពេលចាប់ផ្តើមមានផ្ទៃពោះដែរ។ របកគំហើញទាំងនេះមានភាពប្រាកដប្រជានិងខុសគ្នាស្រឡះពីជំងឺរាតត្បាតផ្សេងៗទៀតដូចជាជំងឺផ្តាសាយបក្សី H1N1 ឆ្នាំ២០០៩ ដែលបណ្តាលឱ្យមានជំងឺធ្ងន់ធ្ងរលើស្ត្រីមានផ្ទៃពោះឬវីរុសហ្សិកាដែលធ្វើឱ្យទារកទើបនឹងកើតមានទម្រង់ខុសពីធម្មតា។ក្នុងពេលដែលកំពុងរៀបរៀងឯកសារនេះព័ត៌មានស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩លើស្ត្រីដែលមានផ្ទៃពោះនៅវ័យក្មេងនិងព័ត៌មានបង្ហាញស្តីពីហានិភ័យទាបនៃភាពធ្ងន់ធ្ងររបស់ជំងឺកូវីដ-១៩នេះលើស្ត្រីក្នុងវ័យបន្តពូជមិនទាន់មាននៅឡើយ។

**ការរក្សាសំណុំសេវាសុខាភិបាលសំខាន់ៗ**

ជំងឺជំងឺកូវីដ-១៩ ទំនងជាប៉ះពាល់ខ្លាំងជាងលើ ប្រទេសដែលមានប្រព័ន្ធសុខាភិបាលមិនទាន់រឹងមាំទំនង។ ការថយចុះនូវលទ្ធភាពទទួលបាននិងការប្រើប្រាស់សេវាសុខភាព មាតានិងទារកក្នុងអំឡុងពេលរាតត្បាតនេះ នឹងបណ្តាលអោយមានការកើនឡើងនូវចំនួនមាតានិងទារកដែលប្រឈមនឹងផលវិបាក ឬស្លាប់ក្នុងអំឡុងពេលមានផ្ទៃពោះ សម្រាលនិងក្រោយសម្រាល។ ដូច្នេះអ្នកគ្រប់គ្រងសេវាសុខាភិបាលត្រូវពិចារណាអោយបានល្អិតល្អន់នូវលទ្ធភាពក្នុងការផ្តល់សេវាទាំងនេះនៅមូលដ្ឋាននិងនៅសហគមន៍ ដើម្បីធានានូវការបន្តទទួលបាននូវសេវាសុខភាពមាតានិងទារកសំខាន់ៗ។

ស្ត្រីមានផ្ទៃពោះទាំងអស់រួមទាំងអ្នកដែលមានការឆ្លងមេរោគដែលត្រូវបានបញ្ជាក់ឬសង្ស័យថាមានជំងឺកូវីដ-១៩ មានសិទ្ធិទទួលបានការថែទាំប្រកបដោយគុណភាពខ្ពស់ មុនពេលសម្រាល ពេលសម្រាលនិងក្រោយពេលសម្រាល ដោយរួមបញ្ចូលទាំងការថែទាំទារកទើបនឹងកើតនិងថែទាំសុខភាពផ្លូវចិត្ត។

សេវាថែទាំផ្នែកសម្ភពគួរតែបន្តផ្តល់អាទិភាពជាសេវាសុខភាពស្នូលដ៏សំខាន់ ហើយសេវាថែទាំសុខភាពផ្លូវភេទនិងបន្តពូជដទៃទៀតដូចជា ផែនការគ្រួសារ ការការពារកំណើតបន្ទាន់ ការព្យាបាលជំងឺកាមរោគ ការថែទាំក្រោយការរំលូតកូននិងសេវារំលូតកូនប្រកបដោយសុវត្ថិភាពនិងស្របច្បាប់នៅតែជាសេវាសុខភាពស្នូលផងដែរ។

អ្នកផ្តល់សេវាថែទាំផ្នែកសម្ភព រួមទាំងឆ្មបនិងបុគ្គលិកដែលផ្តល់ការគាំពារមាតានិងទារកមិនថានៅតាមមូលដ្ឋានសុខាភិបាលឬនៅក្នុងសហគមន៍គឺជាអ្នកផ្តល់សេវាថែទាំដ៏សំខាន់ដែលត្រូវការពារនិងផ្តល់អាទិភាពដល់ពួកគាត់ដើម្បីបន្តផ្តល់ការថែទាំដល់ស្ត្រីមានផ្ទៃពោះនិងទារក។

សេចក្តីណែនាំនេះសម្រាប់ធ្វើផែនការដើម្បីគាំទ្រនិងរៀបចំផែនការត្រៀមទុកជាមុនដើម្បីឆ្លើយតបបន្ថែមលើគោលការណ៍ណែនាំស្តីអំពីសេវាសំខាន់ៗ អំឡុងពេលមានការរាលដាលនិងដើម្បីបំពេញបន្ថែមលើឯកសារដែលទើបតែចុះផ្សាយស្តីអំពីការការពារសុខភាពនៅសហគមន៍ រួមទាំងការធ្វើយុទ្ធនាការនានាក្នុងអំឡុងពេលដែលកំពុងមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដោយយោងទៅតាមសេចក្តីណែនាំរបស់អង្គការសុខភាពពិភពលោក សម្រាប់រក្សានូវសេវាសុខភាពសំខាន់ៗ បានចុះផ្សាយ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ បានពង្រីកបន្ថែមអំពីមាតិកានៃការផ្តល់សេវាសំខាន់ៗនិងផែនការយុទ្ធសាស្ត្រត្រៀមទុកជាមុននិងការឆ្លើយតបស្តីអំពីជំងឺកូវីដ-១៩។ សេចក្តីណែនាំនេះនឹងគាំទ្រដល់ការអនុវត្តសកម្មភាពជាគោលដៅសំខាន់ៗនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសហគមន៍ដើម្បីរៀបចំឡើងវិញនិងរក្សាការទទួលបានសេវាមានសុវត្ថិភាពនិងមានគុណភាពដែលមាននៅក្នុងសំណុំសេវាសំខាន់ៗ។ សេចក្តីណែនាំនេះនឹងបង្ហាញអំពី ការផ្លាស់ប្តូរចាំបាច់ដើម្បីរក្សាសុខភាពរបស់ប្រជាជនមានសុវត្ថិភាពនិងរក្សាការបន្តការផ្តល់សំណុំសេវាសំខាន់ៗ អំឡុងពេលនៃការឆ្លើយតបលើការរាលដាលជំងឺកូវីដ-១៩។ សេចក្តីណែនាំនេះសំដៅលើអ្នកធ្វើការសម្រេចចិត្តនិងអ្នកគ្រប់គ្រងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ខាងក្រោមនេះជាអនុសាសន៍នានាសម្រាប់ជួយគាំទ្រដល់អ្នកគ្រប់គ្រងសេវាសុខាភិបាលដើម្បីធានានូវការបន្តសំណុំសេវាសុខាភិបាលសំខាន់ៗ ។

**យុទ្ធសាស្ត្រនានាសម្រាប់សំណុំសេវាសុខាភិបាលសំខាន់ៗ**

- ធ្វើការកែប្រែយន្តការនៃការគ្រប់គ្រងនិងសម្របសម្រួលដើម្បីគាំទ្រសកម្មភាពឱ្យបានទាន់ពេល
- កំណត់អាទិភាពសេវាសុខភាពសំខាន់ៗ និងធ្វើការអនុវត្តដើម្បីធ្វើការផ្លាស់ប្តូរទៅតាមតម្រូវការ
- ធ្វើការរៀបចំទីកន្លែងសម្រាប់ការផ្តល់សេវា
- បង្កើតលំហូរសម្រាប់អ្នកជំងឺឱ្យមានសុវត្ថិភាពនិងប្រសិទ្ធភាពនៅគ្រប់កម្រិត
- ធ្វើការពង្រឹងសមត្ថភាពដល់អ្នកផ្តល់សេវាឱ្យបានរហ័ស
- រក្សាឱ្យមានឱសថចាំបាច់ ឧបករណ៍និងបរិក្ខារនានា
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់សុខភាពសាធារណៈនិងបំបាត់របាំងហិរញ្ញវត្ថុនៃការទទួលសេវា
- ពង្រឹងយុទ្ធសាស្ត្រទំនាក់ទំនងដើម្បីគាំទ្រដល់ការប្រើសេវាសំខាន់ៗឱ្យបានសមស្រប

- ពង្រឹងការអភិបាលសេវាសំខាន់ៗ
  - ប្រើបច្ចេកវិទ្យា DIGITAL ដើម្បីធ្វើការគាំទ្រការផ្តល់សេវាសំខាន់ៗ។

# ការពិគ្រោះជំងឺ ការស្រាវជ្រាវ ការបញ្ជូននិង ការការពារខ្លួន

## I. ការពិគ្រោះជំងឺនិងការស្រាវជ្រាវរកជំងឺកូវីដ-១៩

១. ការពិគ្រោះជំងឺនិងការស្រាវជ្រាវរក(Screen)ជំងឺកូវីដ-១៩ ត្រូវអនុវត្តលើស្ត្រីទាំងអស់ដែលមកទទួលសេវាសុខភាពបន្តពូជតាមឯកសារជំនួយស្មារតី ការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺកូវីដ-១៩(Version 2) (MOH Dianosis and Treatment Protocol for COVID-19 in Cambodia)។

២. ត្រូវសាកសួរស្ត្រីទាំងអស់និងសាច់ញាតិឬអ្នកជូនដំណើររបស់ស្ត្រី ដើម្បីតាមដានរកការឆ្លងមេរោគតាមរយៈការសាកសួរអំពីសុខភាពទូទៅ ជំងឺប្រចាំកាយ (ឧទាហរណ៍ ជំងឺបេះដូង ប្រវត្តិជំងឺរបេង ជំងឺទឹកនោមផ្អែម ជំងឺផ្លូវដង្ហើម ឬមេតាបូលិក) សញ្ញាគ្រុនក្តៅនិងរោគសញ្ញាផ្លូវដង្ហើម។ អ្នកដែលមានគ្រុនក្តៅឬរោគសញ្ញានៃផ្លូវដង្ហើមអាចនឹងប្រឈមជំងឺកូវីដ-១៩។ ស្ត្រីមានផ្ទៃពោះដែលកំពុងរស់នៅក្នុងតំបន់ ជនជាតិភាគតិច សហគមន៍ដែលមានមនុស្សច្រើនកុះករ មអាចនឹងមានហានិភ័យខ្ពស់នៃការឆ្លងជំងឺកូវីដ-១៩ ។

៣. ត្រូវមានប្រព័ន្ធបញ្ជូនជាស្រេចដើម្បីធ្វើការបញ្ជូនបន្ទាន់ពីមូលដ្ឋានសុខាភិបាលកម្រិតទាបទៅកាន់កន្លែងមូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ សម្រាប់ស្ត្រីមានផ្ទៃពោះដែលវិវឌ្ឍទៅសភាពមធ្យមនិងធ្ងន់ធ្ងរហើយទាមទារសេវាព្យាបាលកម្រិតខ្ពស់។ ប្រសិនបើអាចបុគ្គលិកផ្នែកសម្ភពនៅមូល ដ្ឋានសុខាភិបាលកម្រិតទាបគួរតែជូនដំណឹងដល់មូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ជាមុនអំពីការបញ្ជូនដោយធានាថាស្ត្រីមានស្ថេរភាពសិន។ ក្នុងករណីស្ត្រីមិនទាន់ឈឺពោះសម្រាលត្រូវរៀបចំបញ្ជូន។

ក្នុងករណីស្ត្រីឈឺពោះសម្រាល សូមមើលទំព័រទី២៦។

**ក.<u>នៅពេលរៀបចំបញ្ជូនបន្ទាន់</u>**

- រៀបចំរថយន្តគិលានសង្គ្រោះសម្រាប់បញ្ជូននិងឱសថបំរុងទុកក្នុងករណីសង្គ្រោះបន្ទាន់ដែលអាចកើតឡើងក្នុងអំឡុងពេលបញ្ជូន
  ដូចជាការតៀ្រតសរសៃឈាមបេះដូងឬសម្ពាធឈាមថយចុះភ្លាមៗ។
- បុគ្គលិករថយន្តគិលានសង្គ្រោះទាំងអស់គួរតែពាក់ម៉ាស់វះកាត់ ។ បុគ្គលិកដែលត្រូវបញ្ជូនអ្នកជំងឺទាំងអស់ត្រូវមាន ឧបករណ៍ការពារខ្លួន(PPE) មុនពេលដឹកជញ្ជូន។
- អ្នកជំងឺឬស្ត្រីត្រូវពាក់ម៉ាស់វះកាត់ (surgical mask) ក្នុងអំឡុងពេលបញ្ជូន ទោះបីជាអ្នកជំងឺឬស្ត្រីមិនបានពាក់នៅពេលចូលសម្រាកក្នុងមន្ទីរពេទ្យក៏ដោយ ។

- ក្នុងអំឡុងពេលបញ្ជូន ប្រសិនបើត្រូវការសប់បញ្ចូលខ្យល់ដោយបាឡុងនិងម៉ាស់ ត្រូវសប់បញ្ចូលដោយថ្នមៗ ដើម្បីកាត់បន្ថយវីរុសចេញតាមផ្លូវដង្ហើមកាន់តែខ្លាំង ក្នុងករណីអ្នកជំងឺខ្វះអុកស៊ីសែនកាន់តែខ្លាំង ហើយពិបាកដកដង្ហើម។ បុគ្គលិកត្រូវពាក់ម៉ាស់ N95 និងស្រោមដៃ។
- ក្នុងអំឡុងពេលបញ្ជូន ប្រសិនបើមិនចាំបាច់ ត្រូវចៀសវាងការដកអុកស៊ីសែនដែលជួយដល់ការដកដង្ហើម ។

ខ. <u>រថយន្តគិលានសង្គ្រោះសម្រាប់បញ្ជូន</u> ៖

- ត្រូវសម្អាតផ្ទៃខាងក្នុងរបស់រថយន្តសង្គ្រោះសម្រាប់បញ្ជូនដោយប្រើសម្ភារសម្រាប់ការពារខ្លួន (PPE) មុនពេលបញ្ជូនពីមូលដ្ឋានសុខាភិបាលកម្រិតទាបទៅកាន់មូលដ្ឋានសុខាភិបាលកម្រិតខ្ពស់។
- ពេលមកដល់មូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ បុគ្គលិកសង្គ្រោះបន្ទាន់ត្រូវដោះសម្ភារសម្រាប់ការពារខ្លួន (PPE) និងបោះចោលដោយអនុលោមទៅតាមគោលការណ៍ណែនាំនិងលាងដៃ។
- បុគ្គលិករថយន្តសង្គ្រោះបន្ទាន់ត្រូវពាក់សម្ភារសម្រាប់ការពារខ្លួន(PPE)ថ្មី មុនពេលធ្វើដំណើរត្រឡប់មកវិញតាមរថយន្តសង្គ្រោះបន្ទាន់តែមួយ ហើយត្រូវដោះចេញនៅពេលបញ្ចប់ភារកិច្ច
- ត្រូវសម្អាតសម្ភារនិងបរិក្ខារដែលបានប្រើក្នុងអំឡុងពេលបញ្ជូនតាមគោលការណ៍ណែនាំនៃការសម្អាត។ ត្រូវសម្អាតរថយន្តសង្គ្រោះបន្ទាន់ភ្លាមបន្ទាប់ពីត្រឡប់មកដល់មន្ទីរពេទ្យរបស់ខ្លួនវិញ។ ព័ត៌មានលម្អិត <u>សូមមើលឧបសម្ពន្ធ១ - ការសម្អាតរថយន្តសង្គ្រោះបន្ទាន់និងយានយន្តបញ្ជូនអ្នកជំងឺ។</u>

៤. ស្ត្រីដែលមានការសង្ស័យថាឆ្លងជំងឺកូវីដ-១៩ ចាំបាច់ត្រូវផ្តល់ម៉ាស់ការពារ និងព្យាបាលនៅកន្លែងព្យាបាលដាច់ដោយឡែកពីអ្នកជំងឺដទៃទៀតប្រសិនបើអាច។ ឧបករណ៍វេជ្ជសាស្ត្រចាំបាច់ត្រូវស្ថិតនៅក្នុងកន្លែងព្យាបាលដាច់ដោយឡែកនិងមិនត្រូវបានចែករំលែកជាមួយអ្នកជំងឺទូទៅផ្សេងទៀតបានឡើយ។ត្រូវសម្អាតឧបករណ៍មុនពេលប្រើឧបករណ៍ទាំងនេះសម្រាប់អ្នកជំងឺផ្សេងទៀត។អ្នកជំងឺឬស្ត្រីទាំងអស់ដែលបានចូលសម្រាកក្នុងមន្ទីរពេទ្យត្រូវទទួលការអប់រំពីអ្នកផ្តល់សេវាក្នុងការអនុវត្តអនាម័យ (លាងដៃ) ឱ្យបានត្រឹមត្រូវ ។

៥. ឧបករណ៍ការពារខ្លួន(PPE)៖ អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពដែលពាក់ព័ន្ធនឹងការថែទាំអ្នកជំងឺផ្ទាល់ត្រូវតែប្រើឧបករណ៍ការពារខ្លួន (PPE)ឱ្យបានត្រឹមត្រូវតាម<u>គោលការណ៍ណែនាំស្តីពីនិតិវិធីប្រតិបត្តិស្តង់ដារស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគជំងឺកូវីដ-១៩នៅមូល ដ្ឋានសុខាភិបាលនិងកន្លែងថែទាំអ្នកជំងឺនៅកម្ពុជា</u>។សម្រាប់អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពដែលផ្តល់សេវាដោយផ្ទាល់ដល់ស្ត្រីដែលក្នុងករណីសង្ស័យថាបានឆ្លងមេរោគនេះត្រូវអនុវត្តដូចតទៅ ៖ អាវវែងមានដៃវែង ម៉ាស់វេជ្ជសាស្ត្រសម្រាប់ផ្តល់សេវាដល់អ្នកជំងឺទាំងអស់ឬរបាំង ម៉ាស់ N95/P2

(បើអ្នកផ្តល់សេវាថែទាំផ្ទៃកសម្ភពត្រូវបានចូលរួមដោយផ្ទាល់នៅក្នុងនីតិវិធីនៃ Aerosolដូចជាការបឺតស្លេស្មឬកំហាក ការផ្តល់ឱសថដោយប្រើបំពង់ខ្យល់ ឬ CPR ) វ៉ែនតាការពារភ្នែក និងស្រោមដៃស្អាត។

៦. សម្រាប់អ្នកផ្តល់សេវាថែទាំផ្ទៃកសម្ភពដែលផ្តល់ការយកចិត្តទុកដាក់ដល់ស្ត្រីដែលមិនមានរោគសញ្ញានៃការឆ្លងមេរោគក្នុងមូលដ្ឋានសុខាភិបាលឧបករណ៍ការពារខ្លួន PPE ចាំបាច់ត្រូវប្រើតាមស្តង់ដារ ការប្រុងប្រយ័ត្ននិងវាយតម្លៃហានិភ័យ ។ ការពាក់ឧបករណ៍ការពារខ្លួន PPE សម្រាប់ទំនាក់ទំនងជាមួយអ្នកជំងឺទាំងអស់គឺអាស្រ័យលើភាពអាចរកបាននៃឧបករណ៍ការពារខ្លួន PPE នៅក្នុងមន្ទីរពេទ្យរបស់ខ្លួន និងការវិនិច្ឆ័យផ្ទាល់ខ្លួនអំពីហានិភ័យនៃការប្រឈមដោយអ្នកផ្តល់សេវាថែទាំផ្ទៃកសម្ភព។

សូមមើល<u>គោលការណ៍ណែនាំស្តីពីនិតិវិធីប្រតិបត្តិស្តង់ដារស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគជំងឺកូវីដ-១៩នៅមូលដ្ឋានសុខាភិបាលនិងកន្លែងថែទាំអ្នកជំងឺនៅកម្ពុជា។</u>

ស្រោមដៃនិងអាវការពារត្រូវពាក់ក្នុងពេលផ្តល់ការថែទាំដែលអាចពាក់ព័ន្ធនឹងការប៉ះពាល់ឈាម វត្ថុរាវ កំហាក លាមក ទឹកនោម ទឹករំអិលតាមមាត់ ការបូមឈាម ត្បាររន្ធមាត់ស្បូន និងសម្អាតទ្វារមាស។

ក្នុងដំណាក់កាលទី២ និងទី៣ នៃការឈឺពោះសម្រាល ត្រូវលាងដៃ របាំងម៉ាស់ របាំងវះកាត់ អាវការពារ វ៉ែនតាការពារភ្នែកនិងស្រោមដៃ។

សម្រាប់ព័ត៌មានលម្អិតស្តីពីការពាក់នៅពេលណា ដោយអ្នកណា និងកន្លែងណាមាននៅក្នុង<u>ឧបសម្ព័ន្ធទី២ ឧបករណ៍ការពារខ្លួនសម្រាប់ជំងឺកូវីដ-១៩។</u>

៧. ក្នុងអំឡុងពេលនៃការទាក់ទងជាមួយអ្នកជំងឺ អ្នកផ្តល់សេវាថែទាំផ្ទៃកសម្ភពត្រូវអនុវត្តគោលការណ៍ណែនាំស្តីពីការបង្ការនិងការគ្រប់គ្រងដូចជាការលាងដៃដែលជួយកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩។

៨. ការលាងសម្អាតផ្ទៃដោយប្រើផលិតផលសម្អាត (ឧ. 5% Sodium Hypochlorite (bleach)) និងជូតផ្ទៃដោយកន្សែង ក្រដាសឬក្រណាត់ស្អាតមុននិងក្រោយផ្តល់សេវានិងបន្ទាប់មកត្រូវលាងដៃ។ សូមមើល<u>ឧបសម្ព័ន្ធទី៣ - ការអនុវត្តការលាងសម្អាត។</u>

៩. បន្ថែមលើការអនុវត្តការគ្រប់គ្រងការឆ្លងមេរោគជាប្រចាំ អ្នកផ្តល់សេវាថែទាំផ្ទៃកសម្ភពចាំបាច់ត្រូវរក្សាចម្ងាយយ៉ាងតិច១.៥ ម៉ែត្រនៅពេលផ្តល់សេវាដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង។ ទោះជាយ៉ាងណាក៏ដោយអ្នកផ្តល់សេវាត្រូវរក្សាការពិនិត្យរាងកាយនិងត្រូវលាងដៃមុននិងក្រោយប៉ះស្ត្រី។

១០. អ្នកផ្តល់សេវាថែទាំផ្ទៃកសម្ភពនិងបុគ្គលិកផ្សេងទៀតក៏ត្រូវរក្សាចម្ងាយប្រវែង២ម៉ែត្រពីគ្នាតាមដែលអាចធ្វើទៅបាន ទោះបីមិនមានវត្តមានអ្នកជំងឺក៏ដោយ។

## II. គំនូសបំព្រួញនៃការពិគ្រោះជំងឺនិងការវាយតម្លៃពីសញ្ញាគ្រោះថ្នាក់ចំពោះស្ត្រីដែលសង្ស័យឬបញ្ជាក់ថាមានជំងឺកូវីដ ១៩

សាកសួរស្ត្រីមុនពេលមកដល់មូលដ្ឋានសុខាភិបាល (ឧ. តាមទូរស័ព្ទបើអាច) ធ្វើរោគវិនិច្ឆ័យក្នុងបន្ទប់ដាច់ដោយឡែកពីផ្លូវចូលទៅកន្លែងចុះឈ្មោះផ្តល់ម៉ាស់វះកាត់សម្រាប់ការ វាយតម្លៃផ្ទាល់ជាមួយស្ត្រី




**ការដាក់ស្ត្រីនៅដាច់ដោយឡែក**

- ណែនាំស្ត្រីត្រឡប់ទៅផ្ទះដោយមធ្យោបាយផ្ទាល់ខ្លួនបើអាច(សូមកុំប្រើមធ្យោបាយធ្វើដំណើរសាធារណៈ ឬធ្វើដំណើរជាមួយអ្នកផ្សេង)

➢ **ការផ្តល់សេវា ANC ជាបន្ត**

- បន្តផ្តល់សេវា ANC បន្ទាប់ពីរយៈពេល១៤ថ្ងៃនៃការបាត់រោគសញ្ញា និងលទ្ធផលអវិជ្ជមាន។
- ផ្តល់សេវា ANC តាមមធ្យោបាយផ្សេងទៀត ក្នុងអំឡុងពេលស្ត្រីស្នាក់នៅក្នុងផ្ទះ ប្រសិនបើសេវា ANC មិនអាចពន្យារពេលបាន។
- ណែនាំស្ត្រីពីលេខទូរស័ព្ទរបស់មន្ទីរពេទ្យ ប្រសិនបើពាក់ព័ន្ធ។

**ជូនដំណឹងផ្នែកសម្ភពជាបន្ទាន់**

➢ **ការចូលសម្រាកពេទ្យ ការថែទាំជាសកល**

- ដាក់ស្ត្រីដាច់ដោយឡែក
- អនុវត្តន៍តាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងការបង្ការការឆ្លងរោគ
- ជូនដំណឹងដល់ក្រុមការងារផ្នែកសម្ភព ទារក
- ប្រឹក្សាយោបល់ជាមួយក្រុមការពារជំងឺឆ្លង
- កំណត់ចំនួនអ្នកថែទាំ
- ព្យាបាលតាមរោគសញ្ញាដែលរកឃើញ

- **ជំងឺកូវីដ-១៩**
  - ណែនាំពីវិធីសាស្ត្រអនាម័យនិងការបង្ការការឆ្លងរោគ
  - ផ្តល់ព័ត៌មានស្តីពីជំងឺកូវីដ-១៩ ។
- **អ្វីដែលមិនគួរធ្វើ**
  - ស្ត្រីមិនត្រូវទៅសាលារៀន កន្លែងធ្វើការ និងកន្លែងសាធារណៈឬជិះរថយន្តសាធារណៈ។
  - កុំប្រាស្រ័យទាក់ទងជាមួយសមាជិកនិងអ្នកខាងក្រៅ
- **អ្វីដែលគួរធ្វើ**
  - ស្នាក់នៅក្នុងផ្ទះ។
  - បើកបង្អួចឱ្យខ្យល់ចេញចូល។
- **លក្ខខណ្ឌធ្វើតេស្ត គិតត្រឹមបច្ចុប្បន្នភាពចុងក្រោយបង្អស់**
  - ក្តៅខ្លួនលើស៣៨អង្សាឬប្រវត្តិក្តៅខ្លួនឬមានបញ្ហាផ្លូវដង្ហើមស្រួចស្រាល់ (ពិបាកដកដង្ហើម ក្អកនិងឈឺក)
  - សមាជិកគ្រួសារសង្ស័យថាមានជំងឺកូវីដ-១៩
  - ធ្វើដំណើរទៅក្រៅប្រទេសក្នុងរយៈពេល១៤ថ្ងៃមុន
  - មានប្រាស្រ័យទាក់ទងនឹងអ្នកដែលសង្ស័យថាមាន ជំងឺកូវីដ-១៩
  - បុគ្គលិកសុខាភិបាលដែលប៉ះពាល់អ្នកជំងឺផ្ទាល់
  - មានអ្នកដំណើរតាមកប៉ាល់ក្នុងរយៈពេល១៤ថ្ងៃមុននឹងចេញរោគសញ្ញា
  - អ្នកជំងឺចូលសម្រាកពេទ្យ
- **ស្ថានភាពផ្សេងទៀតនៃផលវិបាកផ្នែកសុខភាពសាធារណៈ។**

- **ការបញ្ជូន**
  - លទ្ធផលវិជ្ជមាននៃជំងឺកូវីដ-១៩ រួមជាមួយរោគសញ្ញាណាមួយផ្សេងទៀត
- **មុនពេលសម្រាល**
  - អនុវត្តទម្រង់ការវិទ្យុសាស្ត្រ
  - តាមដានទារកតាមសញ្ញាដែលបង្ហាញ
- **សម្រាល**
  - បន្ទប់ត្រូវមានខ្យល់ចេញចូល
  - ជំងឺកូវីដ-១៩ មិនធ្វើឱ្យមានការផ្លាស់

ប្តូររបៀបនៃការសម្រាល លុះត្រាមានសញ្ញាបង្ហាញពីតម្រូវការនៃការសម្រាលដោយវះកាត់

- **ទីតាំងរបស់ម្តាយនិងទារកទើបនឹងកើត**
  - ម្តាយនិងទារកក្នុងបន្ទប់តែមួយ
  - ពិភាក្សាពីហានិភ័យនិងអត្ថប្រយោជន៍ជាមួយឪពុកម្តាយ
  - ស្វែងរកតម្រូវការរបស់ស្ត្រី ដោយផ្អែកលើស្ថានភាពរបស់ជំងឺជម្រើសរបស់ស្ត្រី សុខភាពផ្លូវចិត្តរបស់ស្ត្រី លទ្ធផលតេស្តនិងសមត្ថភាពរបស់បុគ្គលិកពេទ្យ
- **ការបំបៅកូនដោយដោះម្តាយឬផលិតផលជំនួសទឹកដោះម្តាយ**
  - គាំទ្រការបំបៅកូនដោយទឹកដោះម្តាយ
- **វិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់**
  - ណែនាំពីអនាម័យដៃ ប្រើម៉ាស់ ប្រាស្រ័យទាក់ទងកម្លាតឆ្ងាយពីគ្នា វិធីបង្ការពេលក្អក កណ្តាស់ពេលប៉ះទារកទើបនឹងកើត។
- **ការប្រាស្រ័យទាក់ទងជាមួយអ្នកដែលសង្ស័យថាមានជំងឺកូវីដ-១៩**
  - ការប្រាស្រ័យទាក់ទងផ្ទាល់លើសពី១៥នាទី
  - ការប្រាស្រ័យទាក់ទងក្នុងបន្ទប់បិទជិតលើស២ម៉ោងក្នុងផ្ទះ។

# ការថែទាំផ្ទៃពោះមុនសម្រាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

## I. គោលបំណង

គោលបំណងសំខាន់នៃការណែនាំនេះ គឺដើម្បីធានាថាអ្នកផ្តល់សេវាផ្នែកសម្ភពអាចផ្តល់សេវាថែទាំមុនសម្រាលដោយការគោរពនិងជាលក្ខណៈបុគ្គល ដើម្បីការពារ សុវត្ថិភាពរបស់ស្ត្រី ក្រុមគ្រួសារ និងអ្នកផ្តល់សេវា ក្នុងអំឡុងពេលមានការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩។

ក្នុងអំឡុងការរាតត្បាត អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពនឹងព្យាយាមអាចកាត់បន្ថយការទាក់ទងជាមួយស្ត្រីដោយផ្ទាល់ ដើម្បីកាត់បន្ថយការឆ្លងជំងឺកូវីដ-១៩ ដែលតម្រូវឱ្យការពិនិត្យផ្ទៃពោះខ្លះត្រូវធ្វើឡើងដោយប្រើតាមប្រព័ន្ធ telehealth ដោយការជជែកតាមទូរស័ព្ទឬវីដេអូ (ទំនាក់ទំនងពីចម្ងាយ) ដើម្បីធានាថាគ្មានការអាក់ខានក្នុងការផ្តល់សេវាឬរអាក់រអួលក្នុងការថែទាំតាមកាលកំណត់។

អ្នកផ្តល់សេវាថែទាំមុនសម្រាល ត្រូវធ្វើការវិនិច្ឆ័យក្នុងការសម្រេចចិត្តថាតើស្ត្រីណាដែលអាចសមស្របសម្រាប់កាលវិភាគនៃការណាត់ជួបជំនួសនៃការថែទាំផ្ទៃពោះផ្ទាល់ (ទំនាក់ទំនង) ដែលរាប់បញ្ចូលទាំងទំនាក់ទំនងពីចម្ងាយ។ ជាទូទៅសម្រាប់ស្ត្រីដែលមានទូរស័ព្ទដែលអាចធ្វើការប្រាស្រ័យទាក់ទងតាមទូរស័ព្ទបាន អាចមានហានិភ័យទាបពីការឆ្លងជំងឺកូវីដ-១៩ ហើយត្រូវចងចាំថាស្ថានភាពហានិភ័យអាចផ្លាស់ប្តូរ នៅពេលមានផ្ទៃពោះកាន់តែធំ ដូចនេះការវាយតម្លៃហានិភ័យត្រូវតែកើតមាននៅគ្រប់ពេលដែលទំនាក់ទំនងជាមួយអ្នកផ្តល់សេវាដើម្បីស្វែងរកការថែទាំ។

ក្នុងករណីចាំបាច់ការពិនិត្យរាងកាយស្ត្រីមុនសម្រាល ត្រូវអនុវត្តដោយការគោរពនិងធ្វើយ៉ាងឆាប់រហ័សដើម្បីកាត់បន្ថយពេលវេលាដែលបានចំណាយនូវគម្លាតចម្ងាយពីគ្នា ១ម៉ែត្រកន្លះ។

## II. ការរៀបចំទីកន្លែងនិងការផ្តល់សេវាថែទាំមុនពេលសម្រាល ៖

- ពិគ្រោះជំងឺនិងពិនិត្យគ្រប់ស្ត្រីទាំងអស់ដើម្បីរករោគសញ្ញាជំងឺកូវីដ-១៩មុនពេលចូលទៅទទួលសេវា។
- កំណត់ចំនួនស្ត្រី ចូលក្នុងមូលដ្ឋានសុខាភិបាល។
- ផ្លាស់ប្តូរកាលវិភាគនៃការថែទាំផ្ទៃពោះមុនសម្រាល (បន្ទាប់ពីវាយតម្លៃហានិភ័យ)។
- អាចផ្លាស់ប្តូរពីការថែទាំផ្ទៃពោះមុនសម្រាលនៅមូលដ្ឋានសុខាភិបាលទៅធ្វើនៅសហគមន៍ ឬកន្លែងដែលអាចធ្វើទៅបាន (ការផ្តល់សេវាតាមមូលដ្ឋាន)។
- សម្រាប់ការវាយតម្លៃដែលមិនតម្រូវឲ្យពិនិត្យរាងកាយអាចធ្វើនៅក្រៅបន្ទប់ដែលមានបរិយាកាសល្អ។
- កំណត់ចំនួនអ្នកចូលរួមគាំទ្រដូចជាដៃគូ កុមារ(នៅពេលមកពិនិត្យថែទាំផ្ទៃពោះមុនសម្រាល)

- វាយតម្លៃការពិនិត្យរាងកាយដាច់ដោយឡែកពីការពិគ្រោះពិភាក្សាក្នុងការថែទាំផ្ទៃពោះមុនសម្រាល។
- ផ្តល់ទំនាក់ទំនងនៅនឹងកន្លែង'one-stop' ដោយរួមបញ្ចូលសេវាដូចជា អេកូសាស្ត្រ ឱសថ តេស្តឈាមនិងការធ្វើតេស្តផ្សេងៗទៀត ដើម្បីបង្ការមិនឱ្យស្ត្រីត្រឡប់ទៅមកញឹកញាប់។
- ត្រូវផ្តល់សេវាថែទាំស្ត្រីមានផ្ទៃពោះឱ្យឆ្ងាយពីសេវាជំងឺទូទៅ ទោះជាការសង្គ្រោះបន្ទាន់ឬការថែទាំជំងឺក្រៅក៏ដោយ។ ត្រូវមានការលើកទឹកចិត្តឱ្យបន្តការថែទាំជាស្តង់ដារ ក្នុងអំឡុងពេលស្ត្រីមានផ្ទៃពោះ ពេលសម្រាលនិងក្រោយសម្រាល ដើម្បីកាត់បន្ថយការប្រាស្រ័យទាក់ទងរវាងអ្នកផ្តល់សេវាជាមួយនិងស្ត្រី ព្រមទាំងដៃគូ ក្នុងការកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងមូលដ្ឋានសុខាភិបាល។
- ផ្តល់ការអប់រំ ការពិគ្រោះពិភាក្សាស្តីពីព័ត៌មានសុខាភិបាល ដោយឆ្មបឬអ្នកផ្តល់សេវាថែទាំផ្នែកសម្ភព នៅពេលចាប់ផ្តើមផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាល ការអប់រំនេះត្រូវរួមបញ្ចូលទាំងការរក្សាគម្លាតសង្គម (អង្គុយឱ្យឆ្ងាយពីគ្នាយ៉ាងតិច១.៥ម៉ែត្រ) រោគសញ្ញា ទម្រង់ការសម្រាប់ការរក្សាគម្លាតគ្នានៅក្នុងផ្ទះ សញ្ញាសង្គ្រោះបន្ទាន់។ល។
- ផ្តល់ការអប់រំសុខភាពនិងលើកទឹកចិត្តដល់ស្ត្រីឱ្យមានទំនាក់ទំនងជាប្រចាំជាមួយអ្នកផ្តល់សេវា ដើម្បីកាត់បន្ថយការភ័យខ្លាចអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំពោះស្ត្រីមានផ្ទៃពោះនិងទារកទើបនឹងកើត។ គោលការណ៍ណែនាំការបង្ការ ទាក់ទងនឹងជំងឺកូវីដ-១៩ សម្រាប់ស្ត្រីមានផ្ទៃពោះក៏ដូចជាប្រជាជនទូទៅដែរ។
- ផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាលនិងសេវាថែទាំផ្នែកសម្ភព ដល់ស្ត្រីដែលមិនមានចេញរោគសញ្ញា ជំងឺកូវីដ-១៩ ហើយប្រសិនបើអាច កុមារ សមាជិកគ្រួសារនិងដៃគូដទៃទៀតមិនគួរចូលរួមដំណើរជាមួយស្ត្រីដើម្បីមកទទួលសេវាឡើយ។
- បន្តការផ្តល់សេវានិងការពិនិត្យរាងកាយជាធម្មតាសម្រាប់សេវាថែទាំផ្ទៃពោះមុនសម្រាល ប៉ុន្តែត្រូវយកចិត្តទុកដាក់បន្ថែមលើវិធានការត្រួតពិនិត្យការឆ្លងរោគ។ ស្ត្រីទាំងអស់ត្រូវលាងដៃពេលមកដល់កន្លែងរង់ចាំ ពេលចូលបន្ទប់ព្យាបាល ពេលចេញពីបន្ទប់ព្យាបាលនិងពេលចេញពីមូលដ្ឋានសុខាភិបាល។
- អ្នកផ្តល់សេវាថែទាំសម្ភពត្រូវលាងដៃមុននិងក្រោយពេលផ្តល់សេវា ព្រមទាំងលាងដៃភ្លាមបន្ទាប់ពីពិនិត្យរាងកាយរបស់ស្ត្រី។ លាងដៃភ្លាមបន្ទាប់ពីធ្វើការសម្អាតគុ សម្ភារនិងក្រោយពេលក្អកឬកណ្តាស់។
- គួរកាត់បន្ថយចំនួនលើកនៃការមកពិនិត្យផ្ទៃពោះមុនសម្រាលគឺជាការសមស្របដើម្បីបន្ថយចំនួនស្ត្រីមកពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាល ដែលអាចបន្ថយការប្រឈមមុខនឹងការឆ្លងមេរោគ។ ការថែទាំផ្ទៃពោះមុនសម្រាលដែលមិនអាចផ្តល់ជូននៅមូលដ្ឋានសុខាភិបាលអាចផ្តល់ជូន បានតាមរយៈ ទូរស័ព្ទ whatsapp, skype, facetime (កន្លែងដែលមាន)

និងសមស្របបំផុតនៅពេលដែលស្ត្រីមិនត្រូវការវាយតម្លៃគ្លីនិក ធ្វើតេស្តនិងអង្កេត។ កាលវិភាគផ្លាស់ប្តូរនៃការទទួលសេវានិងខ្លឹមសារនៃការផ្តល់សេវា ការថែទាំមុនសម្រាល ការថែទាំក្រោយសម្រាល តាមរយៈទូរស័ព្ទដែលមានរៀបរាប់ដូចខាងក្រោម។ នៅពេលស្ត្រីមកទទួលការពិនិត្យផ្ទៃពោះអ្នកផ្តល់សេវាគួរពិចារណាពី ការផ្តល់ថ្នាំគ្រាប់ជាតិដែក អាស៊ីតហ្វូលិក Ultrasonography OGT(Oral Glucose Tolerence) និងការ ផ្តល់ថ្នាំបង្ការចៀសវាងការមកទទួលសេវាច្រើនដង។

- ខ្លឹមសារជាក់លាក់នៃការថែទាំផ្ទៃពោះមុនសម្រាលនៅតែមិនផ្លាស់ប្តូរក្នុងបរិបទនៃជំងឺកូវីដ-១៩។ ទោះយ៉ាងណាអ្នកផ្តល់សេវាថែទាំផ្នែកសម្ភពចាំបាច់ត្រូវយល់ដឹងអំពីហានិភ័យនៃការបាក់ទឹកចិត្ត ការថប់អារម្មណ៍ អំពីហិង្សាដោយសារតែផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គមនៃជំងឺរាតត្បាតជំងឺកូវីដ-១៩ដោយសារផលប៉ះពាល់ជំងឺកូវីដ-១៩។ បញ្ហាទាំងនេះបន្ថែមការព្រួយបារម្ភដល់ស្ត្រីនិងអ្នកផ្តល់សេវាថែទាំផ្ទៃពោះនិងសម្ភពដែលត្រូវការឱ្យមានយន្តការណែនាំបញ្ជូនបន្តដើម្បីជួយស្ត្រីទាំងនេះ។

**សម្រាប់ស្ត្រីមានផ្ទៃពោះដែលមានរោគសញ្ញាជំងឺកូវីដ-១៩ ៖**

- **ក្នុងករណីស្ត្រីត្រូវអនុវត្តការស្នាក់នៅក្នុងផ្ទះ** ការណាត់ជួបម្តងទៀតត្រូវធ្វើឡើងវិញបន្ទាប់ពីបញ្ចប់រយៈពេលស្នាក់នៅក្នុងផ្ទះ។

  ស្ត្រីអាចបញ្ឈប់ការស្នាក់នៅក្នុងផ្ទះក្រោមលក្ខខណ្ឌ៣យ៉ាង ៖ ស្ត្រីមិនមានអាការៈក្តៅខ្លួន៣ថ្ងៃដោយមិនប្រើថ្នាំបន្ថយកំដៅហើយរោគសញ្ញាផ្សេងទៀតមានភាពប្រសើរឡើង (ឧ. ដង្ហើមខ្លីឬក្អក) និង

  យ៉ាងហោចណាស់៧ថ្ងៃបានកន្លងផុតទៅចាប់តាំងពីរោគសញ្ញាដំបូងរបស់ស្ត្រីបានលេចចេញមក។ ស្ត្រីត្រូវបានគេណែនាំឱ្យជួបគ្រូពេទ្យប្រសិនបើស្ថានភាពនេះកាន់តែអាក្រក់ទៅៗ ឬប្រសិនបើរោគសញ្ញាមិនមានភាពប្រសើរឡើងក្រោយរយៈពេល៧ថ្ងៃ។

  ប្រសិនបើស្ត្រីមានលទ្ធភាពទៅកន្លែងធ្វើតេស្តរកមេរោគបាន ៖ ស្ត្រីអាចនឹងចាកចេញពីផ្ទះបន្ទាប់ពីនៅដាច់ដោយឡែកក្នុងផ្ទះក្រោមលក្ខខណ្ឌ៣ដូចតទៅ ៖ ស្ត្រីលែងក្តៅខ្លួនហើយរោគសញ្ញាផ្សេងទៀតមានភាពប្រសើរឡើង ហើយស្ត្រីបានធ្វើតេស្តអវិជ្ជមានចំនួនពីរដងជាប់គ្នាក្នុងរយៈពេល ២៤ម៉ោងបន្ទាប់ពីតេស្តនីមួយៗ។

- **ស្ត្រីដែលមានរោគសញ្ញាជំងឺកូវីដ-១៩ ហើយមានបញ្ហាផលវិបាកទាក់ទងនឹងការមានផ្ទៃពោះ** ចាំបាច់ត្រូវពិនិត្យដាច់ដោយឡែកពីអ្នកដទៃនៅក្នុងបន្ទប់ដាច់ដោយឡែកប្រសិនបើអាចឬចាប់ពីពេលទទួលសេវារហូតដល់ពេលបញ្ចប់ការទទួលសេវានិងមិនមានស្ត្រីផ្សេងទៀតនៅក្បែរ ដើម្បីកាត់បន្ថយឱកាសឆ្លងដល់អ្នកផ្តល់សេវានិងស្ត្រីដទៃទៀត។ ស្ត្រីដែលមានរោគសញ្ញាត្រូវពាក់ម៉ាស់វះកាត់ហើយអ្នកផ្តល់សេវាត្រូវពាក់ឧបករណ៍ការពារខ្លួនPPE តាមអនុសាសន៍របស់ក្រសួងសុខាភិបាល។

ផ្នែកខាងក្រោមនេះផ្តល់នូវការណែនាំជាក់ស្តែង ស្តីពីទំនាក់ទំនងក្នុងការថែទាំផ្ទៃពោះមុនសម្រាលដែលត្រូវបានអនុវត្តពីចម្ងាយ (ទូរស័ព្ទ កម្មវិធីផ្ញើសារ telehealth)និងផ្តល់នូវទិសដៅសម្រាប់បន្តផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាលប្រកបដោយការគោរពក្នុងអំឡុងពេលមានជំងឺកូវីដ-១៩រាតត្បាត។ ឯកសារនេះមានបំណងគាំទ្រការផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាលតាមវិធីផ្សេងៗគ្នា ប៉ុន្តែមិនសម្រាប់ជំនួសគោលនយោបាយនិងពិធីសារដែលមានស្រាប់នោះទេ។ ការផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាលត្រូវអនុវត្តតាមគោលការណែនាំ របស់ក្រសួងសុខាភិបាលស្តីពីការផ្ទៃពោះមុនសម្រាលនៅពេលដែលស្ថានភាពរាតត្បាតជាសាកលជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់។

**មុនពេលចាប់ផ្តើមផ្តល់សេវាតាមទូរស័ព្ទ ៖**

- បង្កើតយុទ្ធសាស្ត្រសម្រាប់មូលដ្ឋានសុខាភិបាលឬប្រព័ន្ធសុខាភិបាល ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ដើម្បីណែនាំនិងតាមដានការផ្លាស់ប្តូរនៅក្នុងទំនាក់ទំនងសម្រាប់ផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាល
- ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកនូវបច្ចេកវិទ្យា សម្រាប់ទំនាក់ទំនងផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាលពីចម្ងាយ រួមទាំងធនធានគ្រប់គ្រាន់ សម្រាប់អ្នកផ្តល់សេវាក្នុងការទំនាក់ទំនងតាមទូរស័ព្ទ (ការភ្ជាប់ប្រព័ន្ធទូរស័ព្ទចល័ត ឧបករណ៍សម្រាប់សាកថ្ម ស៊ីមកាត កាតទូរស័ព្ទឬថវិកាសម្រាប់ទិញកាតទូរស័ព្ទ)
- ទទួល កត់ត្រានិងរៀបចំឯកសារដោយមានការយល់ព្រមពីស្ត្រីសម្រាប់ទំនាក់ទំនងសេវាថែទាំផ្ទៃពោះមុនសម្រាលពីចម្ងាយ។

## III. ពេលវេលាកំណត់សម្រាប់ការផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

ត្រូវរក្សាកាលវិភាគនៃការថែទាំផ្ទៃពោះមុនសម្រាលរបស់ក្រសួងសុខាភិបាលនាពេលបច្ចុប្បន្នតាមដែលអាចធ្វើទៅបាន។ នៅកន្លែងដែលមានបច្ចេកវិទ្យានិងសេវាទូរស័ព្ទ ការថែទាំផ្ទៃពោះមុនសម្រាលខ្លះអាចផ្តល់ពីចម្ងាយទៅបាន។
ខាងក្រោមជាកាលវិភាគនៃពិនិត្យផ្ទៃពោះដែលអាចអនុវត្តបានទល់មុខគ្នា និងធ្វើពីចម្ងាយ។

**ពេលវេលាកំណត់នៃការផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាល ៖**

- **ការពិនិត្យលើកទី១** ៖ គភ៌មានអាយុតិចជាង១២សប្តាហ៍ ការផ្តល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី២ ៖** គភ៌មានអាយុពី២០-២៤សប្តាហ៍ ការផ្តល់សេវាពីចម្ងាយ
- **ការពិនិត្យលើកទី៣ ៖** គភ៌មានអាយុពី៣០-៣២សប្តាហ៍ ការផ្តល់សេវាពីចម្ងាយ
- **ការពិនិត្យលើកទី៤ ៖** គភ៌មានអាយុពី៣៦-៣៨សប្តាហ៍ ការផ្តល់សេវាដោយផ្ទាល់

រាល់ការផ្តល់សេវាថែទាំផ្ទៃពោះមុនសម្រាល ស្ត្រីត្រូវទទួលនូវ ៖

- ការវាយតម្លៃនិងព័ត៌មាន អំពីរោគសញ្ញាជំងឺកូវីដ-១៩រួមមាន ៖ គ្រុនក្តៅ ក្អក ហៀរសំបោរ ឈឺកនិងពិបាកដកដង្ហើម។ ប្រសិនបើស្ត្រីរាយការណ៍ពីរោគសញ្ញាឬធ្លាប់មានទាក់ទងជាមួយអ្នកសង្ស័យថាមានជំងឺកូវីដ-១៩ ដែលបានបញ្ជាក់នូវព័ត៌មានជាក់លាក់តាមប្រទេសពីការដាក់ខ្លួនឱ្យនៅដាច់ពីគេ ត្រូវផ្តល់ដំបូន្មានឱ្យទាក់ទងតាមទូរស័ព្ទឬកំណត់ពេលវេលាឡើងវិញតាមដែលអាចធ្វើទៅបាន (ប្រសិនបើត្រូវការជាបន្ទាន់សូមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល)។
- ព័ត៌មានអំពីសញ្ញាគ្រោះថ្នាក់ក្នុងពេលមានផ្ទៃពោះនិងការត្រៀមជុំវិញកំណើតរួមមាន ៖ ការធ្លាក់ឈាមតាមទ្វារមាស ប្រកាច់ ឈឺក្បាលខ្លាំង ស្រវាំងភ្នែក គ្រុនក្តៅ អស់កម្លាំងខ្លាំង ឈឺពោះខ្លាំងដកដង្ហើមញាប់ឬពិបាក ។
- ការវាយតម្លៃហានិភ័យនៃការមានផ្ទៃពោះដែលកំពុងតែកើតមានរួមមាន ៖ សុខុមាលភាពអារម្មណ៍ និងសុវត្ថិភាពផ្ទាល់ខ្លួន។
  ប្រសិនបើការវាយតម្លៃហានិភ័យបានរកឃើញថាមានផលវិបាកដែលអាចនឹងកើតមានឬកើតមានជាក់ស្តែង ចាំបាច់ត្រូវជួបឱ្យបានច្រើនដងឬជួបទល់មុខគ្នា។
- ដើម្បីធានាបាននូវផែនការថែទាំដ៏សមស្របត្រូវមានឯកសារផ្តល់សេវាគ្រប់គ្រាន់ ។

គ្រប់សេវាដែលត្រូវផ្តល់ គួរបង្កើតឱ្យមានការបញ្ចូលនូវព័ត៌មានដែលទទួលបានតាមការទាក់ទងស្ត្រីពីចម្ងាយទៅក្នុងបញ្ជីកត់ត្រា។

គួរពិចារណាបង្កើតឱ្យមានទម្រង់ការសម្រាប់ធ្វើការតាមដានសកម្មភាព ការផ្គត់ផ្គង់សម្ភារបរិក្ខារ និងការពិនិត្យតាមដាន។ ទម្រង់ការនេះត្រូវច្បាស់លាស់ កត់ត្រានិងរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវ និងសម្រាប់ធ្វើការបញ្ជូនជាបន្ទាន់។

## IV. ការថែទាំផ្ទៃពោះមុនសម្រាលពីចម្ងាយ

សេចក្តីណែនាំខាងក្រោមនេះគឺសម្រាប់ស្ត្រីដែលត្រូវការសេវាថែទាំផ្ទៃពោះមុនសម្រាលពីចម្ងាយ ការអនុវត្តជាស្តង់ដារគួរតែបន្តសម្រាប់រាល់ការជួបផ្ទាល់មុខគ្នា។
នេះមិនមែនជាសេចក្តីណែនាំពេញលេញ សម្រាប់ការមករកសេវាថែទាំផ្ទៃពោះមុនសម្រាលនោះទេ ប៉ុន្តែជាសេចក្តីណែនាំសម្រាប់ស្ត្រីដែលត្រូវទទួលសេវាថែទាំផ្ទៃពោះមុនសម្រាលពីចម្ងាយ។

សកម្មភាពសម្រាប់ផ្តល់ជូនស្ត្រីដែលត្រូវការសេវាថែទាំផ្ទៃពោះមុនសម្រាលពីចម្ងាយ (ដោយមិនគិតពីបច្ចេកទេស) ៖

- ការថែទាំផ្អែកសម្ពពប្រកបដោយការគោរព រួមមាន៖
  - ផ្តល់សេវាដល់ស្ត្រីមានផ្ទៃពោះ ដោយសេចក្តីថ្លៃថ្នូរនិងការគោរព
  - ការរក្សាការសម្ងាត់និងភាពឯកជន

- មិនមានភាពរើសអើង

- សកម្មភាពដែលគួរធ្វើ នៅគ្រប់ទំនាក់ទំនងជាមួយស្ត្រី ៖
  - ណែនាំខ្លួនអ្នកនិងសួរសុខទុក្ខស្ត្រីក្នុងលក្ខណៈរាក់ទាក់
  - ការវាយតម្លៃពីរោគសញ្ញានៃជំងឺកូវីដ-១៩ (ទាំងស្ត្រីនិងអ្នកពាក់ព័ន្ធ) និងឆ្លើយតបសមស្របប្រសិនបើរោគសញ្ញាត្រូវបានរកឃើញ
  - សាកសួរនិងយកចិត្តទុកដាក់លើសុខុមាលភាពរាងកាយ សង្គម អារម្មណ៍និងវប្បធម៌
  - សាកសួរអំពីការវិវត្តនៃការមានផ្ទៃពោះ
  - តាមដាននិងវាយតម្លៃជាប្រចាំ
  - ពន្យល់ពីរបៀបនៃការធ្វើតេស្តសំណាកនិងការយល់ព្រម
  - សាកសួរប្រវត្តិជំងឺនិងធ្វើការវាយតម្លៃជាបន្តទៅលើកត្តាហានិភ័យ
  - ពិភាក្សាពីសញ្ញាគ្រោះថ្នាក់ ៖
    - ការធ្លាក់ឈាមតាមទ្វារមាស
    - ការប្រកាច់
    - ឈឺក្បាលខ្លាំង និងស្រវាំងភ្នែក
    - គ្រុនក្តៅនិងអស់កម្លាំងខ្លាំង
    - ឈឺពោះខ្លាំង
    - ដកដង្ហើមញាប់និងពិបាកដកដង្ហើម
  - ផ្តល់ពេលវេលាសមស្របសម្រាប់សំណួរ ចម្លើយ
  - ផ្តល់ព័ត៌មានជាក់លាក់អំពីការមានផ្ទៃពោះនិងការអប់រំ
  - ផ្តល់ការពិគ្រោះពិភាក្សានិងធ្វើការបញ្ជូនទៅកន្លែងដែលសមស្រប
  - ពិភាក្សាពីផែនការសម្រាប់ការបញ្ជូនបន្ទាន់ពីផ្ទះរបស់ស្ត្រីទៅមូលដ្ឋានសុខាភិបាលប្រសិនបើចាំបាច់
  - រៀបចំផែនការសម្រាប់ការជួបដើម្បីផ្តល់ការថែទាំផ្ទៃពោះមុនសម្រាលបន្តបន្ទាប់។

| ការផ្ដល់សេវាថែទាំផ្ទៃពោះមុនសម្រាល | |
|---|---|
| **ការផ្ដល់ការថែទាំផ្ទៃពោះមុនសម្រាលលើកទី១ (ដោយផ្ទាល់)** | |
| ពិនិត្យលើកទី១៖<br>គភ៌មានអាយុតិចជាង១២សប្ដាហ៍ | • ថ្លឹងទម្ងន់ វាស់កម្ពស់<br>• ប្រសិនជាអាច គណនាសន្ទស្សន៍ម៉ាស់រាងកាយ( BMI)<br>$BMI=\frac{\text{ទម្ងន់(គិតជា គ.ក)}}{\text{កំពស់}x\text{កំពស់ (គិតជា ម)}}$<br>• យកសញ្ញាជីវិត (សម្ពាធឈាម ជីពចរ កម្ដៅ ចង្វាក់ដង្ហើម)<br>• ពិនិត្យរកភាពស្លេកស្លាំង<br>• ពិនិត្យរកមើលហើម ដុំពកនៅក ដោះ<br>• ធ្វើតេស្តទឹកនោម បញ្ជាក់ពីការមានផ្ទៃពោះក្នុងករណីដែលការពិនិត្យគ្លីនិកមិនទាន់បញ្ជាក់ ច្បាស់<br>• វាស់កម្ពស់ស្បូន (ប្រសិនបើមិនអាចវាស់បាន ធ្វើការលូកទ្វារមាស ឬពិនិត្យអេកូសាស្ត្រ)<br>• គណនារកថ្ងៃ ខែ សម្រាលរំពឹងទុក<br>• មើលស្នាមវះយកកូននិងស្នាមវះពោះដទៃទៀត ពីមុនមក<br>• ធ្វើតេស្តឈាមរក ៖ ក្រុមឈាម រ៉េស៊ីស(Rh) អេម៉ូក្លូប៊ីន/អេម៉ាតូគ្រីត មេរោគដែលអាចចម្លងពីម្ដាយទៅកូន (អេដស៍-ស្វាយ) គ្រុនចាញ់ក្នុងករណីចាំបាច់<br>• ផ្ដល់ថ្នាំបង្ការជំងឺតេតាណូសបើសិនជាស្ត្រីមិនធ្លាប់ទទួលបានថ្នាំបង្ការនេះទេ ឬផ្ដល់ថ្នាំបង្ការបន្តទៅតាមកំណត់ត្រាក្នុងប័ណ្ណផ្ទាល់ ថ្នាំបង្ការជំងឺតេតាណូស<br>• ប្រសិនជាចាំបាច់ ធ្វើតេស្តឈាមពេញលេញ (Full blood count testing) ដើម្បីបញ្ជាក់ចំនួនគោលិកាឈាម<br>• ធ្វើតេស្តទឹកនោមរកប្រូតេអ៊ីន គ្លុយកូស<br>• ផ្ដល់ប្រឹក្សាឱ្យបរិភោគអាហារមានសុខភាពល្អ ធ្វើសកម្មភាពធម្មតា ដើម្បីកុំឱ្យឡើងទម្ងន់ហួសកំណត់<br>• ពិនិត្យរកសញ្ញារងគ្រោះដោយអំពើហិង្សាដែលអាចបណ្ដាលឱ្យផលវិបាក ក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលសម្រាល ដើម្បីសង្គ្រោះ ផ្ដល់ប្រឹក្សានិងកត់ត្រាជាឯកសារ |

| | |
|---|---|
| | • អប់រំពីការត្រៀមជុំវិញកំណើត<br>• ធ្វើការណាត់ជួបសម្រាប់ការពិនិត្យផ្ទៃពោះលើកទី២<br>• ផ្តល់ព័ត៌មានអំពីសុវត្ថិភាពតាមរយៈទូរស័ព្ទនិងកាលវិភាគនៃសេវាការថែទាំផ្ទៃពោះមុនសម្រាល និងទទួលបានការយល់ព្រមពីស្ត្រីក្នុងការផ្តល់សេវា។ ត្រូវបញ្ជាក់លេខទូរស័ព្ទនិងលេខទូរស័ព្ទបម្រុងរបស់ស្ត្រីឱ្យបានត្រឹមត្រូវ<br>• ធានាថាស្ត្រីមានលេខទំនាក់ទំនងរបស់អ្នកផ្តល់សេវាតាមទូរស័ព្ទឬលេខទូរស័ព្ទទំនាក់ទំនងរបស់មូលដ្ឋានសុខាភិបាល។ |

| **ការផ្តល់ការថែទាំផ្ទៃពោះមុនសម្រាលលើកទី២ ពីចម្ងាយតាមទូរស័ព្ទ** | |
|---|---|
| ពិនិត្យលើកទី២ ៖ គភ៌មានអាយុពី ២០-២៤សប្តាហ៍ | អ្នកផ្តល់សេវាគួរអនុវត្តសកម្មភាពដូចខាងក្រោម ៖<br>• ណែនាំខ្លួនអ្នកនិងសួរសុខទុក្ខស្ត្រីក្នុងលក្ខណៈរួសរាយរាក់ទាក់<br>• វាយតម្លៃចំពោះរោគសញ្ញាដែលអាចកើតមាននៃជំងឺកូវីដ-១៩ (ទាំងស្ត្រីនិងអ្នកពាក់ព័ន្ធ)និងបញ្ជូនឬណែនាំនៅទៅរកសេវាថែទាំផ្សេងទៀត ប្រសិនបើរកឃើញមានរោគសញ្ញាជំងឺកូវីដ-១៩<br>• សាកសួរអំពីសុខភាពទូទៅនិងសុខុមាលភាពរបស់ស្ត្រី រួមទាំងការទល់លាមក ការក្លាយរោគតាមផ្លូវនោម បញ្ហាដំណេកនិងអំពើហិង្សា<br>• សាកសួរនិងយកចិត្តទុកដាក់លើសុខុមាលភាពរាងកាយ សង្គម អារម្មណ៍និងវប្បធម៌ ដោយមានការគាំទ្រពីអ្នកដែលពាក់ព័ន្ធនិងការធ្វើផែនការសុវត្ថិភាព<br>• សួរអំពីការវិវត្តនៃការមានផ្ទៃពោះ<br>• តាមដាននិងវាយតម្លៃជាប្រចាំ<br>• ពន្យល់ពីរបៀបនៃការធ្វើតេស្តសំណាកនិងការយល់ព្រម<br>• សាកសួរប្រវត្តិជំងឺនិងធ្វើការវាយតម្លៃជាបន្តទៅលើកត្តាហានិភ័យ ដោយសួរពីបញ្ហាណាមួយត្រូវបានរកឃើញកាលពីពេលថែទាំផ្ទៃពោះមុនសម្រាលលើកទី១<br>• ពិភាក្សាពីសញ្ញាគ្រោះថ្នាក់ ៖<br>- ការធ្លាក់ឈាមតាមទ្វារមាស<br>- ការប្រកាច់<br>- ឈឺក្បាលខ្លាំង និងស្រវាំងភ្នែក |

| | |
|---|---|
| | - គ្រុនក្តៅនិងអស់កម្លាំងខ្លាំង<br>- ឈឺពោះខ្លាំង<br>- ដកដង្ហើមញាប់និងពិបាកដកដង្ហើម<br>• អប់រំពីការត្រៀមជុំវិញកំណើត<br>• ផ្តល់ព័ត៌មានជាក់លាក់អំពីការមានផ្ទៃពោះដោយគណនាអាយុផ្ទៃពោះ និងថ្ងៃ ខែ ឆ្នាំសម្រាលកូនរំពឹងទុក<br>• សាកសួរស្ត្រីពីការលូតលាស់របស់ទារកក្នុងផ្ទៃ ដូចជាការកំរើករបស់ទារក ទំហំផ្ទៃពោះធំជាងមុន<br>• សាកសួរនិងផ្តល់ដំបូន្មានអំពីរបបអាហារ<br>• សាកសួរពីឱសថដែលកំពុងប្រើ (ថ្នាំគ្រាប់ជាតិដែក ថ្នាំទម្លាក់ព្រូន។ល។)<br>• ផ្តល់ការអប់រំពីការលើកកម្ពស់សុខភាពដូចជាការបំបៅកូនដោយទឹកដោះម្តាយ ការដាក់ស្បែកប៉ះស្បែក ការផ្តល់ថ្នាំបង្ការនិងការពន្យារកំណើត<br>• ផ្តល់ការពិគ្រោះពិភាក្សានិងធ្វើការបញ្ជូនទៅកន្លែងដែលសមស្រប<br>• ពិភាក្សាពីផែនការសម្រាប់ការបញ្ជូនបន្ទាន់ពីផ្ទះរបស់ស្ត្រី ទៅមូលដ្ឋានសុខាភិបាល ប្រសិនបើចាំបាច់<br>• ផ្តល់ពេលវេលាសមស្របសម្រាប់សំណួរ ចម្លើយ<br>• រៀបចំផែនការសម្រាប់ការជួបដើម្បីផ្តល់ការថែទាំផ្ទៃពោះមុនសម្រាលបន្តបន្ទាប់<br>• រំលឹកស្ត្រីអំពីសារៈសំខាន់នៃការថែទាំមុនពេលសម្រាលបន្តរក្សាការណាត់ជួបលើកក្រោយនិងដឹងពីអ្វីដែលស្ត្រីត្រូវធ្វើ ប្រសិនបើមានការព្រួយបារម្ភទាក់ទងនឹងការមានផ្ទៃពោះឬសញ្ញាគ្រោះថ្នាក់ណាមួយ។ |
| ពិនិត្យលើកទី៣៖ គភ៌មានអាយុពី ៣០-៣២ សប្តាហ៍ | អនុវត្តដូចការថែទាំផ្ទៃពោះលើកទី២ ពីចម្ងាយតាមទូរស័ព្ទដោយបន្ថែមសកម្មភាពមួយចំនួនដូចខាងក្រោម ៖<br>• វាយតម្លៃកត្តាគ្រោះថ្នាក់ជាបន្ត ដូចជា ការធ្លាក់ឈាម ជំងឺទឹកនោមផ្អែម លើសសម្ពាធឈាម។ល។<br>• សាកសួរពីការឡើងទម្ងន់<br>• ពិភាក្សាពីសញ្ញានៃការឈឺពោះសម្រាលមិនគ្រប់ខែ និងអ្វីដែលស្ត្រីត្រូវធ្វើប្រសិនបើមានសញ្ញានៃការឈឺពោះសម្រាលចាប់ផ្តើម<br>• ពិភាក្សាពីការបែកស្រោមទឹកភ្លោះ និងការស្វែងរកជំនួយ<br>• ពិភាក្សាពីសារៈសំខាន់នៃការមានអ្នកកំដរនៅជាមួយក្នុងពេលឈឺពោះសម្រាល។ |

| ការផ្តល់ការថែទាំផ្ទៃពោះមុនសម្រាលលើកទី៤ដោយផ្ទាល់ | |
|---|---|
| ពិនិត្យលើកទី៤ ៖ គភ៌មានអាយុពី ៣៦-៣៨សប្តាហ៍ | • ថ្លឹងទម្ងន់ ធ្វើការប្រៀបធៀបទៅនឹងទម្ងន់ថ្លឹងលើកមុនដើម្បីវាយតម្លៃរកបញ្ហាអាហារូបត្ថម្ភ<br>• យកសញ្ញាជីវិត (សម្ពាធឈាម ជីពចរ កម្តៅ ចង្វាក់ដង្ហើម) ធៀបជាមួយកំណត់ត្រាលើកមុន<br>• ពិនិត្យរកសញ្ញាគ្រោះថ្នាក់ក្នុងពេលមានផ្ទៃពោះ និងគ្រប់គ្រងផលវិបាក<br>• ពិនិត្យវាយតម្លៃភាពស្លេកស្លាំង បើនៅមានស្លេកស្លាំង ត្រូវបញ្ជូន<br>• ពិនិត្យរកមើលហើម ដុំពកនៅក ដោះ<br>• វាស់កម្ពស់ស្បូន ស្ទាបផ្ទៃពោះក្រែងមានកូនភ្លោះ ឬកូនច្រើន<br>• ស្ទាបផ្ទៃពោះក្រែងកូននៅទទឹងពោះ ឬទម្រង់មិនធម្មតា ចលនាកូនក្នុងផ្ទៃ<br>• ស្តាប់ចង្វាក់បេះដូងកូន<br>• ពិនិត្យអេកូសាស្រ្តក្នុងករណីជាចាំបាច់<br>• ធ្វើតេស្តឈាមរក ក្រុមឈាម រ៉េស៊ុស(Rh) អេម៉ូក្លូប៊ីន/អេម៉ាតូគ្រីត (បើមិនទាន់បានធ្វើ)<br>• រំលឹកស្រ្តីផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ឱ្យមកសម្រាលកូននៅមន្ទីរពេទ្យដែល មានសេវាថែទាំព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍<br>• ពិនិត្យរកមេរោគគ្រុនចាញ់ក្នុងករណីចាំបាច់<br>• ផ្តល់ថ្នាំបង្ការជំងឺតេតាណូសបន្តបើចាំបាច់<br>• ប្រសិនជាចាំបាច់ ធ្វើតេស្តឈាមពេញលេញ (Full blood count testing) ដើម្បីបញ្ជាក់ចំនួនគោលិកាឈាម<br>• ធ្វើតេស្តទឹកនោមរកប្រូតេអ៊ីន គ្លុយកូស (បើសិនចាំបាច់)<br>• ពិនិត្យរកសញ្ញារងគ្រោះដោយអំពើហិង្សាដែលអាចបណ្តាលឱ្យផលវិបាកក្នុងអំឡុងពេលមានផ្ទៃពោះនិងពេលសម្រាលដើម្បីសង្គ្រោះ ផ្តល់ប្រឹក្សានិងកត់ត្រាជាឯកសារ<br>• រំលឹកម្តាយនៅពេលមកសម្រាលកូន ឱ្យយកមកជាមួយនូវសៀវភៅសុខភាពមាតា ប័ណ្ណចាក់ថ្នាំបង្ការជំងឺតេតាណូស។ |

# ការថែទាំពេលឈឺពោះសម្រាលក្នុងអំឡុងពេលមាន ជំងឺកូវីដ-១៩

## I. ការរៀបចំសេវាថែទាំពេលឈឺពោះសម្រាលនៅមូលដ្ឋានសុខាភិបាល

ដើម្បីចូលរួមជាមួយក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការចម្លងរោគមេរោគកូវីដ-១៩ មូល ដ្ឋានសុខាភិបាលនីមួយៗត្រូវពិចារណានូវវិធានការដូចខាងក្រោម ៖

១. ការពិគ្រោះជំងឺនិងការស្រាវជ្រាវរកជំងឺកូវីដ-១៩ចាំបាច់ត្រូវធ្វើឡើងសម្រាប់ស្ត្រីនិងដៃគូរបស់ពួកគេមុនពេលចូលក្នុងមូលដ្ឋានសុខាភិបាលដូចមានចែងក្នុងផ្នែកមុន។

២. ត្រូវប្រុងប្រយ័ត្នចំពោះការទប់ស្កាត់ការឆ្លងរោគជាទៀងទាត់ សម្រាប់ការថែទាំក្នុងអំឡុងពេលឈឺពោះសម្រាលនិងពេលសម្រាល។ ត្រូវចងចាំថាជំងឺកូវីដ-១៩ អាចបង្កឱ្យដល់ក្រុមស្ត្រីដែលមានហានិភ័យទាប មានសភាពស្រាលហើយទន្ទឹមនឹងនោះ ផលវិបាកធ្ងន់ធ្ងរដែលមិនទាក់ទងនឹងជំងឺកូវីដ-១៩ អាចកើតមានក្នុងអំឡុងពេលមានផ្ទៃពោះនិងសម្រាលកូន ដែលធ្វើឱ្យមានអត្រាស្លាប់ខ្ពស់សម្រាប់ម្តាយនិងទារកទើបនឹងកើត។

ក្នុងករណីមានបញ្ហាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងទារកទើបនឹងកើតមិនគួរពន្យារពេលក្នុងការយកចិត្តទុកដាក់ចំពោះម្តាយឬទារកទើបនឹងកើតឡើយ។

**ការត្រៀមរៀបចំបន្ទប់សម្រាល**

ស្ត្រីភាគច្រើនក្នុងអំឡុងពេលឈឺពោះសម្រាលដែលមិនមានរោគសញ្ញាផ្លូវដង្ហើម ត្រូវបន្តទទួលសេវាដូចធម្មតានៅក្នុងបន្ទប់សម្រាល។ ទោះយ៉ាងណាក៏ដោយត្រូវប្រុងប្រយ័ត្នខ្ពស់ចំពោះការអនុវត្តការទប់ស្កាត់ការឆ្លងរោគដូចជា ៖

- ត្រូវមានឧបករណ៍ការពារខ្លួនPPE គ្រប់គ្រាន់ ដូចជា៖ របាំងមុខ ម៉ាស់ ស្រោមដៃ វ៉ែនតា អាវធំ ទឹកសម្លាប់មេរោគសម្រាប់លាងដៃ សាប៊ូនិងទឹកនិងឧបករណ៍សម្អាត នៅក្នុងពេលឈឺពោះសម្រាល។
- ត្រូវសម្អាតផ្ទៃបន្ទប់និងសម្ភារឱ្យបានស្អាតជាមួយនឹងថ្នាំបាញ់សម្លាប់មេរោគនិងក្រណាត់ស្អាតបន្ទាប់ពីស្ត្រីឬបុគ្គលិកបានប៉ះពាល់។
- បុគ្គលិកគួរអនុវត្តអនាម័យដៃឱ្យបានទៀងទាត់ លាងដៃមុននិងក្រោយពេលពិនិត្យអ្នកជំងឺម្នាក់ៗ។

៣. ស្ត្រីទាំងអស់ត្រូវទទួលការលើកទឹកចិត្តឱ្យទូរស័ព្ទទៅមូលដ្ឋានសុខាភិបាល (បើអាចធ្វើទៅបាន) ដើម្បីទទួលបានការប្រឹក្សាក្នុងពេលចាប់ផ្តើមឈឺពោះសម្រាលនិងជូនដំណឹងដល់អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពអំពីរោគសញ្ញាផ្លូវដង្ហើមឬរោគសញ្ញាផ្សេងៗទាក់ទងនឹងជំងឺកូវីដ-១៩ដែលមានប្រយោជន៍ដល់ការរៀបចំផែនការថែទាំឬការបញ្ជូន។

៤. ស្ត្រីទាំងអស់មានសិទ្ធិទទួលបានការយកចិត្តទុកដាក់ដោយសេចក្តីមេត្តា សេចក្តីថ្លៃថ្នូរនិងការគោរព។ ស្ត្រីគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មាន ផ្តល់ការយល់ព្រម មិនយល់ព្រម និងការសម្រេចចិត្តរបស់គាត់ រួមមានការប្តូរឥរិយាបថក្នុងអំឡុងពេលឈឺពោះសម្រាល និងពេលសម្រាល។

៥. ដៃគូដែលមិនមានរោគសញ្ញាគួរអនុញ្ញាតឱ្យស្នាក់នៅជាមួយស្ត្រីក្នុងអំឡុងពេលឈឺពោះសម្រាល និងសម្រាល។ ការគាំទ្រពីដៃគូ អាចកាត់បន្ថយពេលវេលានៃការឈឺពោះសម្រាល បង្កើនការសម្រាលកូនតាមធម្មជាតិ បន្ថយការសម្រាលកូនដោយការវះកាត់និងអន្តរាគមន៍វេជ្ជសាស្ត្រដទៃទៀត។ ប្រសិនបើដៃគូរបស់គាត់មានរោគសញ្ញា ពួកគេត្រូវនៅដាច់ដោយឡែកពីគេនិងមិនអនុញ្ញាតឱ្យចូលក្នុងបន្ទប់ឈឺពោះសម្រាល។ ស្ត្រីគួរតែត្រូវបានណែនាំនៅពេលធ្វើផែនការអំពីការសម្រាលរបស់ពួកគេដើម្បីកំណត់ស្វែងរកការគាំទ្រផ្សេងទៀតប្រសិនបើចាំបាច់។

## II. សម្រាប់ស្ត្រីដែលមានរោគសញ្ញាសង្ស័យនៃជំងឺកូវីដ-១៩

### ១. មណ្ឌលសុខភាព

- ត្រូវបញ្ជូនស្ត្រីដែលមានករណីសង្ស័យនៃជំងឺកូវីដ-១៩ ទៅមន្ទីរពេទ្យបង្អែកដែលមានសេវាព្យាបាលជំងឺកូវីដ-១៩។
- ករណីស្ត្រីឈឺពោះសម្រាលដែលមិនអាចបញ្ជូនទៅមូលដ្ឋានសុខាភិបាលដែលមានសេវាព្យាបាលជំងឺកូវីដ-១៩ទាន់ពេល អ្នកផ្តល់សេវាផ្នែកសម្ភពត្រូវ ៖
    - ផ្តល់សេវាសម្រាលតាមធម្មតា ដោយអនុវត្តតាមគោលការណែនាំIPC
    - ពិគ្រោះយោបល់ជាមួយក្រុមឆ្លើយតបបន្ទាន់របស់មន្ទីរសុខាភិបាលដើម្បីធ្វើតេស្តរកជំងឺកូវីដ-១៩ និងរៀបចំផែនការបញ្ជូនស្ត្រីចេញពីមូលដ្ឋានសុខាភិបាល និងចត្តាឡីស័កនៅមូលដ្ឋានសុខាភិបាលដែលមានសេវាព្យាបាលជំងឺកូវីដ-១៩ នៅពេលដែលស្ត្រីមានស្ថេរភាព។

### ២. មន្ទីរពេទ្យ

១. បន្ទាប់ពីពិគ្រោះជំងឺនិងការវាយតម្លៃ បានរកឃើញថាស្ត្រីមានរោគសញ្ញាដូចគ្នានឹងជំងឺកូវីដ-១៩ (SAR-CoV-2) និងតម្រូវឱ្យស្ត្រីចូលសម្រាកពេទ្យ ហើយការថែទាំទាំងអស់គួរតែបន្តផ្តល់នៅក្នុងបន្ទប់ដែលនៅដាច់ដោយឡែកពីគេ សម្រាប់ការស្នាក់នៅរបស់ស្ត្រីរហូតដល់ចេញពីមូលដ្ឋានសុខាភិបាលបើអាចធ្វើទៅបាន ។ ត្រូវកាត់បន្ថយចំនួនបុគ្គលិកដែលត្រូវចូលក្នុងបន្ទប់របស់ស្ត្រី

ដោយគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

២. ស្ត្រីដែលមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរគួរតែត្រូវបានផ្តល់ ម៉ាស់វះកាត់ ហើយបុគ្គលិកគួរតែត្រូវបានផ្តល់ជូននូវឧបករណ៍ការពារខ្លួនPPE សម្រាប់រយៈពេលនៃការថែទាំសុខភាព។

៣. នៅពេលដែលស្ត្រីមិនមានលទ្ធភាពទទួលបានបន្ទប់តែមួយ វានៅតែចាំបាច់ក្នុងការស្វែងរកវិធីនៃការបំបែកស្ត្រីដែលមានជំងឺ ពីស្ត្រីទូទៅនៅក្នុងបន្ទប់តែមួយដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងរោគ។ វិធានការនេះក៏ត្រូវអនុវត្តផងដែរចំពោះស្ត្រីពេលចូលសម្រាកពេទ្យក្នុងអំឡុងពេលមានផ្ទៃពោះនិងក្រោយពេលសម្រាលរួច។

៤. វិធីនៃការសម្រាលកូនត្រូវកំណត់ដោយផ្អែកលើលក្ខខណ្ឌនៃការសម្រាលនិងចំណង់ចំណូលចិត្តរបស់ស្ត្រី។ការសម្រេចចិត្តទាំងនេះមិនគួរត្រូវបានជះឥទ្ធិពលដោយជំងឺកូវីដ-១៩ លើកលែងតែមាតាឬទារកមានបញ្ហាបន្ទាន់ក្នុងការអនុវត្តធម្មតា។

៥. ការថែទាំក្នុងអំឡុងពេលឈឺពោះសម្រាលមិនគួរខុសពីធម្មតាឡើយ ស្ត្រីដែលមានជំងឺកូវីដ-១៩ រួមជាមួយនិងរោគសញ្ញាផ្លូវដង្ហើមទោះបីជាស្រួចស្រាល់ឬស្រាលក៏ដោយត្រូវធ្វើការតាមដានតុល្យភាពសារធាតុរាវរៀងរាល់ម៉ោងក្នុងអំឡុងពេលឈឺពោះសម្រាលដើម្បីចៀសវាងហានិភ័យនៃការផ្តល់លើសតម្រូវការ។

៦. ប្រសិនបើស្ត្រីដែលសម្រាលតម្រូវឱ្យមានការវះកាត់យកកូន បុគ្គលិកទាំងអស់នៅក្នុងបន្ទប់សម្រាលគួរតែពាក់ឧបករណ៍ការពារខ្លួនPPE។ហានិភ័យធំបំផុតចំពោះបុគ្គលិកក្នុងបន្ទប់សម្រាលក្នុងអំឡុងការវះកាត់គឺការឆ្លងរោគតាមរយៈការសុងតាមផ្លូវដង្ហើម (វីរុសដែលមានក្នុងខ្យល់)។

៧. មិនមានភ័ស្តុតាងណាមួយទេដែលបញ្ជាក់ថាការផ្តល់ថ្នាំស្តេរ៉ូអ៊ីតសម្រាប់ជួយដល់សួតរបស់ទារកបង្កឱ្យមានគ្រោះថ្នាក់ណាមួយនៅក្នុងបរិបទនៃជំងឺកូវីដ-១៩។ ថ្នាំស្តេរ៉ូអ៊ីតគួរផ្តល់ឱ្យតែក្នុងករណីចាំបាច់។ ទោះបីជាក្នុងករណីណាក៏ដោយការសម្រាលបន្ទាន់មិនគួរពន្យារពេលឡើយ។

## III. ការថែទាំជាសារវន្តទារកទើបនឹងកើត

ការរំខាននៃជំងឺកូវីដ-១៩ទៅលើសេវាថែទាំសុខភាពមាតានិងទារកក្នុងពេលមានជំងឺរាតត្បាតអាចនាំឱ្យមានអត្រាស្លាប់ខ្ពស់និងភាពមានជំងឺក្នុងចំណោមទារកទើបនឹងកើតនិងអាចប៉ះពាល់ដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព២០៣០(SDG)។

សកម្មភាពគន្លឹះខាងក្រោមនេះគឺសម្រាប់បន្តផ្តល់សេវាថែទាំជាសារវន្តទារកទើបនឹងកើតជាប្រចាំ (មិនមែនផ្ទុកជំងឺកូវីដ-១៩) នៅតាមមូលដ្ឋានសុខាភិបាលនិងតាមផ្ទះ ដើម្បីបង្ការការឆ្លងរោគ។

**១. សកម្មភាពគន្លឹះនៃការថែទាំជាសារវន្តទារកទើបនឹងកើតក្នុងពេលមានជំងឺកូវីដ-១៩ រាតត្បាត**

- សេវាថែទាំជាសារវន្តទារកទើបនឹងកើត ចាំបាច់ត្រូវផ្តល់ជូនសម្រាប់ទារកទើបនឹងកើតភ្លាមទាំងអស់ (លើកលែងតែត្រូវការសង្គ្រោះបន្ទាន់) ស្របតាមពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់។

- ដាក់ទារកទើបនឹងកើតភ្លាមនៅជាមួយម្តាយឱ្យស្បែកទារកប៉ះជាមួយស្បែកម្តាយ ទោះបីជាម្តាយមានផ្ទុកវីរុស ឬកើតជំងឺកូវីដ-១៩ក៏ដោយ ប៉ុន្តែត្រូវអនុវត្តអនាម័យឱ្យបានសមស្រប នៅពេលកូនដោយទឹកដោះម្តាយ ដូចជា លាងសម្អាតដៃឱ្យបានស្អាតជាមួយសាប៊ូ ឬអាល់កុល មុននិងក្រោយពេលប៉ះពាល់ទារក ពាក់ម៉ាស់ដើម្បីកាត់បន្ថយលទ្ធភាពនៃដំណក់ទឹកមាត់តូចៗ ដែលអាចមានផ្ទុកវីរុសកូវីដ-១៩ ឆ្លងរាលដាលដល់ទារក។ ។
- ចំពោះទារកទើបនឹងកើតភ្លាម ហើយត្រូវការសង្គ្រោះបន្ទាន់ ត្រូវអនុវត្តការសង្គ្រោះទារកដូចក្នុងពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់ ប៉ុន្តែធានាឱ្យមានការចូលរួមដោយបុគ្គលិកសុខាភិបាលឱ្យមានចំនួនតិចបំផុត (មួយនាក់សម្រាប់ករណីមានហានិភ័យទាបឬពីរនាក់សម្រាប់ជួយសង្គ្រោះបន្ទាន់) និងត្រូវពាក់ឧបករណ៍ការពារខ្លួនPPE។
- អនុវត្តយ៉ាងតឹងរឹងទៅលើការទប់ស្កាត់ការឆ្លងវីរុសកូវីដ-១៩ រួមទាំងការលាងសម្អាតដៃរាល់ពេលមុននិងក្រោយពេលប៉ះទារកទើបនឹងកើត ការពាក់ម៉ាស់និងការរក្សាគម្លាតសុវត្ថិភាព។
- កំណត់ចំនួនភ្ញៀវចេញ ចូលសាកសួរសុខទុក្ខស្ត្រីជាម្តាយនិងទារកក្នុងមូលដ្ឋានសុខាភិបាល។
- ត្រូវធ្វើការថែទាំជាសារវន្តគ្រប់ទារកទើបនឹងកើតទាំងអស់ ហើយធ្វើការថែទាំបន្ថែមលើទារកដែលកើតមិនគ្រប់ខែឬមានទម្ងន់ទាបតាមរបៀបម្តាយកង់ហ្គូរូនិងបន្តការគាំទ្រ សេវាថែទាំក្រោយសម្រាលតាមសេចក្តីណែនាំសម្រាប់អនុវត្តកញ្ចប់សេវាថែទាំពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល សម្រាប់ឱកាស ១០០០ថ្ងៃ នៃការផ្តល់សេវាសម្រាប់ស្ត្រី ទារកនិងកុមារ តាមរយៈការផ្តល់ការពិគ្រោះជំងឺតាមទូរស័ព្ទដោយបុគ្គលិកថែទាំផ្នែកសម្ភពនិងបុគ្គលិកសុខាភិបាលនៅតាមសហគមន៍។
- ចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅពេលទារកកើតភ្លាមនិងមានសញ្ញាចង់បៅក្នុងអំឡុងពេល១ម៉ោងដំបូង និងបន្តបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់កូនមានអាយុ៦ខែ បើទោះបីជាម្តាយឬទារកមានផ្ទុកវីរុសឬកើតជំងឺកូវីដ-១៩ ក៏ដោយ។ ម្តាយដែលឈឺធ្ងន់ គួរតែត្រូវបានគាំទ្រឱ្យប្រឫបាច់ទឹកដោះម្តាយទុកសម្រាប់បញ្ចុកកូន។
- ធានាឱ្យមានអុកស៊ីសែនគ្រប់គ្រាន់ រួមជាមួយនឹងប្រព័ន្ធចែកចាយអុកស៊ីសែននៅក្នុងកន្លែងថែទាំទារកទើបនឹងកើត។
- យកចិត្តទុកដាក់ខ្ពស់ចំពោះទម្រង់ការនៃការបង្ការនិងការទប់ស្កាត់ការឆ្លងរោគក្នុងអំឡុងពេលជំងឺកូវីដ-១៩និងហាមចូលចំពោះភ្ញៀវទាំងអស់ក្នុងបរិវេណផ្នែកសម្ភពលើកលែងតែម្តាយ។ អ្នកម្តាយត្រូវទទួលការបង្ហាត់បង្ហាញអំពី ការលាងសម្អាតដៃជាមួយទឹកនិងសាប៊ូនិងការលាងសម្អាតដៃដោយអាល់កុល។
- សម្អាតកន្លែងថែទាំទារកទើបនឹងកើត ដូចទៅនឹងកន្លែងដែលផ្តល់ការព្យាបាលដល់អ្នកដែលសង្ស័យឬផ្ទុកជំងឺកូវីដ-១៩។

២. ការថែទាំទារកទើបនឹងកើតដែលមានផ្ទុកឬមានរោគសញ្ញានៃការឆ្លងមេរោគកូវីដ-១៩ (តេស្តវិជ្ជមាន)

- ទោះបីជាមិនទាន់មានរោគសញ្ញាជាក់លាក់ត្រូវបានដឹងក៏ដោយ ក៏ទារកទើបនឹងកើតដែលមានជំងឺកូវីដ-១៩ អាចបង្ហាញនូវរោគសញ្ញាខុសៗគ្នាជាងមនុស្សពេញវ័យ។
- ទារកទើបនឹងកើតដែលមានរោគសញ្ញានៃការឆ្លងមេរោគកូវីដ-១៩ ក៏ចាំបាច់ត្រូវតាមដានឱ្យបានហ្មត់ចត់ ពីព្រោះជំងឺផ្សេងៗទៀតរបស់ទារក អាចមានរោគសញ្ញាប្រហាក់ប្រហែលគ្នានឹងជំងឺកូវីដ-១៩ ដែរ។
- មូលដ្ឋានសុខាភិបាលត្រូវមានបន្ទប់ដាច់ដោយឡែកសម្រាប់ទារកទើបនឹងកើតឈឺ ដែលសង្ស័យថាឆ្លងមេរោគកូវីដ-១៩ ហើយកំពុងមានជំងឺផ្សេងៗទៀត ដែលចាំបាច់ត្រូវការសម្រាកពេទ្យ។
- ទារកទើបនឹងកើតដែលមានរោគសញ្ញានៃការឆ្លងមេរោគកូវីដ-១៩ ហើយកើតពីម្តាយដែលមានការសង្ស័យឬផ្ទុកជំងឺកូវីដ-១៩ ឬបានប៉ះពាល់ទៅនឹងអ្នកជំងឺផ្សេងទៀត គួរតែត្រូវដាក់ជាមួយម្តាយក្នុងបន្ទប់ដាច់ដោយឡែក ជាពិសេសក្នុងបន្ទប់ដែលមានសំពាធអវិជ្ជមាន ប្រសិនបើមានឬត្រូវប្រើកង្ហារបឺតខ្យល់ក្នុងករណីគ្មានបន្ទប់ដែលមានសំពាធអវិជ្ជមាន ។
- ត្រូវមានអ្នកផ្តល់សេវាថែទាំដាច់ដោយឡែកសម្រាប់ផ្តល់សេវាក្នុងបន្ទប់ដាច់ដោយឡែកដែលបុគ្គលិកទាំងនោះមកពីផ្នែកថែទាំទារកទើបនឹងកើត។ នៅពេលបុគ្គលិកនៅកន្លែង២ផ្សេងគ្នាហើយត្រូវធ្វើការរួមគ្នា ត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព។
- ផ្គត់ផ្គង់ឧបករណ៍ការពារខ្លួនPPE ឱ្យបានគ្រប់គ្រាន់និងបណ្តុះបណ្តាលបុគ្គលិកពីរបៀបប្រើឱ្យបានត្រឹមត្រូវ។
- ប្រសិនបើចាំបាច់បញ្ជូនទារកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ រួមទាំងអំឡុងពេលបញ្ជូនតាមរថយន្តសង្គ្រោះបន្ទាន់ ត្រូវគោរពតាមគោលការណ៍ណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាលនិងថែទាំសុខភាព។

## IV. ការបំបៅកូនដោយទឹកដោះម្តាយ

កម្មវិធីនិងសេវាការពារ លើកកម្ពស់និងគាំទ្រដល់ការបំបៅកូនដោយទឹកដោះម្តាយ (ទឹកដោះដំបូងនិងបំបៅទឹកដោះម្តាយតែមួយមុខគត់) និងអាហារបំប៉នបន្ថែមសមស្របតាមអាយុប្រកបដោយសុវត្ថិភាពគួរតែរក្សាជាសមាសភាគមួយដ៏សំខាន់នៃកម្មវិធីនិងការឆ្លើយតបសម្រាប់កុមារតូចៗនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ ។

## ១. សកម្មភាពគន្លឹះអាហារូបត្ថម្ភរបស់ទារកនិងកុមារតូចអំឡុងពេលរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- ការពិគ្រោះពិភាក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយ ការគាំទ្រផ្នែកចិត្តសាស្រ្តជាមូលដ្ឋាន និងការគាំទ្រការអនុវត្តពីរបៀបចិញ្ចឹមកូន ត្រូវបានផ្តល់ដល់ស្រ្តីមានផ្ទៃពោះនិងម្តាយដែលមានទារកទើបនឹងកើតនិងកុមារតូច។ ម្តាយ ទារកទើបនឹងកើតនិងកុមារតូច គួរអនុញ្ញាតឱ្យនៅជាមួយគ្នា ដើម្បីអនុវត្តការដាក់ស្បែកទារកប៉ះនិងស្បែកម្តាយ តាមរបៀបម្តាយកង់ហ្គូរូ ដូចនេះម្តាយអាចមើលថែរនិងផ្តល់ភាពកក់ក្តៅដល់កូនពេញមួយថ្ងៃ ជាពិសេសការផ្តល់ភាពកក់ក្តៅដល់ទារកនេះ គួរតែធ្វើឡើងភ្លាមបន្ទាប់ពីសម្រាលក្នុងអំឡុងពេលនៃការបំបៅកូនដោយទឹកដោះម្តាយ។
- អនុវត្តនិងសម្របសម្រួលតាមផែនការកាត់បន្ថយផលប៉ះពាល់លើអាហារូបត្ថម្ភ សុខភាព សន្តិសុខ ស្បៀង ជីវភាពរស់នៅ កសិកម្ម ទឹកស្អាត ការគាំពារសង្គម សុខភាពផ្លូវចិត្ត និងការគាំទ្រដោយផ្តោតលើទារកនិងកុមារតូច។
- ប្រព័ន្ធរបបអាហារ សុខាភិបាល ទឹកស្អាតនិងការគាំពារសង្គម គួរតែផ្តល់សកម្មភាពជាអាទិភាពដល់ការសម្រេចបាននូវសេវាបង្ការ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺរាតត្បាតទៅលើរបបអាហារនិងសុខុមាលរបស់កុមារ ដែលមានប្រព័ន្ធស្រាវជ្រាវនិងព្យាបាលទៅលើកុមារដែលខ្វះអាហារូបត្ថម្ភ។
- គោរពឱ្យបានពេញលេញនូវអនុក្រិតលេខ១៣៣ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារតូច។
- ការផ្សព្វផ្សាយនិងការធ្វើអំណោយទីផ្សារចំពោះអាហារដែលប៉ះពាល់សុខភាព អាហារផ្ទុកសារធាតុខ្លាញ់ខ្ពស់ គ្មានជាតិស្ករឬអំបិល មិនគួរស្វែងរកឬទទួលយកនោះទេ។

## ២. ការបំបៅកូនដោយទឹកដោះម្តាយចំពោះម្តាយដែលមានរោគសញ្ញានៃជំងឺកូវីដ-១៩ ឬតេស្តវិជ្ជមាន

ម្តាយដែលសង្ស័យឬមានផ្ទុកមេរោគកូវីដ-១៩ ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគេនៅក្នុងមូប ដ្ឋានសុខាភិបាលឬនៅផ្ទះ គួរណែនាំឱ្យបន្តការបំបៅកូនដោយទឹកដោះម្តាយជាធម្មតា ដោយអនុវត្តអនាម័យឬការបង្ការជាចាំបាច់ក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្តាយ មានដូចជា ៖

- ការបំបៅកូនដោយទឹកដោះម្តាយដែលមានផ្ទុកមេរោគ SARS-CoV-2 ដែលបង្កឱ្យមានជំងឺកូវីដ-១៩មិនត្រូវបានហាមឃាត់ទេ។ គួរបំបៅទារកតាមគោលការណ៍ណែនាំស្តីពីការបំបៅកូនដោយទឹកដោះម្តាយ និងត្រូវអនុវត្ត រួមមាន ៖
  - លាងដៃជាមួយសាប៊ូនិងទឹកមុននិងក្រោយពេលប៉ះពាល់ទារក
  - សម្អាតវត្ថុដែលប្រើជាប្រចាំ នៅពេលដែលម្តាយមានរោគសញ្ញាកូវីដ-១៩ កាន់ឬប៉ះពាល់ដោយប្រើសាប៊ូនិ ងទឹក

- ប្រសិនបើម្តាយមានរោគសញ្ញាផ្លូវដង្ហើម ត្រូវពាក់ម៉ាស់នៅពេលថែទាំទារក
- រក្សាគម្លាតយ៉ាងហោចណាស់ ១.៥ ម៉ែត្រ ជាមួយមនុស្សផ្សេងទៀត ចៀសវាងការប៉ះភ្នែក ច្រមុះនិងមាត់។

• ម្តាយគ្រប់រូបគួរទទួលបាននូវការគាំទ្រក្នុងការបំបៅកូនដោយទឹកដោះម្តាយនិងគ្រប់គ្រងផលវិបាកនៃការបំបៅកូនដោយទឹកដោះម្តាយ រួមទាំងវិធានការបង្ការនិងការត្រួតពិនិត្យការទប់ស្កាត់ការឆ្លងរោគ។ ការគាំទ្រនេះគួរតែត្រូវបានផ្តល់ដោយបុគ្គលិកសុខាភិបាលជំនាញ និងដោយអ្នកប្រឹក្សាយោបល់អំពីការបំបៅកូនដោយទឹកដោះម្តាយនៅតាមសហគមន៍។

• នៅក្នុងស្ថានភាពដែលម្តាយមានសភាពជំងឺកូវីដ-១៩ធ្ងន់ធ្ងរឬផលវិបាកសុខភាពផ្សេងៗ ស្ត្រីមិនត្រូវបន្តមើលថែទាំទារកឬបំបៅកូនដោយទឹកដោះម្តាយនោះទេ។ ស្ត្រីគួរត្រូវបានលើកទឹកចិត្តក្នុងការច្របាច់យកទឹកដោះទុកសម្រាប់ផ្តល់ដល់ទារកប្រកប ដោយសុវត្ថិភាពដោយអនុវត្តវិធានការអនាម័យដែលសមស្រប។

• ម្តាយនិងបុគ្គលិកសុខាភិបាលត្រូវប្រឹក្សាយោបល់ដើម្បីបន្តការបំបៅកូនដោយទឹកដោះម្តាយ ប្រសិនបើទារកឬកុមារឈឺឬសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ឬជំងឺផ្សេងៗទៀត។

# ការថែទាំក្រោយសម្រាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

## I. ការរៀបចំសេវាថែទាំក្រោយសម្រាល

ដើម្បីបន្ថយការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពនឹងព្យាយាមកាត់បន្ថយរយៈពេលនៃការចូលសម្រាកពេទ្យនិងការទាក់ទងជាមួយស្រ្តីដោយផ្ទាល់ចំពោះស្រ្តីដែលមានស្ថានភាពមិនបន្ទាន់។ដូចនេះការថែទាំក្រោយសម្រាលនិងការថែទាំនៅសហគមន៍អាចមានការផ្លាស់ប្តូរ។ ស្រ្តីនិងទារកដែលមានសុខភាពល្អ អាចអនុញ្ញាតិឱ្យចាកចេញពីមូលដ្ឋានសុខាភិបាលឆាប់ដែលអាស្រ័យទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលហើយសេវាថែទាំក្រោយសម្រាលក្រោយចេញពីមូលដ្ឋានសុខាភិបាលមួយចំនួនអាចធ្វើឡើងបានដោយប្រយោលតាម Telehealth ដូចជាធ្វើតាមទូរស័ព្ទឬសន្ទនាដោយមើលមុខគ្នាឃើញ ដើម្បីធានាថាមិនមានការរាំងស្ទះក្នុងការផ្តល់សេវាឬបែងចែកពេលវេលាក្នុងការថែទាំផ្នែកសម្ភពដល់ស្រ្តី។ ការថែទាំនៅមូលដ្ឋានសុខាភិបាលអាចជំនួសដោយការថែទាំនៅផ្ទះ ដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល។ អ្នកផ្តល់សេវា នឹងពិចារណាដោយផ្អែកលើគ្លីនិក ថាតើស្រ្តីណាគួរទទួល ការថែទាំដោយប្រយោលនិងអាចចាកចេញពីមូលដ្ឋានសុខាភិ បាលបានលឿន។ ការថែទាំដោយប្រយោលសមស្របសម្រាប់ស្រ្តីដែលមានទូរស័ព្ទនិងមានហានិភ័យទាប។

នៅពេលដែលចាំបាច់ដើម្បីពិនិត្យរាងកាយស្រ្តីនៅក្រោយពេលសម្រាល ការពិនិត្យផ្នែករាងកាយនឹងត្រូវបានអនុវត្តដោយការគោរព ប៉ុន្តែធ្វើយ៉ាងឆាប់រហ័សដើម្បីកាត់បន្ថយពេលវេលាដែលបានចំណាយហើយក៏នៅចម្ងាយពីគ្នាយ៉ាងតិច១.៥ ម៉ែត្រ ។

- សេវាថែទាំសុខភាពនិងកន្លែងផ្តល់សេវាអាច ៖
  - ពិគ្រោះជំងឺនិងស្រាវជ្រាវគ្រប់ស្រ្តីនិងអ្នកពាក់ព័ន្ធទាំងអស់ដើម្បីរកសញ្ញានិងរោគសញ្ញាជំងឺកូវីដ-១៩មុនពេលចូលឬចាកចេញពីមូលដ្ឋានសុខាភិបាល។
  - កំណត់ចំនួនអ្នកដែលចូលរួមក្នុងសេវាថែទាំក្រោយសម្រាល ដោយអនុញ្ញាតិឱ្យមានតែស្រ្តីអ្នកពាក់ព័ន្ធ១នាក់ដែលមិនមានរោគសញ្ញាជំងឺកូវីដ-១៩និងអ្នកផ្តល់សេវាថែទាំផ្នែកសម្ភព។ ប្រសិនបើអាចមិនត្រូវអនុញ្ញាតិឱ្យក្មេងឬសមាជិកគ្រួសាររបស់ស្រ្តីចូលឡើយ។
  - បន្ទាប់ពីវាយតម្លៃហានិភ័យរួច អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពអាចផ្លាស់ប្តូររបៀបនៃការផ្តល់ការថែទាំក្រោយសម្រាល ។
  - ធ្វើការវាយតម្លៃរាងកាយដោយឡែកពីការពិភាក្សាឬសំណួរចម្លើយក្នុងការថែទាំក្រោយសម្រាល។
  - មូលដ្ឋានសុខាភិបាលជាច្រើនបានបង្កើតសារ "ហាមភ្ញៀវចូលសួរសុខទុក្ខ" ប្រសិនបើកន្លែងដែលអនុញ្ញាតឱ្យភ្ញៀវចូល ត្រូវពិនិត្យភ្ញៀវទាំងនោះបើមានរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាល់ឬការឆ្លងឬទំនាក់ទំនងជាមួយអ្នកដែលអាចកើតមានជំងឺ-១៩មិនត្រូវអនុញ្ញាតឱ្យចូលក្នុងមូល ដ្ឋាន

សុខាភិបាល។

- ភ្ញៀវពីខាងក្រៅទាំងអស់ត្រូវអនុវត្តតាមនីតិវិធីទប់ស្កាត់ការឆ្លងនិងលាងដៃជាមួយសាប៊ូនិងទឹកពេលចូលនិងចេញពីបន្ទប់ដែលស្ត្រីនិងទារកទើបនឹងកើតត្រូវបានគេថែទាំ។ ការលាងដៃគួរតែធ្វើឡើងម្តងទៀតពេលចាកចេញពីមូលដ្ឋានសុខាភិបាល។

## II. ការថែទាំក្រោយសម្រាលចំពោះម្តាយមានឆ្លងជំងឺកូវីដ-១៩

១. បច្ចុប្បន្ននេះមិនទាន់មានភស្តុតាងណាមួយដែលបញ្ជាក់ថាស្ត្រីដែលមានរោគសញ្ញានៃការឆ្លងមេរោគកូវីដ-១៩ ដែលទើបនឹងសម្រាលកូនរួចភ្លាមនេះត្រូវការបំបែកចេញពីទារកទេ ។ ការបំបែកម្តាយនិងទារកដើម្បីកាត់បន្ថយការឆ្លងជំងឺដែលកើតមានដល់ទារក មានហានិភ័យជាជាងការទទួលបានអត្ថប្រយោជន៍ពីការរក្សាម្តាយនិងទារកឱ្យនៅជាមួយគ្នា ដែលមានភស្តុតាងគាំទ្រដល់ការដាក់ស្បែកប៉ះស្បែកភ្លាមៗ ការចាប់ផ្តើមបំបៅដោះដំបូង សម្រាប់ការរក្សាកំដៅដល់ទារកការការពារការថយចុះជាតិស្ករក្នុងឈាមនិងបន្ថយការឆ្លងរោគនិងការស្លាប់របស់ទារក។

ម្តាយនិងទារកទាំងអស់ដោយមិនគិតពីស្ថានភាពមេរោគកូវីដ-១៩ត្រូវការការគាំទ្រនៅជាមួយគ្នាក្នុងបន្ទប់ ដើម្បីផ្តល់ការបំបៅកូនដោយទឹកដោះម្តាយ អនុវត្តស្បែកប៉ះស្បែកឬថែទាំទារកតាមបែបម្តាយកង់ហ្គូរូ។

២. ស្ត្រីដែលមានរោគសញ្ញាការឆ្លងមេរោគកូវីដ-១៩ ចាំបាច់ត្រូវចៀសវាងការទាក់ទងជាមួយម្តាយនិងទារកដទៃទៀត ការអនុវត្តការលាងដៃមុននិងក្រោយពេលប៉ះពាល់ជាមួយទារក និងពិចារណាពាក់ម៉ាស់ពេលបំបៅ ដាក់ស្បែកប៉ះស្បែកឬថែទាំទារកតាមបែបម្តាយកង់ហ្គូរូ។ ការលាងសម្អាតជាប្រចាំនិងការសម្លាប់មេរោគលើផ្ទៃទាំងអស់ដែលម្តាយមានការប៉ះពាល់ ក៏គួរត្រូវអនុវត្តយ៉ាងទៀងទាត់ផងដែរ។

៣. ម្តាយដែលឆ្លងមេរោគ ទឹកដោះរបស់គាត់ ត្រូវបានបង្ហាញថាមានលទ្ធផលអវិជ្ជមានមេរោគកូវីដ-១៩ ការបំបៅកូនដោយទឹកដោះមិនត្រូវបានគេហាមឃាត់ទេ។ អ្នកផ្តល់សេវាថែទាំផ្នែកសម្ភពត្រូវការគាំទ្រម្តាយក្នុងការបំបៅកូនដោយទឹកដោះម្តាយ ហើយប្រសិនបើស្ត្រីមានការពិបាកត្រូវផ្តល់ការគាំទ្រដល់ស្ត្រីក្នុងការច្របាច់យកទឹកដោះម្តាយនិងផ្តល់ដល់ទារក។

៤. ការឆ្លងរោគចំពោះទារកទើបនឹងកើតមានចំនួនតិច ដែលត្រូវបានគេរាយការណ៍ក្នុងអំឡុងពេលក្រោយសម្រាលហើយទារកទាំងនោះមិនមានអាការៈធ្ងន់ធ្ងរទេ។ ទារកមានបញ្ហានិងមានផលវិបាកភ្លាមនៅពេលសម្រាល ត្រូវបានគេពិចារណាដោយសារតែជំងឺម្តាយឬទារកកើតមិនគ្រប់ខែ។ ទារកកើតមិនគ្រប់ខែឬឈឺអាចត្រូវការការគាំទ្រផ្នែកវេជ្ជសាស្ត្របន្ថែមនៅក្នុងមូលដ្ឋានសុខាភិបាល។ទោះជាយ៉ាងណាក៏ដោយទារកទើបនឹងកើតមានសិទ្ធិទទួលបានការនៅជាមួយម្តាយឪពុក គ្មានម្តាយណាម្នាក់ត្រូវបែកចេញពីកូនដោយគ្មានការយល់ព្រមពីនាងឡើយ។

## III. ការថែទាំក្រោយសម្រាល ចំពោះម្តាយមិនមានឆ្លងរោគ

ការអនុញ្ញាតឱ្យចេញពីមូលដ្ឋានសុខាភិបាលមុនពេលកំណត់ គួរតែត្រូវបានពិចារណាបន្ទាប់ពីការសម្រាលមិនមានផលវិបាកសម្រាប់ម្តាយនិងទារកទើបនឹងកើតដែលមានសុខភាពល្អ។ ក្នុងអំឡុងពេលនៃឆ្លងជំងឺកូវីដ-១៩ក្នុងសហគមន៍ ការអនុញ្ញាតឱ្យចេញពីមូលដ្ឋានសុខាភិបាលអាចត្រូវបានគេពិចារណាបន្ទាប់ពីរយៈពេល៦ម៉ោងចំពោះស្ត្រីដែលសម្រាលតាមធម្មតាដែលមិនមានផលវិបាកនិង២ថ្ងៃចំពោះស្ត្រីដែលសម្រាលដោយការវះកាត់យកកូន ហើយក៏អាស្រ័យទៅតាមស្ថានភាពរបស់ស្ត្រីផងដែរ។ ការអនុញ្ញាតឱ្យចេញនេះអាចធ្វើទៅបានប្រសិនបើម្តាយត្រូវបានគេគាំទ្រយ៉ាងល្អ ហើយមានប្រព័ន្ធសម្រាប់ការគាំទ្រដល់ផ្ទះឬទូរស័ព្ទដោយអ្នកផ្តល់សេវាថែទាំផ្នែកសម្ភព។

## IV. ការពិគ្រោះពិភាក្សាសម្រាប់ម្តាយគ្រប់រូប

១. ការបំបៅកូនដោយទឹកដោះម្តាយត្រូវការការលើកទឹកចិត្តនិងផ្តល់ការគាំទ្រពីអ្នកផ្តល់សេវាថែទាំផ្នែកសម្ភព។

២. ការថប់បារម្ភនិងការធ្លាក់ទឹកចិត្តក្រោយពេលសម្រាលកូន គឺជារឿងធម្មតាសម្រាប់ម្តាយ ហើយក៏អាចកើតមានចំពោះឪពុកផងដែរ។ បញ្ហានេះអាចត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដោយសារការដាក់ឱ្យនៅឆ្ងាយពីសង្គមនិងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុទៅលើគ្រួសារនិងសហគមន៍ទូទៅដែលបណ្តាលមកពីជំងឺកូវីដ-១៩រាតត្បាតជាសាកល។ ឪពុកម្តាយទើបមានកូនដំបូង ចាំបាច់ត្រូវបានលើកទឹកចិត្តឱ្យទាក់ទងជាមួយឪពុកម្តាយ មិត្តភក្តិនិងក្រុមគ្រួសារផ្សេងទៀតតាមរយៈទូរស័ព្ទ ឬតាមប្រព័ន្ធអនឡាញផ្សេងទៀតដែលមាន។ ពួកគេក៏ចាំបាច់ត្រូវបានទទួលដំបូន្មានសមស្រប ការបញ្ជូនទៅរកសេវាឯកទេសនិងព័ត៌មានទំនាក់ទំនងសម្រាប់អ្នកផ្តល់សេវាថែទាំផ្នែកសម្ភព អ្នកផ្តល់សេវាសុខភាពសហគមន៍និងសេវាសង្គ្រោះបន្ទាន់ប្រសិនបើពួកគេមិនអាចដោះស្រាយបានត្រូវហៅទូរស័ព្ទ។

៣. ប្រើទូរស័ព្ទឬវីដេអូ តាមដានក្នុងអំឡុងពេលក្រោយសម្រាល អាចត្រូវបានពិចារណាជំនួសឱ្យការថែទាំក្រោយពេលសម្រាលនៅមូលដ្ឋានសុខាភិបាល ដោយលក្ខខណ្ឌសមស្រប ប្រសិនបើមិនមានការធ្វើតេស្ត ទម្រង់ការឬការពិនិត្យរាងកាយ។

ផ្នែកខាងក្រោមនេះផ្តល់នូវការណែនាំជាក់ស្តែង ស្តីពីទំនាក់ទំនងក្នុងការថែទាំក្រោយសម្រាលដែលត្រូវបានអនុវត្តពីចម្ងាយ (ទូរស័ព្ទ កម្មវិធីផ្ញើសារ telehealth)និងផ្តល់នូវទិសដៅសម្រាប់បន្តផ្តល់សេវាថែទាំក្រោយសម្រាលប្រកបដោយការគោរពក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ រាតត្បាត។ ឯកសារនេះមានបំណងគាំទ្រការផ្តល់សេវាថែទាំក្រោយសម្រាលតាមវិធីផ្សេងៗគ្នា ប៉ុន្តែមិនសម្រាប់ជំនួសគោលនយោបាយនិងពិធីសារដែលមានស្រាប់នោះទេ។ ការផ្តល់ការថែទាំក្រោយសម្រាល នឹងអនុវត្តដូចក្នុងពិធីសារជាតិ ស្តីពីការថែទាំក្រោយសម្រាលលើម្តាយនិងទារកនៅពេលដែលស្ថានភាពរាតត្បាតជាសាកលជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់។

**មុនពេលចាប់ផ្ដើមផ្ដល់សេវាតាមទូរស័ព្ទ ៖**

- បង្កើតយុទ្ធសាស្ត្រសម្រាប់មូលដ្ឋានសុខាភិបាលឬប្រព័ន្ធសុខាភិបាល ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ដើម្បីណែនាំនិងតាមដានការផ្លាស់ប្ដូរនៅក្នុងទំនាក់ទំនងសម្រាប់ផ្ដល់សេវាថែទាំក្រោយសម្រាល។
- ផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិកនូវបច្ចេកវិទ្យា សម្រាប់ទំនាក់ទំនងផ្ដល់សេវាថែទាំក្រោយសម្រាលពីចម្ងាយ រួមទាំងធនធានគ្រប់គ្រាន់ សម្រាប់អ្នកផ្ដល់សេវាក្នុងការទំនាក់ទំនងតាមទូរស័ព្ទ (ការភ្ជាប់ប្រព័ន្ធទូរស័ព្ទចល័ត ឧបករណ៍សម្រាប់សាកថ្ម ស៊ីមកាត កាតទូរស័ព្ទឬថវិកាសម្រាប់ទិញកាតទូរស័ព្ទ)។
- ទទួលនិងចងក្រងឯកសារដោយមានការយល់ព្រមពីស្ត្រីសម្រាប់ទំនាក់ទំនងសេវាថែទាំក្រោយសម្រាលពីចម្ងាយ។

## V. ការថែទាំក្រោយសម្រាលក្រោយពេលចេញពីមូលដ្ឋានសុខាភិបាលក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

ការថែទាំក្រោយសម្រាលត្រូវធ្វើដាច់ដោយឡែកពីគ្នាទៅតាមតម្រូវការរបស់ម្ដាយនិងទារកទើបនឹងកើត។ ការផ្ដល់សេវាថែទាំក្រោយសម្រាលពីចម្ងាយ អាចធ្វើឡើងចំពោះស្ត្រីនិងទារកទើបកើតដែលមានហានិភ័យទាប។ ប្រសិនបើស្ត្រីសមស្របសម្រាប់ធ្វើការប្រាស័យទាក់ទងពីចម្ងាយ អ្នកផ្ដល់សេវាផ្នែកសម្ភពត្រូវធ្វើការពិចារណាគាំទ្រដល់ស្ត្រីនិងដៃគូ ឧទាហរណ៍ ស្ត្រីដែលមានហានិភ័យទាប ស្ត្រីដែលមានកូនច្រើនដងហើយមានបទពិសោធន៍បំបៅកូនដោយទឹកដោះម្ដាយបានជោគជ័យសមស្របនឹងទទួលបានសេវាពីចម្ងាយជាជាងស្ត្រីដែលមានកូនលើកដំបូងដែលមានការជួយគាំទ្រតិចតួចនៅផ្ទះ។

ការផ្ដល់សេវាដោយផ្ទាល់គួរធ្វើសម្រាប់ស្ត្រីនិងទារកទើបនឹងកើត ៖

- ងាយរងគ្រោះ រួមមានអំពើហិង្សាលើស្ត្រី បញ្ហាផ្លូវចិត្តនិងសង្គម
- សម្រាលដោយវះកាត់ឬមានផលវិបាកក្រោយសម្រាល
- សម្រាលកូនមិនគ្រប់ខែនិងទារកមានទម្ងន់ទាប
- មានផលវិបាកផ្សេងៗសម្រាប់ស្ត្រីនិងទារកទើបនឹងកើត
  រួមមានបញ្ហានៃការបំបៅដោះដែលមិនអាចប៉ាន់ប្រមាណដោយការផ្ដល់សេវាពីចម្ងាយ។

ខាងក្រោមនេះ ជាកាលវិភាគណាត់ជួបនិងវិធី ផ្ដល់សេវាថែទាំក្រោយសម្រាលចំពោះម្ដាយនិងកូនដែលណែនាំដោយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកនៃក្រសួងសុខាភិបាល៖

- **ការពិនិត្យលើកទី១** ៖ អំឡុងពេល៧ថ្ងៃក្រោយសម្រាល (ពិនិត្យទាំងម្ដាយនិងកូន)
  ការផ្ដល់សេវាដោយផ្ទាល់

- **ការពិនិត្យលើកទី២ ៖** ថ្ងៃទី១៤ក្រោយសម្រាល(ពិនិត្យទាំងម្ដាយនិងកូន) ការផ្ដល់សេវាពីចម្ងាយ
- **ការពិនិត្យលើកទី៣ ៖** ១ខែកន្លះក្រោយសម្រាល(ពិនិត្យទាំងម្ដាយនិងកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី៤ ៖** កូនមានអាយុ២ខែកន្លះ (ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី៥ ៖** កូនមានអាយុ៣ខែកន្លះ(ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី៦ ៖** កូនមានអាយុ៦ខែ (ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី៧ ៖** កូនមានអាយុ៩ខែ (ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី៨ ៖** កូនមានអាយុ១២ខែ (ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី៩ ៖** កូនមានអាយុ១៨ខែ (ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់
- **ការពិនិត្យលើកទី១០ ៖** កូនមានអាយុ២៤ខែ (ពិនិត្យសុខភាពកូន) ការផ្ដល់សេវាដោយផ្ទាល់

រាល់ការផ្ដល់សេវាពីចម្ងាយនិងដោយផ្ទាល់ស្ត្រីនិងទារកគ្រប់រូបទទួលបានការពិនិត្យដូចខាងក្រោម ៖

- ការវាយតម្លៃនិងព័ត៌មាន អំពីរោគសញ្ញាជំងឺកូវីដ-១៩រួមមាន ៖ ក្ដៅខ្លួន ក្អក ហៀរសំបោរ ឈឺបំពង់ក ឬពិបាកដង្ហើម។ ប្រសិនបើស្ត្រីរាយការណ៍ពីរោគសញ្ញាឬធ្លាប់មានទាក់ទងជាមួយអ្នកសង្ស័យថាមានជំងឺកូវីដ-១៩ ដែលបានបញ្ជាក់នូវព័ត៌មានជាក់លាក់តាមប្រទេសពីការដាក់ខ្លួនឱ្យនៅដាច់ពីគេ ត្រូវផ្ដល់ដំបូន្មានឱ្យទាក់ទងតាមទូរស័ព្ទឬកំណត់ពេលវេលាឡើងវិញតាមដែលអាចធ្វើទៅបាន (ប្រសិនបើត្រូវការជាបន្ទាន់សូមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល អនុសាសន៍របស់ប្រទេស ដើម្បីស្វែងរកការថែទាំ)។
- ព័ត៌មានអំពីសញ្ញាគ្រោះថ្នាក់ក្រោយសម្រាល ៖
  - សញ្ញាគ្រោះថ្នាក់របស់ទារករួមមាន ៖ មិនចង់បៅដោះ ប្រកាច់ ចង្វាក់ដង្ហើមញាប់≥ ៦០ដងក្នុង១នាទី ដង្ហក់ខ្លាំង មិនធ្វើចលនា ក្ដៅខ្លួន≥៣៧.៥អង្សាសេ សីតុណ្ហក្នុងខ្លួន<៣៥.៥អង្សាសេ ខាន់លឿងក្នុងអំឡុង២៤ម៉ោងដំបូងឬលឿងបាតដៃនិងបាតជើង
  - សញ្ញាគ្រោះថ្នាក់របស់ម្ដាយរួមមាន ៖ ធ្លាក់ឈាមក្រោយសម្រាល បម្រុងក្រឡាភ្លើង ក្រឡាភ្លើង ក្លាយរោគនិងរលាកសរសៃវ៉ែន។
- ការវាយតម្លៃហានិភ័យក្រោយសម្រាលដែលកំពុងតែកើតមាន រួមមាន ៖ សុខុមាលភាពអារម្មណ៍និងសុវត្ថិភាពផ្ទាល់ខ្លួន។ ប្រសិនបើការវាយតម្លៃហានិភ័យបានរកឃើញថាមានផលវិបាកដែលអាចនឹងកើតមានឬកើតមានជាក់ស្ដែង ចាំបាច់ត្រូវជួបឱ្យបានច្រើនដងឬជួបទល់មុខគ្នា។
- ដើម្បីធានាបាននូវផែនការថែទាំដ៏សមស្របត្រូវមានឯកសារផ្ដល់សេវាគ្រប់គ្រាន់ ។ គ្រប់សេវាដែលត្រូវផ្ដល់ គួរបង្កើតឱ្យមានការបញ្ចូលនូវព័ត៌មានដែលទទួលបានតាមការទាក់ទងស្ត្រីពីចម្ងាយទៅក្នុងបញ្ជីកត់ត្រា។

## VI. ការថែទាំក្រោយសម្រាលពីចម្ងាយ

សេចក្តីណែនាំខាងក្រោមនេះគឺសម្រាប់ស្ត្រីដែលត្រូវការសេវាថែទាំក្រោយសម្រាលពីចម្ងាយ ការអនុវត្តជាស្តង់ដារគួរតែបន្តសម្រាប់រាល់ការជួបផ្ទាល់មុខគ្នា។ នេះមិនមែនជាសេចក្តីណែនាំពេញលេញ សម្រាប់ការមករកសេវាថែទាំក្រោយសម្រាលនោះទេ ប៉ុន្តែជាសេចក្តីណែនាំសម្រាប់ស្ត្រីដែលត្រូវទទួលសេវាថែទាំក្រោយសម្រាលពីចម្ងាយ។

ពិភាក្សាជាមួយស្ត្រីអំពីធនធានដែលមាននិងបណ្តាញគាំទ្រនៅផ្ទះក្នុងករណីមានការផ្លាស់ប្តូរណាមួយបានកើតឡើងដូចជា គ្រួសារមិនអាចធ្វើដំណើរទៅជួយគាំទ្រស្ត្រីនៅផ្ទះ មិនមានអ្នកមើលថែទាំទារក ត្រូវជួយស្ត្រីឱ្យស្វែងរកធនធានគាំទ្រក្នុងសហគមន៍បើមាន ។

ពិភាក្សាពីពេលវេលានិងរបៀបដែលស្ត្រីអាចទាក់ទងអ្នកផ្តល់សេវាថែទាំសុខភាពបានក្រោយពេលសម្រាលកូន ជាពិសេសក្នុងករណីសង្គ្រោះបន្ទាន់។

ពិភាក្សាអំពីការពន្យារកំ ណើត គ្រប់មធ្យោបាយទាំងអស់រួមមានមធ្យោបាយពន្យារកំណើតទំនើបរយៈពេលវែង ដោយពិភាក្សាពីការផ្លាស់ប្តូរការផ្តល់សេវាទាំងនេះនៅក្នុងបរិបទការកាត់បន្ថយការជួបដោយផ្ទាល់ក្រោយសម្រាល។ ពិភាក្សាអំពីហានិភ័យនៃការបរាជ័យនៃមធ្យោបាយពន្យារកំ ណើតបែបបុរាណ។ ពិភាក្សាអំពីវិធីនិងកន្លែងដែលត្រូវទទួលមធ្យោបាយពន្យារកំណើតប្រសិនបើសេវាទាំងនេះបានផ្លាស់ប្តូរក្នុងអំឡុងពេលជំងឺកូវីដ-១៩និងផ្តល់ជម្រើសនៃមធ្យោបាយពន្យារកំណើតមុនពេលស្ត្រីចាកចេញពីមូលដ្ឋានសុខាភិបាលប្រសិនបើអាចឬផ្តល់ព័ត៌មានទាំងនេះក្នុងអំឡុងពេលផ្តល់សេវាថែទាំក្រោយសម្រាលដោយផ្ទាល់ជាមួយស្ត្រី។

សកម្មភាពសម្រាប់ផ្តល់ជូនស្ត្រីដែលត្រូវការសេវាថែទាំក្រោយសម្រាលពីចម្ងាយ ដោយមិនគិតពីបច្ចេកទេស ៖

- ការថែទាំផ្នែកសម្ភពប្រកបដោយការគោរព រួមមាន៖
  - ព្យាបាលស្ត្រីទាំងអស់ដោយសេចក្តីថ្លៃថ្នូរនិងការគោរព
  - ការរក្សាការសម្ងាត់និងភាពឯកជន
  - មិនមានភាពរើសអើង
  - គាំទ្រសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានព័ត៌មាននិងធ្វើការសម្រេចចិត្តដោយស្វ័យភាព
- សកម្មភាពគួរធ្វើនៅពេលផ្តល់សេវា ៖
  - ណែនាំខ្លួនអ្នកនិងសួរសុខទុក្ខស្ត្រីក្នុងលក្ខណៈរាក់ទាក់
  - ការវាយតម្លៃពីរោគសញ្ញានៃជំងឺកូវីដ-១៩ (ទាំងស្ត្រីនិងអ្នកពាក់ព័ន្ធ)ដោយយោងទៅតាមសេចក្តីណែនាំតាមប្រទេសនិងធ្វើការថែទាំប្រសិនបើរោគសញ្ញាត្រូវបានរកឃើញ
  - សាកសួរនិងយកចិត្តទុកដាក់លើសុខុមាលភាពរាងកាយ សង្គម អារម្មណ៍និងវប្បធម៌
  - សាកសួរអំពីសុខុមាលភាពរបស់ទារក អាហាររូបត្ថម្ភ ការលូតលាស់និងសកម្មភាព

- អនុវត្តការសង្កេតនិងវាយតម្លៃជាប្រចាំលើស្ត្រីនិងទារក
- ពន្យល់រាល់ការធ្វើតេស្តសំណាក របៀបនិងទទួលការយល់ព្រមពីស្ត្រី
- សាកសួរកត្តាប្រឈម កត្តាហានិភ័យ
- ពិភាក្សាពីសញ្ញានិងរោគសញ្ញានៃផលវិបាកក្រោយសម្រាល ៖
  - ធ្លាក់ឈាមក្រោយសម្រាល
  - បម្រុងក្រឡាភ្លើង ក្រឡាភ្លើង
  - ការក្លាយរោគ
  - រលាកសរសៃវ៉ែន (thromboembolism)
  - ការរលៀសដោះ
- ពិភាក្សាពីមធ្យោបាយពន្យារកំណើត
- ពិភាក្សាពីសញ្ញាគ្រោះថ្នាក់របស់ទារករួមមាន៖
  - មិនចង់បៅដោះ
  - ប្រកាច់
  - ចង្វាក់ដង្ហើមញាប់ ≥ ៦០ដង/នាទី
  - ដង្ហក់ខ្លាំង
  - មិនធ្វើចលនា
  - ក្តៅខ្លួន ≥៣៧.៥ អង្សា
  - សីតុណ្ហក្នុងខ្លួនទាប <៣៥.៥ អង្សា
  - ខាន់លឿងក្នុងអំឡុង២៤ម៉ោងដំបូងឬលឿងបាតដៃនិងបាតជើងនៅគ្រប់អាយុ
- ផ្តល់ពេលវេលាសមស្របសម្រាប់សំណួរ ចម្លើយ
- ផ្តល់ព័ត៌មាននិងការអប់រំទៅតាមតម្រូវការផ្សេងៗរបស់ស្ត្រី
- ផ្តល់ការពិគ្រោះពិភាក្សានិងធ្វើការបញ្ជូនទៅកន្លែងសមស្រប
- ពិភាក្សាពីផែនការសម្រាប់ការបញ្ជូនក្នុងករណីសង្គ្រោះបន្ទាន់ពីផ្ទះរបស់ស្ត្រីទៅមូលដ្ឋានសុខាភិបាល ប្រសិនបើចាំបាច់
- រៀបចំផែនការសម្រាប់ទទួលសេវាថែទាំក្រោយសម្រាលនិងការថែទាំបន្តបន្ទាប់
- កត់ត្រាទុករាល់ព័ត៌មានទាំងអស់ដូចជា ការប៉ាន់ប្រមាណ ការពិភាក្សានិងផែនការសម្រាប់ការថែទាំបន្ត។

**ការផ្តល់ការថែទាំក្រោយសម្រាលដោយផ្ទាល់ ៖**

- ការថែទាំក្រោយសម្រាលដោយផ្ទាល់ត្រូវអនុវត្តដោយគោរពតាមពិធីសារជាតិ

- បន្ថែមពីលើការថែទាំក្រោយសម្រាលលើកទី១នេះ ត្រូវផ្តល់ព័ត៌មានដល់ស្ត្រីស្តីពីការផ្តល់សេវាតាមទូរស័ព្ទនិងកាលវិភាគនៃការផ្តល់សេវាថែទាំក្រោយសម្រាលដោយទទួលការយល់ព្រមពីស្ត្រីសម្រាប់សេវាលើកក្រោយ
- បញ្ជាក់ឡើងវិញនូវលេខទូរស័ព្ទរបស់ស្ត្រីនិងលេខដែលអាចទាក់ទងបានផ្សេងទៀត
- ស្ត្រីត្រូវមានលេខទូរស័ព្ទរបស់អ្នកផ្តល់សេវាឬលេខដែលអាចទាក់ទងបានផ្សេងទៀតនៅមូលដ្ឋានសុខាភិបាល
- ធានាថាស្ត្រីមានថ្នាំជាតិដែក ហ្វូលីកអាស៊ីតនិងឱសថផ្សេងៗទៀត ដើម្បីចៀសវាងស្ត្រីមកទទួលម្តងទៀតនៅមូលដ្ឋានសុខាភិបាលដោយគ្រាន់តែមកយកឱសថតែមួយមុខ។

ការផ្តល់ការថែទាំក្រោយសម្រាលពីចម្ងាយ ៖

- ធ្វើការណែនាំខ្លួន និង សួរសុខទុក្ខស្ត្រីដោយរាក់ទាក់
- ផ្តល់ការថែទាំសម្តពដោយការគោរព
- សួរពីអារម្មណ៍របស់ស្ត្រី

❖ ការវាយតម្លៃចំពោះរោគសញ្ញាដែលអាចកើតមាននៃជំងឺកូវីដ-១៩ ទាំងស្ត្រី ទារកនិងអ្នកគាំទ្រ ព្រមទាំងបញ្ជូនទៅរកសេវាផ្សេងទៀតដើម្បីព្យាបាល ប្រសិនបើមានរោគសញ្ញា

- បញ្ជាក់ពីថ្ងៃសម្រាល ម៉ោងនិងប្រភេទនៃការសម្រាល
- សាកសួរពីចំនួនដងនៃការសម្រាលកូន
- សាកសួរពីបញ្ហាដែលកើតមានក្នុងអំឡុងពេលមានគភ៌ឬសម្រាល
- វាយតម្លៃរកការប្រឈមជាបន្ត

❖ វាយតម្លៃសុខភាពផ្លូវចិត្ត

- សាកសួរពីអារម្មណ៍ធូរស្រាលបន្ទាប់ពីការឈឺពោះសម្រាលនិងសម្រាល
- សាកសួរពីការទទួលទានដំណេក
- ពិភាក្សាពីការដេករបស់ទារក
- សាកសួរពីការព្រួយបារម្ភ
- ពិភាក្សាពីដំណោះស្រាយ
- សាកសួរពីការផ្លាស់ប្តូរអារម្មណ៍របស់ស្ត្រី
- ពិភាក្សាពីសញ្ញា រោគសញ្ញានៃការធ្លាក់ទឹកចិត្តក្រោយសម្រាលនិងបញ្ជូន
- វាយតម្លៃពីអំពើហិង្សាលើស្ត្រី
- សាកសួរពីសុវត្ថិភាពនៅផ្ទះ
- ផ្តល់ព័ត៌មានស្តីពីសេវានិងលេខទូរស័ព្ទដែលអាចទាក់ទងបាននៅពេលកើតមានអំពើហិង្សា
- សាកសួរពីអ្នកដែលអាចផ្តល់ការគាំទ្រឬជួយស្ត្រីបាន ប្រសិនបើត្រូវការជំនួយ
- ធ្វើការគាំទ្រផ្នែកអារម្មណ៍ រាងកាយនិងធ្វើផែនការសុវត្ថិភាព

❖ ការវាយតម្លៃសុខភាពផ្លូវកាយ

- សាកសួរពីរបបអាហារព្រមទាំងផ្តល់ដំបូន្មាន
- សាកសួរពីការប្រើថ្នាំជាតិដែក ថ្នាំទម្លាក់ព្រូន វីតាមីនបន្ថែមនិងឱសថដែលប្រើប្រចាំថ្ងៃ
- សាកសួរអំពី ការធ្លាក់ឈាម បរិមាណ ពណ៌ ក្លិន
- ពិភាក្សាអំពីការផ្លាស់ប្តូរសរីរៈសាស្ត្រធម្មតាក្រោយពេលសម្រាលកូននិងការធ្លាក់ឈាមកករឃ្លោក រហូតដល់ទៅ ៤-៦ សប្តាហ៍បន្ទាប់ពីសម្រាល
- ពិភាក្សាពីការព្យាបាលបន្ទាន់ សម្រាប់ការធ្លាក់ឈាមមិនធម្មតាក្រោយសម្រាល
- ពិភាក្សាពីការព្រួយបារម្ភនិងការបញ្ជូនបើចាំបាច់
- សាកសួរពីការបន្ទោរបង់លាមកនិងទឹកនោម
- សាកសួរស្នាមរហែកឬដេរទ្វារមាស
- សាកសួរពីការសម្អាតកន្លែងមានថ្នេរ
- សាកសួរពីការធ្វើចលនារាងកាយ
- សាកសួរពីសញ្ញាគ្រោះថ្នាក់ដូចជា ៖
  - ការធ្លាក់ឈាមតាមទ្វារមាស
  - ធ្លាក់ស មានក្លិន
  - ឈឺក្បាលខ្លាំង ស្រវាំងភ្នែក ក្តៅខ្លួន
  - អស់កម្លាំងខ្លាំង
  - ដកដង្ហើមញាប់ឬពិបាក
  - រោគសញ្ញាដូចជាជំងឺផ្តាសាយ
  - ឈឺឬក្រហមនៅដោះ
  - ឈឺឬហើមកំភួនជើង
- ប្រសិនបើមានការព្រួយបារម្ភ ត្រូវប្រឹក្សាយោបល់ជាមួយអ្នកផ្តល់សេវាឬបញ្ជូនស្ត្រី

❖ វាយតម្លៃពីការបំបៅទារក

- សាកសួរពីការបំបៅកូនដោយទឹកដោះម្តាយនិងពិភាក្សាពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយមួយមុខគត់
- សាកសួរពីសភាពដោះ ការគ្រប់គ្រងការលាសដោះនិងការច្របាច់យកទឹកដោះ

❖ វាយតម្លៃសភាពទារកទើបនឹងកើត

- សាកសួរពីសុខភាពរបស់ទារក
- ពិភាក្សាពីចលនារបស់ទារក
- សាកសួរពីសភាពនៃទងផ្ចិតរបស់ទារកនិងការថែទាំ

- ពិភាក្សាពីសារៈសំខាន់នៃការលាងដៃនិងអនាម័យទូទៅក្នុងការការពារការឆ្លងរោគចំពោះទារកទើបនឹងកើត
- សាកសួរពីសញ្ញាគ្រោះថ្នាក់របស់ទារកដូចជា ៖
  - ឈប់បៅដោះ
  - ការថយចុះចលនា
  - ប្រកាច់ សន្លឹម
  - ក្តៅពេកឬត្រជាក់ពេក
  - ដង្ហើមញាប់ជាងធម្មតាឬដង្ហក់ពេលដកដង្ហើម
  - រោគសញ្ញាខាន់លឿង
- ប្រសិនបើមានសញ្ញាគ្រោះថ្នាក់ត្រូវធ្វើការបញ្ជូន

❖ ការលើកកម្ពស់សុខភាពនិងការអប់រំ

- ការពន្យារកំណើត
- ពិភាក្សាពីមធ្យោបាយពន្យារកំណើតទំនើបនិងជម្រើសនៃមធ្យោបាយពន្យារកំ ណើត
- ពិភាក្សាអំពីការបន្តការរួមភេទប្រកបសុវត្ថិភាព
- ផ្តល់ព័ត៌មានអំពីអាហារូបត្ថម្ភ
- ធ្វើការណាត់ជួបបន្ត
- ផ្តល់ពេលវេលាសមស្របសម្រាប់សំណួរ ចម្លើយ។

# ការថែទាំកុមារនិងសេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩

## I. ការថែទាំកុមារ

**សកម្មភាពសម្រាប់ការថែទាំកុមារ ៖**

កុមារគ្រប់រូប គ្រប់វ័យនិងនៅគ្រប់ប្រទេសទាំងអស់បានរងផលប៉ះពាល់ ជាពិសេសផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនិងក្នុងករណីខ្លះដោយវិធានការកាត់បន្ថយការបង្កគ្រោះថ្នាក់ដោយចៃដន្យច្រើនជាងផលល្អ។ គ្រួសារជាច្រើនបានជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ចដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោកអាចដែលបណ្តាលឱ្យកុមារស្លាប់រាប់រយរាប់ពាន់នាក់បន្ថែមទៀតនៅក្នុងអំឡុងឆ្នាំ២០២០ ដែលផ្ទុយពីវឌ្ឍនភាពដែលបានសម្រេចកាលពី ២ ទៅ ៣ ឆ្នាំចុងក្រោយនៃការកាត់បន្ថយអត្រាមរណភាពទារក ។

ការគំរាមគំហែងដល់ការរស់រាននិងសុខភាពរបស់កុមារអាយុក្រោម៥ឆ្នាំដោយសារតែការរាំងស្ទះដល់ការបំពេញការងារជាប្រចាំ រួមមានសេវាចាំបាច់មួយចំនួនដូចជា ការលើកកម្ពស់សុខភាពអាហារូបត្ថម្ភ ការផ្តល់ថ្នាំបង្ការ ការព្យាបាលជំងឺទូទៅ ដូចជាជំងឺរលាកសួត ជំងឺរាក ជំងឺដែលអាចការពារបានដោយសារការផ្តល់វ៉ាក់សាំង ការគ្រប់គ្រងកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ កង្វះអាហារូបត្ថម្ភកម្រិតមធ្យម និងការព្យាបាលជំងឺរុំារ៉ៃក្នុងចំណោមកុមារដែលកំពុងរស់ជាមួយមេរោគអេដស៍។

សេវាថែទាំកុមារតូចគួរតែត្រូវបានពង្រឹងនិងផ្តល់ប្រឹក្សានិងសេវាសម្រាប់ការមើលថែប្រកបដោយការទទួលខុសត្រូវ ផ្តល់អាទិភាពដល់ឪពុកម្តាយគួបផ្សំនឹងការផ្តល់ចំណីអាហារនិងការការពារកុមារពីការរំលោភបំពាននិងអំពើហិង្សា។

កុមារប្រឈមនឹងការថប់បារម្ភក្នុងអំឡុងពេលដាក់ឱ្យនៅដាច់ដោយឡែកនិងការបិទបំរាមគោចរ ព្រមទាំងបានទទួលផលប៉ះពាល់អវិជ្ជមានដោយសារការរាតត្បាតជាសកលនៅលើគ្រួសាររបស់ពួកគេដែលនាំឱ្យមានហានិភ័យសម្រាប់សុវត្ថិភាពកុមារផងដែរ។ វិធានការទាំងឡាយដូចជាការបិទបំរាមគោចរ ការបិទជំរុំបានបង្កឱ្យមានហានិភ័យខ្ពស់ដល់កុមារឱ្យទទួលរងនូវអំពើហិង្សានិងការរំលោភបំពាន។ អំពើហិង្សាបែបនេះទំនងជាកើតមានច្រើននៅពេលដែលក្រុមគ្រួសារត្រូវបានបង្ខាំងឱ្យនៅតែក្នុងផ្ទះនិងជួបប្រទះភាពតានតឹងនិងការថប់បារម្ភយ៉ាងខ្លាំង។

ការប្រើលើសលុបរបស់កុមារនិងយុវវ័យនូវប្រព័ន្ធអ៊ិនធឺណេតសម្រាប់ការសិក្សាពីចម្ងាយនិងនាទីកម្សាន្តក៏បានបង្កើនហានិភ័យក្នុងការប៉ះពាល់នឹងគេហទំព័រដែលមិនសមរម្យនិងការបោកប្រាស់តាមអ៊ិនធឺណេត។

## ការថែទាំកុមារក្នុងពេលមានជំងឺរាតត្បាតជាសកល

ផ្តល់អាទិភាពដល់ការបន្តផ្តល់សេវាផ្តោតលើកុមារដោយផ្តោតលើសមធម៌នៃការទទួលបានសេវាជាពិសេសទាក់ទងនឹងការផ្តល់ថ្នាំបង្ការ សុខភាពមាតា ទារកទើបនឹងកើតនិងសុខភាពកុមារ អាហារូបត្ថម្ភ (បន្ថែមអាហារបំប៉ននិងអាហាររូបត្ថម្ភ) ការអភិវឌ្ឍកុមារតូចនិងកម្មវិធីការពារកុមារ ក៏ដូចជាការរៀននៅថ្នាក់មត្តេយ្យដោយ ៖

- ណែនាំអំពី ការផ្តល់ថ្នាំបង្ការនិងទីកន្លែង ដែលអាចទទួលបាន ។
- ផ្លាស់ប្តូរវិធីសាស្ត្រក្នុងការផ្តល់សេវាដែលកំពុងជួបប្រទះការខ្វះខាតដោយសារជំងឺកូវីដ-១៩ រាតត្បាត ។
- ពិចារណាផ្លាស់ប្តូរការផ្សព្វផ្សាយការអប់រំសុខភាពតាមផ្ទះសម្រាប់ការថែទាំកុមារនិងការអភិវឌ្ឍកុមារតូច ដោយការពិគ្រោះយោបល់តាមទូរស័ព្ទ។
- ការចុះសួរសុខទុក្ខតាមផ្ទះចំពោះកុមារឈឺគួរតែត្រូវបានផ្តល់អាទិភាពដោយមានវិធានការទប់ស្កាត់ការឆ្លងរោគឱ្យបានត្រឹមត្រូវ។
- ការគ្រប់គ្រងកុមារដែលមានជំងឺទូទៅនិងការអភិវឌ្ឍកុមារតូច ត្រូវតែបន្តតាមរយៈមូលដ្ឋានសុខាភិបាលកម្រិតទីមួយនិងការសួរសុខទុក្ខតាមផ្ទះដោយបុគ្គលិកសុខាភិបាលដែលបានបណ្តុះបណ្តាល។ ការរឹតបន្តឹងការទប់ស្កាត់ការឆ្លងរោគរួមមានការពាក់ម៉ាសនិងការអនុវត្តអនាម័យដៃត្រូវបានទាមទារនៅពេលមានទំនាក់ទំនងជាមួយកុមារ។
- ការបញ្ជូនទៅមូលដ្ឋានសុខាភិបាលកម្រិតខ្ពស់សម្រាប់កុមារដែលមានជំងឺធ្ងន់ធ្ងរនិងកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរជាមួយនឹងការបញ្ជូនដោយឥតគិតថ្លៃត្រូវតែបន្ត។ ការពិគ្រោះជំងឺ ការស្រាវជ្រាវនិងការរឹតបន្តឹងការទប់ស្កាត់ការឆ្លងរោគ រួមទាំងការពាក់ម៉ាស់ឱ្យបានត្រឹមត្រូវនិងការអនុវត្តអនាម័យដៃចាំបាច់ត្រូវធានានៅក្នុងមូលដ្ឋានសុខាភិបាល។
- អនុញ្ញាតឱ្យម្តាយឬសមាជិកគ្រួសារដែលមិនមានជំងឺកូវីដ-១៩ អាចស្នាក់នៅជាមួយកុមារដើម្បីផ្តល់ការគាំទ្រក្នុងអំឡុងពេលព្យាបាល។
- ធានាបាននូវភាពអាចរកបាននៃអុកស៊ីសែន (ម៉ាស៊ីនកំហាប់ អុកស៊ីសែនឬទាំងពីរ) រួមជាមួយប្រព័ន្ធចែកចាយអុកស៊ីសែននៅក្នុងបន្ទប់ព្យាបាលកុមារសម្រាប់ទាំងស្ថានភាពដែលកុមារមិនមានជំងឺកូវីដ-១៩ និងដើម្បីគ្រប់គ្រងភាពស្មុគស្មាញនៃជំងឺកូវីដ-១៩ ដែលទាក់ទងនិងបញ្ហាផ្លូវដង្ហើម។
- ការសម្អាតដោយការសម្លាប់មេរោគនៅលើផ្ទៃផ្សេងៗនៅតាមកន្លែងថែទាំកុមារជាមួយអ្នកជំងឺធម្មតាមិនខុសគ្នាពីអ្នកជំងឺដែលមានករណីសង្ស័យឆ្លងឬត្រូវបានគេអះអាងថាមានជំងឺកូវីដ-១៩ ដែលត្រូវការការព្យាបាល។
- ការពារកុមារពីអំពើហិង្សា ការរំលោភបំពានឬការគេងប្រវ័ញ្ចនិងចាត់ថ្នាក់សេវាការពារកុមារជាកត្តាសំខាន់។

- ការការពារជាក់លាក់សម្រាប់កុមារងាយរងគ្រោះរួមមានកុមារចំណាកស្រុក កុមារភៀសខ្លួន កុមារជនជាតិភាគតិច កុមាររស់នៅតំបន់អនាធិបតេយ្យ កុមាររស់នៅជាមួយពិការភាព កុមាររស់នៅទីក្រុងក្នុងតំបន់ប្រជុំជននិងកុមារនៅតាមស្ថាប័នផ្សេងៗ។
- ផ្តល់ការគាំទ្រជាក់ស្តែងដល់ឪពុកម្តាយនិងអ្នកមើលថែរួមទាំងវិធីនិយាយអំពីរោគរាតត្បាតជាសកលជាមួយកុមារពីវិធីគ្រប់គ្រងសុខភាពផ្លូវចិត្តផ្ទាល់ខ្លួនសុខភាពផ្លូវចិត្តរបស់កុមារនិងឧបករណ៍ដើម្បីជួយគាំទ្រដល់ការរៀនសូត្ររបស់កុមារ។

**ការថែទាំកុមារដែលមានរោគសញ្ញានៃការឆ្លងជំងឺកូវីដ-១៩ឬតេស្តវិជ្ជមាន**

- កុមារដែលមានរោគសញ្ញានៃការឆ្លងជំងឺកូវីដ-១៩ ចាំបាច់ត្រូវធ្វើការតាមដានអោយបានហ្មត់ចត់ទៅលើជំងឺទូទៅផ្សេងទៀតដែលអាចបង្ហាញនូវរោគសញ្ញាដូចគ្នា។
- មូលដ្ឋានសុខាភិបាលចាំបាច់ត្រូវមានកន្លែងឬបន្ទប់ដាច់ដោយឡែកសម្រាប់កុមារឈឺដែលមានការសង្ស័យពីការឆ្លងជំងឺកូវីដ-១៩និងកំពុងមានបញ្ហារួមផ្សេងៗទៀតដែលទាមទារឱ្យមានការមើលថែអ្នកជំងឺ។
- អនុញ្ញាតឱ្យម្តាយឬសមាជិកគ្រួសារស្នាក់នៅជាមួយកុមារដើម្បីផ្តល់ការគាំទ្រអំឡុងពេលព្យាបាល។
- កុមារដែលមានរោគសញ្ញានៃការឆ្លងជំងឺកូវីដ-១៩ គួរត្រូវដាក់នៅក្នុងបន្ទប់ដាច់ដោយឡែកដែលមានខ្យល់ចេញចូលល្អប្រសើរជាងមុន។
- ធានាបាននូវភាពអាចរកបាននៃអុកស៊ីសែន (ម៉ាស៊ីនកំហាប់ អុកស៊ីសែនឬទាំងពីរ) រួមជាមួយប្រព័ន្ធចែកចាយអុកស៊ីសែននៅក្នុងបន្ទប់ព្យាបាលកុមារសម្រាប់ទាំងស្ថានភាពដែលកុមារដែលមានជំងឺកូវីដ-១៩ ដើម្បីគ្រប់គ្រងភាពស្មុគស្មាញនៃជំងឺកូវីដ-១៩ ទាក់ទងនិងបញ្ហាផ្លូវដង្ហើម។
- រក្សាការបែងចែកបុគ្គលិកដាច់ដោយឡែក (វេជ្ជបណ្ឌិតនិងគិលានុបដ្ឋាយិកាក៏ដូចជាបុគ្គលិកគាំទ្រផ្សេងទៀត) ឱ្យធ្វើការនៅក្នុងបន្ទប់ដាច់ដោយឡែក សម្រាប់អ្នកដែលធ្វើការនៅផ្នែកថែទាំទារកទើបនឹងកើត។
- រៀបចំការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់នៃឧបករណ៍ការពារខ្លួន(PPE)និងបណ្តុះបណ្តាលបុគ្គលិកអំពីការប្រើឱ្យបានត្រឹមត្រូវ។
- ក្នុងករណីដែលមូលដ្ឋានសុខាភិបាលមិនមានលទ្ធភាពក្នុងការថែទាំ និងព្យាបាល ត្រូវបញ្ជូនកុមារដែលសង្ស័យឬមានជំងឺកូវីដ-១៩ ដោយអនុវត្ត តាមវិធានការរឹតបន្តឹងការទប់ស្កាត់ការឆ្លងរោគរួមទាំងនៅក្នុងរថយន្តសង្គ្រោះបន្ទាន់។ សម្រាប់ព័ត៌មានលម្អិតស្តីពីការគ្រប់គ្រងកុមារដែលមានតេស្តវិជ្ជមាននៃជំងឺកូវីដ-១៩ សូមយោងទៅលើឯកសាររបស់ក្រសួងសុខាភិបាល ។

**ការថែទាំយុវវ័យក្នុងអំឡុងពេលមានជំងឺកូវីដ-១៩រាតត្បាតជាសកល**

យុវវ័យអាចប្រឈមនឹងការឆ្លងមេរោគកូវីដ-១៩ដូចមនុស្សចាស់ដែរ។ ពួកគេត្រូវគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលទាក់ទងនឹង ការធ្វើតេស្តស្រាវជ្រាវរកមេរោគកូវីដ-១៩ ការទប់ស្កាត់ការរីករាលដាល ការព្យាបាលនិងការអនុវត្តគម្លាតសង្គម។

ការអប់រំដល់យុវវ័យនិងការប្រាស្រ័យទាក់ទងក្នុងសង្គមជាមួយនិងដៃគូរបស់ពួកគេព្រមទាំងជាមួយអ្នកអប់រំ មានឥទ្ធិពលក្នុងពេលកំពុងមានជំងឺរាតត្បាត។ ការពន្យារពេលក្នុងការផ្តាច់ទំនាក់ទំនង ការហាមឃាត់ ការរិតបន្តឹងការជួបជុំគ្នាណាមួយនឹងបង្កឱ្យមានការថប់បារម្ភនៅក្នុងគ្រួសារបង្កឱ្យមានការថប់បារម្ភនិងបាក់ទឹកចិត្ត។ នៅពេលដែលមានកត្តាជាច្រើនខាងលើនេះ ក្មេងស្រីដែលងាយរងគ្រោះអាចប្រឈមមុខនឹងការរួមភេទដោយបង្ខំឬមិនបានការពារដែលអាចនាំទៅរកការមានផ្ទៃពោះនៅវ័យក្មេង ការឆ្លងជំងឺកាមរោគនិងមេរោគអេដស៍។

ត្រូវផ្តល់ការការពារនិងគាំទ្រចិត្តសង្គមដល់យុវវ័យ ប្រសិនបើមានអាណាព្យាបាលឬអ្នកមើលថែទាំរបស់យុវវ័យ បានឆ្លងមេរោគកូវីដ-១៩ បានធ្វើចត្តាឡីស័ក ឬបានស្លាប់។ យុវវ័យមិនមានអារម្មណ៍ល្អទេនៅក្នុងអំឡុងពេលធ្វើចត្តាឡីស័កឬដាក់ខ្លួនឱ្យនៅដាច់ដោយឡែក ដូចនេះតម្រូវឱ្យមានការគាំទ្រពេញលេញពីសង្គម។ ឪពុកម្តាយនិងគ្រួសារត្រូវផ្តល់ការគាំទ្រផ្នែកសង្គម យន្តការសម្រាប់ការអប់រំនិងការទទួលសេវាសុខភាពសម្រាប់យុវវ័យ ជាពិសេសក្នុងករណីក្មេងស្រីដែលងាយរងគ្រោះ។ មនុស្សវ័យក្មេង ដែលងាយរងគ្រោះជាច្រើន ដូចជា អ្នកធ្វើចំណាកស្រុក ជនភៀសខ្លួន ជនដែលគ្មានទីជម្រក ជាពិសេសអ្នកនៅក្នុងមណ្ឌលឃុំឃាំងនិងអ្នកដែលកំពុងរស់នៅក្នុងតំបន់ប្រជុំជនឬតំបន់អនាធិបតេយ្យ ដែលរស់នៅក្នុងលក្ខខណ្ឌងាយរងគ្រោះនិងឆ្លងមេរោគកូវីដ-១៩។ ការទទួលបានការអប់រំ ព័ត៌មាន បច្ចេកវិទ្យាព្រមទាំងរបៀបនៃការការពារមេរោគកូវីដ-១៩ របស់ពួកគេនៅមានកម្រិត។

យុវវ័យគឺជាធនធានដ៏មានតម្លៃមួយហើយជាបណ្តាញការងារក្នុងអំឡុងពេលមានគ្រោះអាសន្ននិងវិបត្តិសុខភាពសាធារណៈ។ យុវវ័យអាចធ្វើការជាមួយមន្ត្រីសុខាភិបាលដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺឆ្លងព្រមទាំងគាំទ្រដល់សមាជិកសង្គមដែលត្រូវបានគេដាក់ឱ្យនៅដាច់ដោយឡែកពីគេ ជាពិសេសមនុស្សចាស់។ ពួកគេមានតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានត្រឹមត្រូវស្តីអំពីជំងឺកូវីដ-១៩និងគាំទ្រការចែករំលែកព័ត៌មានស្តីពីការកាត់បន្ថយហានិភ័យ ការប្រឹងប្រែងនៃការឆ្លើយតបនិងការត្រៀមទុកជាមុនពីថ្នាក់ជាតិ។ ទោះបីជាមានភាពមិនស្មើគ្នានៃបច្ចេកវិទ្យា យ៉ាងណាក៏ដោយ យុវវ័យនៅក្នុងជំនាន់នេះអាចទំនាក់ទំនងគ្នាបានច្រើនតាមរយៈបច្ចេកវិទ្យា ប្រព័ន្ធផ្សព្វផ្សាយនិងអ៊ិនធឺណេត។ នៅក្នុងពេលអនុវត្តគម្លាត សង្គមនិងការដាក់បំរាមគោចរ យុវវ័យដែលចេះប្រើប្រព័ន្ធបច្ចេកវិទ្យានឹងមានតួនាទីសំខាន់ក្នុងការធ្វើឱ្យប្រព័ន្ធទំនាក់ទំនងមានដំណើរការសម្រាប់ផ្តល់ព័ត៌មាននិងគាំទ្រទៅវិញទៅមកនៅក្នុងសហគមន៍ទាំងមូល។

នៅពេលដែលមានការពន្យារពេលនៃការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលលើបញ្ហាជំងឺកូវីដ-១៩ ចាំបាច់ត្រូវតែដោះស្រាយការរាំងស្ទះនៃការផ្តល់សេវាសុខភាពផ្លូវភេទនិងបន្តពូជនិងការផ្តល់ព័ត៌មានជា

ធម្មតាដល់យុវវ័យ។

តម្រូវការនៃសេវាសុខភាពផ្លូវចិត្តនិងការពិគ្រោះពិភាក្សាមានកម្រិតខ្ពស់នៅពេលដែលយុវវ័យកំពុងប្រឈមមុខនឹងការធុញថប់និងការតានតឹងអារម្មណ៍ដោយសារជំងឺកូវីដ-១៩។

- សកម្មភាពនៃការផ្តល់សេវាសុខភាពដល់យុវវ័យ
  - ស្វែងរកមធ្យោបាយថ្មីៗដើម្បីផ្តល់ព័ត៌មាននិងគាំទ្រដល់យុវវ័យដូចជាការអប់រំផ្លូវភេទ សុខភាព និងសេវាកម្មដទៃទៀតក្នុងអំឡុងពេលនៃការបិទសាលារៀន។ តម្រូវការរបស់យុវវ័យសម្រាប់ព័ត៌មានទាក់ទងនិងសុខភាពផ្លូវភេទ សុខភាពបន្តពូជនិងការអប់រំនៅតែចាំបាច់ក្នុងអំឡុងពេលមានជំងឺកូវីដ-១៩។ ដូចនេះតាមដែលអាចធ្វើទៅបាន ការអប់រំស្តីពីសុខភាពផ្លូវភេទគួរតែត្រូវផ្តល់ពីចម្ងាយដោយក្រសួងសុខាភិបាលដល់ពួកគេដើម្បីសិក្សានៅផ្ទះ។
  - ធានាឱ្យមានការផ្គត់ផ្គង់គ្រប់គ្រាន់នូវថ្នាំជាតិដែកនិងអាស៊ីតហ្វូលិក ថ្នាំទម្លាក់ព្រូន មធ្យោបាយពន្យារកំណើត រួមទាំងថ្នាំគ្រាប់ការពារកំណើតបន្ទាន់។
  - ធានាឱ្យមានសេវាសុខភាពសម្រាប់យុវវ័យតាមតម្រូវការនិងត្រូវគោរពតាមយ៉ាងតឹងរឹងនូវគោលការណ៍ណែនាំនៃការការបង្ការនិងការគ្រប់គ្រងការឆ្លងរោគ។
  - ពិចារណាបញ្ចូលការពិគ្រោះយោបល់តាមទូរស័ព្ទសម្រាប់សេវាផ្សេងៗជាពិសេសសេវាសុខភាពផ្លូវចិត្តនិងសុខុមាលភាពសម្រាប់យុវវ័យដែលមិនអាចទទួលបានសេវាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩។
  - ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺកូវីដ-១៩និងនៅពេលចុះសេវាមូលដ្ឋានត្រូវមានការចូលរួមពីយុវវ័យ។
  - គាំទ្រយុវវ័យតាមរយៈ ការលើកកម្ពស់ការយល់ដឹង ឥរិយាបថត្រឹមត្រូវក្នុងការថែរក្សាសុខភាព និងការការពារពួកគេពីមេរោគ ព្រមទាំងចែករំលែកព័ត៌មានត្រឹមត្រូវសម្រាប់ការពារខ្លួនពីការឆ្លងរោគតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។
  - ធានាយន្តការក្នុងការបង្ការ ការពារនិងកាត់បន្ថយផលវិបាកនៃអំពើហិង្សា ការមាក់ងាយ ការរើសអើងលើយុវវ័យក្នុងអំឡុងពេលចត្តាឡីស័កនិងដាក់ខ្លួនឱ្យដាច់ដោយឡែក។
  - លើកកម្ពស់ការប្រាស្រ័យទាក់ទងក្នុងការផ្លាស់ប្តូរសង្គមនិងឥរិយាបថ ដើម្បីជម្រុញការលាងដៃ ការរក្សាគម្លាតពីគ្នា ។

## II. សេវាពន្យារកំណើត

ចំណុចដែលត្រូវធ្វើដើម្បីធានាឱ្យមានការផ្តល់សេវាសេវាពន្យារកំណើត មានដូចជា ៖

- ដោះស្រាយបញ្ហាមានសារៈសំខាន់ទាក់ទងនឹងធនធានមនុស្សដែលបានទទួលវគ្គបណ្តុះបណ្តាល។ កង្វះខាតអ្នកផ្តល់សេវាថែទាំសុខភាពនៅក្នុងរោងចក្រនិងក្នុងប្រព័ន្ធសុខាភិបាលអាចកើតឡើងដោយសារគម្លាតសង្គមវិធានការដាក់ឱ្យនៅឆ្ងាយពីគ្នាឬការបង្ខាំងផ្ទែកខ្លះឬពេញ

លេញដែលរារាំងការធ្វើដំណើរទៅកន្លែងធ្វើការរបស់ពួកគេដែលត្រូវដោះស្រាយដោយអ្នកបង្កើតគោលនយោបាយ។

- លើកកម្ពស់ការចែកចាយមធ្យោបាយពន្យារកំ ណើតនៅតាមសហគមន៍ (មធ្យោបាយពន្យាររយៈពេលខ្លី ដូចជាថ្នាំគ្រាប់ពន្យារកំណើតនិងស្រោមអនាម័យ) តាមរយៈអ្នកស្ម័គ្រចិត្តសហគមន៍។
- ពិចារណាលើការបន្ធូរបន្ថយការរឹតបន្តឹងលើចំនួនថ្នាំពន្យារកំណើតដែលត្រូវផ្តល់ដល់អ្នកប្រើ ដើម្បីចៀសវាងការមកយកម្តងហើយម្តងទៀត។
- ពិចារណាលើការលើកកម្ពស់មធ្យោបាយពន្យារកំណើតរយៈពេលវែង ដូចជាមធ្យោបាយពន្យារកំ ណើតកងដាក់ក្រោមស្បែក កងដាក់ក្នុងស្បូនដែលមិនតម្រូវឱ្យមានការទទួលញឹកញាប់។
- ការដាក់កងក្នុងស្បូននិងការចោះចងដៃស្បូន អាចត្រូវបានផ្តល់ជូនដល់ស្ត្រីនៅពេលក្រោយសម្រាលកូនភ្លាម។ ទោះជាយ៉ាងណាក៏ដោយអ្នកផ្តល់សេវាថែទាំសុខភាព មិនត្រូវលើកទឹកចិត្តស្ត្រីមិនមែនក្រោយសម្រាលឱ្យជ្រើសរើសយកមធ្យោបាយអចិន្ត្រៃយ៍ ដូចជាការចោះចងដៃស្បូន ដើម្បីកាត់បន្ថយការទាក់ទងនិងបន្ទុកការងារនៅតាមមូលដ្ឋានសុខាភិបាលនៅពេលមានជំងឺកូវីដ-១៩រាតត្បាតជាសកល។ ការដកកងក្នុងស្បូនអាចត្រូវធ្វើប្រសិនបើចាំបាច់ដោយសារតែផលប៉ះពាល់ឬផលវិបាក។ ក្នុងករណីបែបនេះមធ្យោបាយពន្យារកំណើតទំនើបផ្សេងទៀតគួរតែត្រូវបានផ្តល់ជូនសម្រាប់ស្ត្រីក្នុងការជ្រើសរើស។

## ១. *ដំណោះស្រាយស្តីពីបញ្ហាប្រឈមនៃប្រព័ន្ធផ្គត់ផ្គង់ឱសថបរិក្ខារពេទ្យ*

- ក្រសួងសុខាភិបាលអាចពិចារណាពង្រឹងការសម្របសម្រួល រវាងទីភ្នាក់ងារអភិវឌ្ឍន៍នានានិងនាយកដ្ឋានផ្សេងៗដើម្បីកំណត់និងដោះស្រាយបញ្ហាផ្គត់ផ្គង់ និងការខ្វះចន្លោះដូចជាការរាំងស្ទះជាប្រព័ន្ធដើម្បីទទួលបានមធ្យោបាយពន្យារកំណើត។
- ជាការសំខាន់ណាស់សម្រាប់ក្រសួងសុខាភិបាលដែលត្រូវធ្វើការវាយតម្លៃស្ថានភាពនៃការផ្គត់ផ្គង់និងការអនុវត្តវិធានការនានាដើម្បីដោះស្រាយចំណុចខ្វះខាតដែលបានកយើញ។
- ការសម្របសម្រួលបានល្អប្រសើរហើយមានទិន្នន័យអំពីមធ្យោបាយពន្យារកំ ណើតនៅក្នុងស្តុក អាចជួយឱ្យក្រសួងសុខាភិបាលធ្វើការលើកកម្ពស់ក្នុងការចែករំលែកឬការផ្ទេរមធ្យោបាយពន្យារកំណើតពីតំបន់មួយទៅក្នុងតំបន់មួយទៀត ក្នុងករណីដែលតំបន់មួយមានលើសស្តុក និងតំបន់ផ្សេងទៀតកំពុងប្រឈមនឹងការដាច់ស្តុក ដូចនេះអាចកាត់បន្ថយការស្តុកទុកក៏ដូចជាការខ្ជះខ្ជាយដែលមិនចាំបាច់។
- មានមូលហេតុជាច្រើនដែលធ្វើឱ្យមានកង្វះមធ្យោបាយពន្យារកំណើត ដូចជាការថយចុះនៃការផលិត ការផ្គត់ផ្គង់វត្ថុធាតុដើម ជម្រើសនៃការដឹកជញ្ជូនទំនិញនិងខ្សែសង្វាក់ផ្គត់ផ្គង់របស់ពិភពលោកចុះខ្សោយ។

ខណៈពេលដែលរដ្ឋាភិបាលនានាអាចពិចារណាស្នើសុំឱ្យអ្នកផលិតបង្កើនការផលិតឱ្យបានជាអតិបរមា ពួកគេក៏អាចបញ្ជាអ្នកផ្គត់ផ្គង់របស់ពួកគេនិងអ្នកដទៃទៀតដើម្បីបង្កើនវត្ថុធាតុដើមឱ្យបានច្រើនបំផុត។ ការលើកកម្ពស់លទ្ធកម្មផលិតផលទូទៅក៏អាចត្រូវបានគេពិចារណាផងដែរសម្រាប់ការបង្កើនប្រសិទ្ធភាពចំណាយ។

- ក្រសួងសុខាភិបាលក៏អាចស្វែងរកលទ្ធភាពនៃភាពជាដៃគូជាមួយក្រសួង នាយកដ្ឋានដទៃទៀតដូចជា រុក្ខាប្រមាញ់ កសិកម្មនិងនេសាទ មហាផ្ទៃ...និងអ្នកដឹកជញ្ជូនឯកជនសម្រាប់ការដឹកជញ្ជូននិងចែកចាយមធ្យោបាយពន្យារកំនើតនិងឱសថបរិក្ខាផ្សេងៗ។

## ២. *ជំរុញភាពជាដៃគូជាមួយវិស័យឯកជន*

- វាមានសារៈសំខាន់ក្នុងការលើកកម្ពស់ភាពជាដៃគូឯកជននិងសាធារណៈ ជាពិសេសអ្នកផ្តល់សេវាថែទាំសុខភាពនៅតាមតំបន់ជនបទ ដើម្បីផ្តល់សេវាពន្យារកំណើតដល់អតិថិជនរបស់ពួកគេ នៅកន្លែងដែលប្រព័ន្ធសុខាភិបាលមានកម្រិតឬខ្វះបុគ្គលិក។
- ស្វែររកការគាំទ្រ ពីអង្គការក្រៅរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលសម្រាប់ការគាំទ្រវិធានការដាក់ឱ្យឆ្ងាយពីគ្នា និងដើម្បីលុបចោលនូវការយល់ខុសនិងព័ត៌មានមិនពិតប្រឆាំងនឹងការពន្យារកំណើតក៏ដូចជាសម្រាប់លើកកម្ពស់ការចែកចាយមធ្យោបាយពន្យារកំណើត។
- បង្កើតប្រព័ន្ធទំនាក់ទំនងដើម្បីផ្តល់ព័ត៌មានអំពីទីកន្លែងដែលអតិថិជនអាចទទួលបាន មធ្យោបាយពន្យារកំ ណើតរួមទាំងថ្នាំគ្រាប់ការពារកំណើតបន្ទាន់និងសេវាការរំលូតកូនប្រកបដោយសុវត្ថិភាព។ ប្រព័ន្ធទំនាក់ទំនងបែបនេះក៏អាចត្រូវបានប្រើសម្រាប់គោលបំណងផ្តល់ការពិគ្រោះពិភាក្សាដើម្បីផ្តល់ព័ត៌មានដល់អតិថិជននិងអាចបំពេញបន្ថែមជាវេទិកាពិគ្រោះយោបល់តាមអ៊ិនធឺណេតដោយមានការចូលរួមពីវិស័យឯកជនឬអង្គការក្រៅរដ្ឋាភិបាល។
- ប្រសិនជាអាចធ្វើទៅបានត្រូវធ្វើការជាដៃគូជាមួយភ្នាក់ងារទំនាក់ទំនងព័ត៌មានវិទ្យាដើម្បីលើកកម្ពស់ការផ្តល់វេជ្ជបញ្ជាតាមប្រព័ន្ធព័ត៌មានវិទ្យា (telemedicine) និងសម្រាប់បង្កើតកម្មវិធីប្រើតាមទូរស័ព្ទដោយឥតគិតថ្លៃដែលកំពុងពេញនិយមក្នុងចំណោមយុវវ័យនិងគូស្វាមីភរិយាពីការផ្តល់ព័ត៌មានអំពីមធ្យោបាយពន្យារកំណើតនិងទីកន្លែងដែលអាចរកបាន។

## ៣. *អនុសាសន៍ផ្សេងទៀត*

- គ្រប់មធ្យោបាយពន្យាកំណើតទំនើបសុទ្ធតែមានសុវត្ថិភាពក្នុងការប្រើក្នុងអំឡុងពេលមានជំងឺកូវីដ-១៩។ អ្នកម្តាយក៏អាចទទួលបានការអប់រំអំពីមធ្យោបាយពន្យារកំ ណើតតាមបែបធម្មជាតិដែលមានសុវត្ថិភាពរួមទាំងការបំបៅដោះកូនដោយទឹកដោះម្តាយផងដែរ។

- ពិចារណាពីមធ្យោបាយពន្យារកំណើត ដែលអាចរកបានដោយមិនចាំបាច់មានវេជ្ជបញ្ជា ដូចជា ស្រោមអនាម័យ ថ្នាំគ្រាប់ពន្យារកំណើតនៅតាមឱសថស្ថាន។
- អនុវត្តការចេញវេជ្ជបញ្ជាតាមរយៈទូរស័ព្ទដៃនិងប្រព័ន្ធផ្សព្វផ្សាយសង្គម (Telemedicine) បន្ថែម ដើម្បីផ្តល់ព័ត៌មានពីសេវានិងទីកន្លែងទទួលមធ្យោបាយពន្យារកំណើត។ ជំរុញការប្រើកម្មវិធីទូរស័ព្ទដោយបុគ្គលិកសុខាភិបាលស្តីពីលក្ខខណ្ឌក្នុងផ្តល់មធ្យោបាយពន្យារកំណើតតាមបែបវេជ្ជសាស្ត្រនិងការថែទាំក្រោយសម្រាល។
- ក្នុងអំឡុងពេលនៃការស្នាក់នៅក្នុងផ្ទះ: គួរពង្រីកសេវាពន្យារកំណើតក្រោយសម្រាល ជាពិសេសមធ្យោបាយពន្យារកំណើតរយៈពេលវែងដូចជា កងដាក់ក្នុងស្បូន កងដាក់ក្រោមស្បែក កងដាក់ក្នុងស្បូនក្រោយសម្រាលភ្លាមនិងថ្នាំចាក់។
- សម្របសម្រួលសេវាពន្យារកំណើតជាមួយសេវាដ៏ទៃផ្សេងទៀត ដើម្បីពង្រឹងនិងដាក់បញ្ចូលគ្នា ដើម្បីឱ្យស្ត្រីអាចទទួលបាននូវសេវានានាដែលចាំបាច់រាល់ការណាត់ជួបនីមួយៗ ។

## III. ការរំលូតកូនប្រកបដោយសុវត្ថិភាព

ការផ្តល់សេវារំលូត ប្រកបដោយសុវត្ថិភាព ជាសេវាថែទាំសំខាន់មួយដែលត្រូវរក្សាទុកនិងផ្តល់ទាន់ពេលវេលា ទោះបីជាក្នុងកាលៈទេសៈដែលមានការរាតត្បាតដោយជំងឺកូវីដ-១៩ក៏ដោយ។ ការពន្យារពេលក្នុងការផ្តល់សេវារំលូតអាចប្រឈមនឹងផលវិបាកកាន់តែច្រើន ហើយអាចប៉ះពាល់សុខភាពនិងសុខុមាលភាពរបស់ស្ត្រីកាន់តែខ្លាំង ព្រមទាំងធ្វើឱ្យបុគ្គលិកសុខាភិបាលប្រឈមទៅនឹងហានិភ័យបន្ថែមទៀតផងដែរ។ ការថែទាំក្រោយរំលូតរួមទាំងការទទួលបាននូវមធ្យោបាយពន្យារកំ ណើត គួរតែទទួលបានតាមតម្រូវការរបស់ស្ត្រី ព្រោះជាសេវាសង្គ្រោះជីវិតស្ត្រី។

## IV. អំពើហិង្សាលើស្ត្រីនៅក្នុងអំឡុងពេលមានជំងឺកូវីដ-១៩រាតត្បាតជាសកល

អំ ពើហិង្សាលើក្មេងស្រីនិងស្ត្រីនៅតែជាបញ្ហាសុខភាពសាធារណៈដ៏ធំមួយនិងជាការគំរាមកំហែងដល់សុខភាពរបស់ស្ត្រីក្នុងពេលមានអាសន្ន។ វិស័យសុខាភិបាលនិងបុគ្គលម្នាក់ៗអាចធ្វើបានច្រើនក្នុងពេលបង្ការនិងដោះស្រាយអំពើហិង្សាលើស្ត្រីក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩ រាតត្បាតជាសកល។ ផលប៉ះពាល់សុខភាពនៃអំពើហិង្សា ជាពិសេសអំពើហិង្សាពីដៃគូស្និទ្ធស្នាល អំពើហិង្សាក្នុងគ្រួសារចំពោះស្ត្រីនិងកូនៗគឺជាកត្តាសំខាន់។ អំ ពីហិង្សាលើស្ត្រីអាចបណ្តាលឱ្យមានរបួសនិងបញ្ហាសុខភាពរាងកាយ ផ្លូវចិត្ត ផ្លូវភេទនិងសុខភាពបន្តពូជធ្ងន់ធ្ងរ រួមទាំងការឆ្លងជំងឺកាមរោគ មេរោគអេដស៍និងការមានផ្ទៃពោះដែលមិនបានគ្រោងទុក។

ក្នុងពេលមានវិបត្តិនៃការផ្ទុះឡើងនៃមេរោគនេះ ស្ត្រីនិងក្មេងស្រីអាចមានហានិភ័យខ្ពស់ពីអំពើហិង្សាដោយដៃគូស្និទ្ធស្នាលនិងទម្រង់ដទៃទៀតនៃអំពើហិង្សាក្នុងគ្រួសារ ដោយសារតែភាពតានតឹងកើនឡើងនៅក្នុងគ្រួសារ។ យុវវ័យ ជាពិសេសក្មេងស្រីនិងស្ត្រីវ័យជំទង់ដែលមានទំនោរប្រឈមមុខកម្រិតខ្ពស់រួចទៅហើយពីអំពើហិង្សាក្នុងគ្រួសារនិងពីដៃគូស្និទ្ធស្នាលអាចកើនឡើងដែលបណ្តាលមកពីការធ្វើចត្តាឡីស័កនិងការដាក់ឱ្យនៅដាច់ដោយឡែក។

អ្នកគ្រប់គ្រងសេវាសុខាភិបាលត្រូវធានាថា បុគ្គលិកសុខាភិបាលមានជំនាញចាំបាច់និងធនធានដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រីដែលដំណោះស្រាយនេះត្រូវបានផ្តល់ដោយការគោរពនិងរក្សាការសម្ងាត់ ហើយសេវាទាំងនោះត្រូវផ្តល់តាមវិធីសាស្ត្រសង្គ្រោះឱ្យរស់រានមានជីវិត (Survivor-Centered Approach)។

ក្នុងអំឡុងពេលឆ្លងរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ការផ្លាស់ប្តូរណាមួយនៅក្នុងការបញ្ជូនបន្តករណីមានអំពើហិង្សាលើស្ត្រីទៅមូលដ្ឋានសុខាភិបាល ត្រូវតែធ្វើបច្ចុប្បន្នភាពទៅដល់សហគមន៍សំខាន់ៗ ហើយអ្នកផ្តល់សេវាត្រូវជូនដំណឹងអំពីបញ្ហានេះ។ ឧបសគ្គនិងបញ្ហាណាមួយ ដែលកើតឡើងពីការការពារស្ត្រីនិងក្មេងស្រីពីការទទួលបានសេវាត្រូវតែបានដោះស្រាយ រួមទាំងការគាំទ្រផ្នែកផ្លូវចិត្តជាពិសេសសម្រាប់អ្នកដែលទទួលរងអំពើហិង្សាឬអ្នកដែលអាចមានហានិភ័យនៃអំពើហិង្សា។ ពិចារណាពីការផ្តល់ឧបករណ៍ជំនួយតាមរយៈទូរស័ព្ទឥតគិតថ្លៃក្នុងអំឡុងពេលស្នាក់នៅក្នុងផ្ទះ។

## ១.ប្រព័ន្ធសុខាភិបាលមានតួនាទីដ៏សំខាន់មួយដើម្បីធានាថាស្ត្រីដែលរងគ្រោះដោយអំពើហិង្សា នៅតែអាចទទួលបានសេវាក្នុងអំឡុងពេលនៃការផ្ទុះនៃជំងឺកូវីដ-១៩

ទោះបីជំងឺកូវីដ-១៩បានប៉ះពាល់យ៉ាងខ្លាំងលើប្រព័ន្ធសុខាភិបាលនិងបុគ្គលិកសុខាភិបាល ក៏ដោយក៏ប្រព័ន្ធសុខាភិបាលនៅតែអាចជួយកាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រីនិងកុមារក្នុងអំឡុងពេលនេះតាមរយៈ៖

- ភាគីពាក់ព័ន្ធទាំងអស់ដែលចូលរួមក្នុងការឆ្លើយតបនៃជំងឺកូវីដ-១៩ចាំបាច់ត្រូវលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ពីអំពើហិង្សាដល់ស្ត្រីនិងកូនៗដោយសារការអនុវត្តវិធានការគម្លាតសង្គម ការស្នាក់នៅផ្ទះនិងបញ្ហាផ្សេងៗទៀតដែលកើតមានឡើងក្នុងអំឡុងពេលមានរោគរាតត្បាតនេះ។
- បុគ្គលិកសុខាភិបាលដែលភាគច្រើនជាស្ត្រី អាចប្រឈមនឹងអំពើហិង្សានៅក្នុងផ្ទះឬកន្លែងធ្វើការ បញ្ហានេះអាចកាន់តែធ្ងន់ធ្ងរនៅពេលប្រព័ន្ធសុខាភិបាលមានបញ្ហា។ អ្នកគ្រប់គ្រងមូលដ្ឋានសុខាភិបាល ត្រូវមានផែនការដោះស្រាយសុវត្ថិភាពរបស់បុគ្គលិកសុខាភិបាល។ អ្នកផ្តល់សេវាជួរមុខដែលទាក់ទងជាមួយជំងឺកូវីដ-១៩អាចនឹងជួបប្រទះការរើសអើង ភាពឯកោនិងមិនទទួលបានសិទ្ធិដូចគេ។ ក្រសួងសុខាភិបាលគួរផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រ

ការលើកទឹកចិត្ត ការឧបត្ថម្ភថវិកា ការធ្វើដំណើរនិងការគាំទ្រការថែទាំកូនៗរបស់បុគ្គលិកសុខាភិបាល។

## ២. *ការឆ្លើយតបអំពើហិង្សាលើស្ត្រីក្នុងកំឡុងពេលមានជំងឺកូវីដ-១៩*

សកម្មភាពដែលអាចជួយកាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រីនិងកុមារសម្រាប់ប្រព័ន្ធសុខាភិបាលរួមទាំងអ្នកផ្តល់សេវាជួរមុខក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ៖

**ក្រសួងសុខាភិបាលនិងអ្នកធ្វើគោលនយោបាយ**

ត្រូវរួមបញ្ចូលសេវាចាំបាច់នានាសម្រាប់ដោះស្រាយអំពើហិង្សាលើស្ត្រីនិងត្រៀមធ្វើផែនការឆ្លើយតបអំពើហិង្សាក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ផ្តល់ធនធានដល់ពួកគេនិងរកមធ្យោបាយដើម្បីឱ្យពួកគេទទួលបានសេវាទាំងនេះ ក្នុងកាលៈទេសៈនៃការអនុវត្តវិធានការគម្លាតសង្គម។ មូលដ្ឋានសុខាភិបាល គួរតែបង្ហាញនិងផ្តល់ព័ត៌មានអំពីសេវាដែលមាន ដូចជាទូរស័ព្ទទាន់ហេតុការណ៍ មណ្ឌលសម្រាប់អ្នកមានវិបត្តិ ជំរក ជំនួយផ្នែកច្បាប់ សម្រាប់ជនរងគ្រោះ រួមមានម៉ោងបំរើការងារ ព័ត៌មានលំអិតទំនាក់ទំនង សេវាដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយនិងរៀបចំការបញ្ជូន។

**អ្នកផ្តល់សេវាសុខាភិបាល**

ចាំបាច់ត្រូវដឹងអំពីហានិភ័យនិងផលវិបាកសុខភាពដែលបង្កឡើងដោយអំពើហិង្សាលើស្ត្រី។ ពួកគេអាចជួយស្ត្រីដែលមកទទួលសេវា ដោយផ្តល់ការគាំទ្រដំបូងនិង ផ្តល់ការព្យាបាល ការគាំទ្រទាំងនេះរួមមាន ៖ ការស្តាប់ដោយយកចិត្តទុកដាក់និងដោយគ្មានការវិនិច្ឆ័យ ការសាកសួរអំពីតម្រូវការនិងការព្រួយបារម្ភ ពង្រឹងសុវត្ថិភាព កត់ត្រានូវបទពិសោធន៍និងអារម្មណ៍របស់ស្ត្រីនិងភ្ជាប់ជនរងគ្រោះទៅរកសេវាគាំទ្រផ្សេងទៀត។គួរសាកល្បងការប្រើវិធីសាស្ត្រនៃការផ្តល់ព័ត៌មានសុខាភិបាលនិងវេជ្ជសាស្ត្រតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីជួយដល់ស្ត្រីដែលទទួលរងគ្រោះដោយអំពើហិង្សា។

**អង្គការមនុស្សធម៌**ចាំបាច់ត្រូវបញ្ចូលសេវាសម្រាប់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សានិងកូនៗរបស់ពួកគេតាមរយៈការធ្វើផែនការឆ្លើយតបនិងប្រមូលទិន្នន័យស្តីពីករណីអំពើហិង្សាលើស្ត្រីក្នុងអំឡុងពេលមានជំងឺកូវីដ-១៩។

**សមាជិកសហគមន៍**គួរតែត្រូវបានគេដឹងអំពីការកើនឡើងហានិភ័យនៃអំពើហិង្សាលើស្ត្រីក្នុងអំឡុងពេលមានជំងឺរាតត្បាតជាសកលនេះនិងតម្រូវការក្នុងការទាក់ទងនិងគាំទ្រដល់ស្ត្រីដែលទទួលរងគ្រោះដោយអំពើហិង្សានិងព័ត៌មានអំពីជម្រកសុវត្ថិភាពដែលអាចជួយដល់ពួកគាត់បាន។ ជាការសំខាន់ដើម្បីធានាថាវាមានសុវត្ថិភាពក្នុងការទំនាក់ទំនងជាមួយស្ត្រីនៅពេលដែលអ្នករំលោភបំពានមានវត្តមាននៅក្នុងផ្ទះ។

**ស្ត្រីដែលជួបប្រទះនឹងអំពើហិង្សា**អាចយល់ថាមានប្រយោជន៍ក្នុងការទំនាក់ទំនងជាមួយក្រុមគ្រួសារនិងមិត្តភក្តិ ស្វែងរកការគាំទ្រតាមរយៈបណ្តាញទូរស័ព្ទបន្ទាន់ឬស្វែងរកសេវាក្នុងសហគមន៍

សម្រាប់ជនរងគ្រោះ។ ពួកគេត្រូវតែមានផែនការសុវត្ថិភាពក្នុងករណីអំពើហិង្សាកើនឡើង រួមបញ្ចូលទាំងអ្នកជិតខាង មិត្តភក្តិ សាច់ញាតិឬទីជម្រកដែលត្រូវទៅក្នុងករណីដែលពួកគេត្រូវការចាកចេញពីផ្ទះភ្លាមៗដើម្បីសុវត្ថិភាព។

## *៣. សកម្មភាពនៃការផ្តល់សេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជនិងយេនឌ័រ*

- ធានាថាស្ត្រីនិងយុវវ័យមានជម្រើសនិងសិទ្ធិក្នុងការប្រើសេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជដោយមិនគិតពីស្ថានភាពនៃជំងឺកូវីដ-១៩រួមទាំងលទ្ធភាពក្នុងការទទួលបានសេវាពន្យារកំណើតសេវាជំងឺកាមរោគនិងមេរោគអេដស៍និងសេវាថែទាំការរំលូតកូនប្រកបដោយសុវត្ថិភាព
- ធានាឱ្យមាននិរន្តរភាពសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ក៏ដូចជាការគាំទ្រផ្នែកសុខភាពផ្លូវចិត្តនិងចិត្តសាស្ត្រផ្នែកសង្គម។
- ផ្តល់ការគាំទ្រនិងសារសមស្របក្នុងគោលបំណងដើម្បីលើកកម្ពស់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ប្រជាជន។
- ធានាថាការឆ្លើយតបមិនបង្កឱ្យមានអំពើហិង្សា ការរើសអើងនិងវិសមភាព។
- ករណីប្រព័ន្ធការពារស្ត្រីនិងក្មេងស្រីមានភាពទន់ខ្សោយឬខូចខាត ដូចនេះវិធានការទាំងឡាយគួរបានអនុវត្តដើម្បីការពារស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាបង្កឡើងដោយដៃគូ
- ផ្តល់អាទិភាពដល់ការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត រៀបចំផែនការអន្តរាគមន៍ ការឃ្លាំមើលសុវត្ថិភាព ការកំណត់អត្តសញ្ញាណនិងយន្តការនៃការបង្ការ។
- គាំទ្រដល់ការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីនិងក្មេងស្រីនៅសហគមន៍ដើម្បីធានាថាការខិតខំនិងការឆ្លើយតបមិនមានការរើសអើងបន្ថែមទៀតទៅដល់អ្នកដែលមានហានិភ័យបំផុត។
- បញ្ចូលការវិភាគយេនឌ័រទៅក្នុងការរៀបចំទុកជាមុននិងការឆ្លើយតប ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃសេវាសុខាភិបាលនិងលើកកម្ពស់សមភាពយេនឌ័រ និងសមធម៌សុខាភិបាល។
- ផ្តល់អាទិភាពដល់ការប្រមូលទិន្នន័យដែលត្រឹមត្រូវនិងពេញលេញដោយបែងចែកតាមអាយុ និងភេទដើម្បីស្វែងយល់ពីផលប៉ះពាល់ដល់បុគ្គលខុសៗគ្នាដោយសារជំងឺកូវីដ-១៩ ដូចជាឧប្បត្តិហេតុ គំរូ និន្នាការ ជាដើម។ល។

## V. ការថែទាំអ្នកផ្ទុកមេរោគអេដស៍

ការបន្តទទួលបានសេវាបង្ការនិងព្យាបាលមេរោគអេដស៍មានសារៈសំខាន់ណាស់ដូចជាការធ្វើតេស្តនិងព្យាបាល ការវាយតម្លៃពីការបង្ខាំងដែលបានអនុវត្តក្នុងការឆ្លើយតបសុខភាពសាធារណៈទៅនឹងការរីករាលដាលជំងឺកូវីដ-១៩ក៏មានសារៈសំខាន់ផងដែរ។

យុវវ័យដែលមានផ្ទុកមេរោគអេដស៍មានហានិភ័យខ្ពស់ដោយសារប្រព័ន្ធភាពស៊ាំខ្សោយនិងការប្រើថ្នាំប្រឆាំងនឹងមេរោគអេដស៍ជាប្រចាំដែលមិនត្រូវបានផ្តល់ជាអាទិភាពក្នុងកំឡុងពេលមានជំងឺរាតត្បាត។

សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ត្រូវបានបញ្ចូលជាមួយសេវាពន្យារកំណើតដោយផ្តល់មធ្យោបាយពន្យារកំណើតនិងថ្នាំប្រឆាំងមេរោគអេដស៍រួមគ្នា ដើម្បីចៀសវាងការទៅកាន់មូលដ្ឋានសុខាភិបាលញឹកញាប់។

### សេវាថែទាំអ្នកផ្ទុកមេរោគអេដស៍ក្នុងអំឡុងពេលមានជំងឺរាតត្បាតជាសកល

- ពិចារណាលើជម្រើសសម្រាប់ពេលវេលានិងទីតាំងនៃការធ្វើតេស្តរកមេរោគអេដស៍ដែលជាការកាត់បន្ថយការប៉ះពាល់នៃការឆ្លងជំងឺកូវីដ-១៩ ដូចជាការរៀបចំសហគមន៍ ការណាត់ជួប។ កុមារដែលមានផ្ទុកមេរោគអេដស៍គួរតែបន្តទទួលការធ្វើតេស្តរករោគវិនិច្ឆ័យនិងការធ្វើរោគវិនិច្ឆ័យឱ្យបានឆាប់។
- អនុវត្តការប្រុងប្រយ័ត្នជាស្តង់ដារសម្រាប់អ្នកជំងឺទាំងអស់តាមការណែនាំរបស់ក្រសួងសុខាភិបាល។
- ធានាឱ្យបាននូវការពិគ្រោះជំងឺការរកឃើញឱ្យបានឆាប់នូវការឆ្លងរោគនិងការគ្រប់គ្រងប្រភពឆ្លងព្រមទាំងដាក់អ្នកជំងឺដែលមានការសង្ស័យពីការឆ្លងជំងឺកូវីដ-១៩ឱ្យនៅដាច់ដោយឡែក ។
- ពង្រីកការគាំទ្រដល់ម្តាយតាមរយៈទូរស័ព្ទ សារដើម្បីសម្របសម្រួលដល់ការផ្តល់ ថ្នាំពន្យារជីវិតសម្រាប់កុមារដោយមានការណែនាំអំពីកម្រិតថ្នាំដល់ម្តាយដែលមិនអាចវិលត្រឡប់មកវិញដោយសារជំងឺកូវីដ-១៩ ឬផ្តល់កញ្ចប់ថ្នាំសម្រាប់ម្តាយនិងកុមាររួមគ្នានិងធ្វើការតាមដានតាមទូរស័ព្ទ។
- សេវានានាត្រូវរួមបញ្ចូលជាមួយការផ្គត់ផ្គង់ថ្នាំប្រឆាំងមេរោគអេដស៍រយៈពេល ៦ខែ ដល់កុមារនិងយុវវ័យដែលផ្ទុកមេរោគអេដស៍ សម្រាប់អ្នកដែលមានទម្ងន់ចាប់ពី២០ គីឡូក្រាមឡើងទៅ
- ធានាឱ្យមានការទទួលបានការចែកចាយថ្នាំប្រឆាំងមេរោគអេដស៍ច្រើនខែ ការព្យាបាលជំងឺរបេង ជំងឺលើសឈាមនិងជំងឺទឹកនោមផ្អែមយ៉ាងហោចណាស់ ៣ខែជាពិសេសរយៈពេល ៦ខែដល់ស្ត្រីមានផ្ទៃពោះនិងបំបៅកូនដោយទឹកដោះម្តាយដែលមានផ្ទុកមេរោគអេដស៍។

# សុខភាពនិងសុវត្ថិភាពរបស់បុគ្គលិកសុខាភិបាល

សុខភាពនិងសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកនិងគ្រួសាររបស់អ្នកមានសារៈសំខាន់ណាស់។ មុនពេលចាកចេញពីមូលដ្ឋានសុខាភិបាលឬមុនពេលចូលផ្ទះត្រូវលាងដៃនិងប្តូរសម្លៀកបំពាក់ហើយបោកគក់ជាមួយសាប៊ូនិងទឹក។

## ៨- ការគ្រប់គ្រង និងការវាយតម្លៃពីហានិភ័យរបស់បុគ្គលិកថែទាំសុខភាព

- បុគ្គលិកថែទាំសុខភាពដែលផ្តល់ការថែទាំដោយផ្ទាល់ដល់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ត្រូវតាមដានអាការៈរោគសញ្ញាដោយខ្លួនឯង (ឧទាហរណ៍ គ្រុនក្តៅ ក្អក ហៀរសំបោរ ដង្ហើមខ្លី) និងធ្វើការវាយតម្លៃពីហានិភ័យ ប្រសិនបើគាត់មានទាក់ទងនិងការប្រឈមនឹងវីរុស។
- មូលដ្ឋានសុខាភិបាលអាចប្រើឧបករណ៍វាយតម្លៃពីហានិភ័យទាក់ទងនឹងជំងឺកូវីដ-១៩របស់អង្គការសុខភាពពិភពលោក សម្រាប់បុគ្គលិកថែទាំសុខភាព ដើម្បីវាយតម្លៃកម្រិតហានិភ័យ។

ប្រសិនបើបុគ្គលិកថែទាំសុខភាពត្រូវបានចាត់ទុកថាមានការប្រឈមហានិភ័យខ្ពស់៖

| សកម្មភាពដែលបុគ្គលិកសុខាភិបាលត្រូវធ្វើ | សកម្មភាពដែលមូលដ្ឋានសុខាភិបាលត្រូវធ្វើ |
|---|---|
| • បញ្ឈប់រាល់សកម្មភាពទាក់ទងជាមួយអ្នកជំងឺក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩<br>• ធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅក្នុងកន្លែងដែលបានរៀបចំទុក<br>• ត្រូវធ្វើតេស្តវីរុសកូវីដ-១៩ | • ផ្តល់ការបណ្តុះបណ្តាលឡើងវិញពីការបង្ការ និងទប់ស្កាត់ការចម្លងរោគសម្រាប់បុគ្គលិកក្នុងមូលដ្ឋានសុខាភិបាល រួមមានស្តង់ដា និងការប្រុងប្រយ័ត្នដាក់ដាច់ដោយឡែក និងការប្រើប្រាស់ឧបករណ៍ការពារខ្លួនឲ្យបានត្រឹមត្រូវ។<br>• ផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គមដល់បុគ្គលិកសុខាភិបាល ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ឬអំឡុងពេលឈឺ ប្រសិនបើគាត់ក្លាយជាអ្នកជំងឺកូវីដ-១៩។<br>• ផ្តល់ការទូទាត់ជូនបុគ្គលិកសុខាភិបាលសម្រាប់រយៈពេលធ្វើចត្តាឡីស័ក ឬ ឈឺ (ប្រសិនបើមិនមានក្នុងប្រាក់បៀវត្សប្រចាំខែ) ឬបន្តកិច្ចសន្យាសម្រាប់រយៈពេលធ្វើចត្តាឡីស័ក ឬមានជំងឺ។ |

ប្រសិនបើបុគ្គលិកថែទាំសុខភាពត្រូវបានចាត់ទុកថាមានហានិភ័យទាបៈ

| **សកម្មភាពដែលបុគ្គលិកសុខាភិបាលត្រូវធ្វើ** | **សកម្មភាពដែលមូលដ្ឋានសុខាភិបាលត្រូវធ្វើ** |
|---|---|
| • កត់ត្រាសម្រាប់ ១៤ ថ្ងៃ ពីថ្ងៃបានប៉ះពាល់ចុងក្រោយជាមួយអ្នកជំងឺកូវីដ-១៩ៈ សីតុណ្ហភាពរបស់អ្នក និងប្រសិនបើអ្នកមានក្អក ហៀរសំបោរ ឬដកដង្ហើមហត់<br>• ទាក់ទងទៅមូលដ្ឋានសុខាភិបាល ប្រសិនបើអ្នកមានកើតនូវរោគសញ្ញា ដែលអាចសន្មតថាជាជំងឺកូវីដ-១៩ | • ពង្រឹងការប្រុងប្រយ័ត្នស្តង់ដា និងការប្រុងប្រយ័ត្នលើការជាក់ដាច់ដោយឡែក និងការប្រើឧបករណ៍ការពារខ្លួនត្រឹមត្រូវ ដល់បុគ្គលិកក្នុងមូលដ្ឋានសុខាភិបាលទាំងអស់ |

ភាពនឿយហត់ ធុញថប់និងអារម្មណ៍តានតឹង ដែលទាក់ទងនឹងបរិស្ថាន គ្រួសារនិងសេដ្ឋកិច្ចដែលបណ្តាលមកពីកូវីដ-១៩ អាចជះឥទ្ធិពលដល់សុខភាពផ្លូវចិត្តនិងផ្លូវកាយ។ ការណែនាំនិងស្វែងរកជំនួយ ប្រសិនបើអ្នកមានអារម្មណ៍តានតឹងហួសហេតុឬមានបញ្ហាសុខភាពផ្លូវចិត្តដែលត្រូវការអន្តរាគមន៍គាំទ្រ

អ្នកផ្តល់សេវាថែទាំសម្ពព ដែលមានបញ្ហាបេះដូង ផ្លូវដង្ហើមឬមេតាប៉ូលីកនិងអ្នកដែលមានបញ្ហាប្រព័ន្ធភាពស៊ាំ រួមទាំងកង្វះប្រព័ន្ធភាពស៊ាំផង ត្រូវចៀសវាងទំនាក់ទំនងជាមួយអ្នកជំងឺឬអ្នកដែលសង្ស័យថាមានជំងឺកូវីដ-១៩និងពិចារណាមិនឱ្យជាប់ភារកិច្ចផ្នែកគ្លីនិក ប្រសិនបើអាចធ្វើទៅបាន។

អ្នកផ្តល់សេវាថែទាំសុខភាពដែលមានផ្ទៃពោះនៅត្រីមាសចុងក្រោយឬមានបញ្ហាសុខភាពដូចជាជំងឺបេះដូងឬស្ទួតត្រូវបានណែនាំឱ្យចៀសវាងការទាក់ទងផ្ទាល់ជាមួយអ្នកជំងឺ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ៖ ការសម្អាតរថយន្តគិលានសង្គ្រោះបន្ទាន់ និងយានយន្តបញ្ជូនអ្នកជំងឺ

### ខ) មធ្យោបាយធ្វើដំណើរៈ រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដឹកអ្នកជំងឺ

| | |
|---|---|
| **បុគ្គលិកថែទាំសុខភាព** | • ការដឹកអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ទៅមូលដ្ឋានសុខាភិបាល ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់។ |
| **អ្នកបើកបរ** | • ពេលបើកបរបញ្ជូនអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ពីមូលដ្ឋានសុខាភិបាលមួយ ទៅមូលដ្ឋានសុខាភិបាលមួយទៀត មិនតម្រូវឱ្យពាក់ឧបករណ៍ការពារខ្លួនឡើយ បើកន្លែងអ្នកបើកបរខណ្ឌដាច់ពីអ្នកជំងឺ តែត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ។<br>• ត្រូវពាក់ម៉ាស់វះកាត់ បើពេលបើកបរ ហើយបើកន្លែងអ្នកបើកបរ មិនខណ្ឌដាច់ពីអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩។<br>• នៅពេលជួយលើកដាក់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់ |
| **បុគ្គលិកអនាម័យ** | • នៅពេលលាងសម្អាតរថយន្តបញ្ជូនជំងឺ ត្រូវពាក់ស្រោមដៃក្រាស់ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ អាវបំពង់ ស្បែកជើងកវែង ឬស្បែកជើងបិទជិត។ |
| **អ្នកជំងឺ** | • គ្រប់អ្នកជំងឺមានរោគសញ្ញាផ្លូវដង្ហើម ត្រូវតែពាក់ម៉ាស់វះកាត់។ |

## ឧបសម្ព័ន្ធទី២ ៖ ឧបករណ៍ការពារខ្លួនសម្រាប់ជំងឺកូវីដ-១៩

ប្រភេទឧបករណ៍ការពារខ្លួនដែលត្រូវបានណែនាំឱ្យប្រើក្នុងបរិបទនៃជំងឺកូវីដ-១៩ យោងតាមទីកន្លែង បុគ្គលិក និងប្រភេទសកម្មភាព។

| ទីកន្លែង (Setting) | ក្រុមគោលដៅ (Target audience) | សកម្មភាព (Activity) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬបាំងការពារមុខ | អាវប៉ាក់(Gown) | អាវអៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| កន្លែងទទួលជំងឺដំបូង (Triage) | បុគ្គលិកថែទាំសុខភាព | ការត្រួតពិនិត្យជំងឺដំបូងដែល មិនទាក់ទងនឹងការថែទាំផ្ទាល់ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ តែត្រូវរក្សាគំលាតយ៉ាងហោច១ម៉ែត្រ។ បើមិនអាចរក្សាគម្លាតបាន សូមពាក់ម៉ាស់វះកាត់ និងវ៉ែនតាការពារ ឬបាំងការពារ។ | | | | | | |
| | អ្នកជំងឺដែលមានរោគសញ្ញាផ្លូវដង្ហើម | រាល់អ្នកជំងឺ | | X | | | | | |
| | អ្នកជំងឺដែលមិនមានរោគសញ្ញាផ្លូវដង្ហើម | រាល់អ្នកជំងឺ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ | | | | | | |
| បន្ទប់ពិគ្រោះជំងឺក្រៅ | បុគ្គលិកថែទាំសុខភាព | ពិនិត្យរាងកាយអ្នកជំងឺដែល មានរោគសញ្ញាផ្លូវដង្ហើម | X | X | | X | X | | |
| | | ពិនិត្យរាងកាយអ្នកជំងឺដែល មិនមានរោគសញ្ញាផ្លូវដង្ហើម | ការប្រុងប្រយ័ត្នជាស្តង់ដា និងវាយតម្លៃពីហានិភ័យ | | | | | | |
| | អ្នកជំងឺដែលមានរោគសញ្ញាផ្លូវដង្ហើម | រាល់អ្នកជំងឺ | | X | | | | | |
| | អ្នកជំងឺដែលមិនមានរោគសញ្ញាផ្លូវដង្ហើម | | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ | | | | | | |
| បន្ទប់អ្នកជំងឺ | បុគ្គលិកថែទាំសុខភាព | ការថែទាំអ្នកជំងឺកូវីដ-១៩ផ្ទាល់ | X | X | | X | X | | |
| | | សកម្មភាពដែលបង្កើតឲ្យមានភាគល្អិតតូចៗតាមខ្យល់ (Aerosol generating procedures[1])** | X | | X | X | X | X | |
| មន្ទីរពិសោធន៍ | បុគ្គលិកថែទាំសុខភាព | ការយកសំណាកចេញពីផ្លូវ ដង្ហើម | X | X | | X | X | | |

| ទីកន្លែង (Setting) | ក្រុមគោលដៅ (Target audience) | សកម្មភាព (Activity) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវប៉ាក់(Gown) | អាវអៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| | | ការយកសំណាកចេញពីផ្លូវដង្ហើមដែលអាចបង្កើតឲ្យមានការសាយភាយភាគល្អិតតូចៗតាមខ្យល់ | X | | X | X | X | X | |
| កន្លែងរដ្ឋបាល | គ្រប់បុគ្គលិកទាំងអស់ | ការងាររដ្ឋបាលដែលមិនទាក់ ទងនឹងការប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ | | | | | | |
| គ្រប់ទីកន្លែង | បុគ្គលិកអនាម័យ | ចូលក្នុងបន្ទប់អ្នកជំងឺសង្ស័យ និងបញ្ជាក់ជំងឺកូវីដ-១៩ | X* | X | | X | X | | X |
| មន្ទីរពិសោធន៍ | | | | | | | | | |
| មន្ទីរពិសោធន៍ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ | តេស្ត Molecular ការកាន់និងរៀបចំសំណាកសម្រាប់ធ្វើ RT-PCR-testing | អនុវត្តទៅតាមសេចក្តីណែនាំសុវត្ថភាពរបស់អង្គការសុខភាពពិភពលោកស្តីពីជំងឺកូវីដ-១៩៖ ស្រោមដៃ អាវប៉ពង់ អាវអៀមដៃវែងដែលគ្របដៃជិត គម្របក្បាល (Coverall), គម្របស្បែកជើង និងវ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ។ ហានិភ័យអាចប្រាប់ឲ្យដឹងពីការប្រើប្រាស់ម៉ាស់សម្រាប់ការពារផ្លូវដង្ហើម (e.g. N95 mask). | | | | | | |
| មធ្យោបាយធ្វើដំណើរ | | | | | | | | | |
| រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដឹកអ្នកជំងឺ | បុគ្គលិកថែទាំសុខភាព | ដឹកអ្នកជំងឺសង្ស័យជំងឺកូវីដ-១៩ ទៅមូលដ្ឋានសុខាភិបាល មួយទៀត | X | X | | X | X | | |
| | អ្នកបើកបរ | ពេលបើកបរ ហើយនិងកន្លែងអ្នកបើកបរនៅដាច់ពីអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ១៩ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួនឡើយ តែរក្សាគំលាតយ៉ាងហោច១ម៉ែត្រ | | | | | | |

| ទីកន្លែង (Setting) | ក្រុមគោលដៅ (Target audience) | សកម្មភាព (Activity) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវរ៉ូប(Gown) | អាវអៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| | | ពេលបើកបរ ហើយ និងកន្លែងអ្នកបើកបរ មិនខណ្ឌដាច់ពីអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ | | X | | | | | |
| | | នៅពេលជួយលើកដាក់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ | X | X | | X | X | | |
| | អ្នកជំងឺ | ដឹកទៅមូលដ្ឋានសុខាភិបាលមួយផ្សេងទៀត | | X | | | | | |
| | បុគ្គលិកអនាម័យ | សម្អាតបន្ទប់រវាងដឹកអ្នកជំងឺសង្ស័យកូវីដ-១៩ | X* | X | | X | X | | X |
| **នៅសហគមន៍ និងផ្ទះ** | | | | | | | | | |
| សហគមន៍ | **ក្រុមឆ្លើយតបបន្ទាន់** | សម្រាប់ការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកជំងឺសង្ស័យឬអ្នកជំងឺកូវីដ-១៩ | ត្រូវតែពាក់ម៉ាស់វះកាត់<br>ត្រូវអនុវត្តរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ | | | | | | |
| | | សម្រាប់ការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកជំងឺដែល មិនមានរោគសញ្ញាបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ<br>ត្រូវរក្សាគំលាតយ៉ាងហោច១ម៉ែត្រ | | | | | | |
| | | ការប្រមូលសំណាកពីផ្លូវដង្ហើម | X | X | | X | X | | |
| | **បុគ្គលិកថែទាំសុខភាព** | ផ្តល់ការថែទាំផ្ទាល់ចំពោះអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ | X | X | | X | X | | |

| ទីកន្លែង (Setting) | ក្រុមគោលដៅ (Target audience) | សកម្មភាព (Activity) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវប៉ាក់(Gown) | អាវរ៉ៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| ផ្ទះ | អ្នកជំងឺដែលមានរោគ សញ្ញាផ្លូវដង្ហើម | សកម្មភាពផ្សេងៗ | | x | | | | | |
| | អ្នកមើលថែអ្នកជំងឺ | ចូលក្នុងបន្ទប់អ្នកជំងឺសង្ស័យនិងជំងឺកូវីដ-១៩ តែមិនធ្វើការថែទាំផ្ទាល់ទេ | | x | | | | | |
| | | ផ្តល់ការថែទាំផ្ទាល់ដល់អ្នកជំងឺសង្ស័យ និង ជំងឺកូវីដ-១៩ ឬ ពេលយកលាមកចាក់ចោល ឬទឹកនោមឬសំរាម | x | x | | | | (ប្រសិនបើមានហានិភ័យនៃការខ្ទាតសារៈរាវ) | |

*ស្រោមដៃក្រាស់

**ឧទាហរណ៍នៃទម្រង់ការទាំងឡាយណាដែលបង្កើតឲ្យមានសាយភាយភាគល្អិតតូចៗតាមខ្យល់ ដូចជាការស៊ិកបំពង់ខ្យល់ដើម្បីសប់ដង្ហើម (Tracheal intubation) ការសប់ដង្ហើមដោយដៃ (non-invasive ventilation) ការចោះបំពង់ខ្យល់ (tracheotomy) ការសង្កត់សង្គ្រោះផ្លូវដង្ហើមបេះដូង (cardiopulmonary resuscitation) ការស៊ិកឆ្លុះទងសួត (bronchoscopy)-

កំណត់សម្គាល់បន្ថែម៖

- តារាងទី១ តំណាងឲ្យស្តង់ដារអប្បបរមាសម្រាប់ឧបករណ៍ការពារខ្លួនPPE ដោយពឹងផ្អែកលើអនុសាសន៍របស់អង្គការសុខភាពពិភពលោក។ ការវាយតម្លៃពីហានិភ័យ ត្រូវតែធ្វើមុនពេលចាប់ផ្តើមនិតិវិធីវេជ្ជសាស្ត្រ ថែទាំ មន្ទីរពិសោធន៍ ឬនិតិវិធីផ្សេងៗទៀត ដើម្បីឲ្យប្រាកដថាបុគ្គលិកទាំងអស់មានសុវត្ថិភាព និងកាត់បន្ថយការប្រើប្រាស់ដែលមិនសមស្រប។
- គម្របក្បាល អាវបំពង់គ្របទាំងមូល និងស្បែកជើងជ័រកវែង មិនចាំបាច់ទេនៅពេលដែលធ្វើការថែទាំផ្ទាល់ជាមួយអ្នកជំងឺសង្ស័យកូវីដ-១៩ ឬអ្នកជំងឺកូវីដ-១៩។

## ឧបសម្ព័ន្ធទី៣ ៖ ការអនុវត្តការលាងសម្អាត

### ៩- ការអនុវត្តន៍ការលាងសម្អាត

- លាងសម្អាតសម្ភារៈដោយប្រើសាប៊ូ និងទឹក គ្រាន់តែជាការជម្រះសារធាតុផ្សេងៗ (ឧទាហរណ៍ ធូលីដី ឈាម ទឹកមាត់ ទឹករំអិល សំបោ ទឹកភ្នែក។ ល។ ) ប៉ុន្តែវាមិនមែនជាការសម្លាប់វីរុស ដែលបង្កជំងឺកូវីដ-១៩ ទេ។
- ការប្រើសារធាតុរម្ងាប់មេរោគគឺជាការចាំបាច់ ដើម្បីកម្ចាត់វីរុសដែលបង្កអោយមានជំងឺកូវីដ-១៩។

- សារធាតុរម្ងាប់មេរោគដែលមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺកូវីដ-១៩ រួមមាន៖

| | |
|---|---|
| 70% ethyl alcohol | ដើម្បីរម្ងាប់មេរោគនៅកន្លែងឬរបស់តូចៗមុននិងក្រោយប្រើប្រាស់ដូចជាសម្ភារៈដែលអាចប្រើឡើងវិញបាន (ឧទាហរណ៍ ទែម៉ូម៉ែត្រ ស្តេតូស្កុប) |
| Sodium hypochlorite (bleach) at 0.5% | ដើម្បីរម្ងាប់មេរោគលើតំបន់ដែលមានប្រឡាក់ឈាម និងសារធាតុរាវ |
| Sodium hypochlorite at 0.1% | ដើម្បីរម្ងាប់មេរោគលើផ្ទៃនិងឧបករណ៍វេជ្ជសាស្ត្រ |
| Chlorine at 0.5% | ដើម្បីរម្ងាប់មេរោគលើផ្ទៃការ្ង |
| Chlorine at 0.05% | ដើម្បីរម្ងាប់មេរោគលើវ៉ែនតា របាំងការពារមុខ ឬវ៉ែនតាសុវត្ថិភាព (*សម្អាតមុនជាមួយសាប៊ូនិងទឹក បន្ទាប់មកត្រាំក្នុង ក្លរីនក្នុងអត្រា 0.0៥%) |

- ត្រូវពាក់ របាំងមុខ វ៉ែនតា អាវបំពង់ និងស្រោមដៃកវែងក្រាស់ នៅពេលលាយក្លរីន ព្រោះក្លរីនអាចបណ្តាលឱ្យរលាកប្រព័ន្ធដង្ហើម និងស្បែក។
- ត្រូវសម្អាតបន្ទប់ យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ ត្រូវតែធ្វើការសម្អាតចុងក្រោយ នៅពេលដែលអ្នកជំងឺចេញពីមន្ទីរពេទ្យ។
- សម្អាតញឹកញាប់កន្លែង ដែលប៉ះពាល់ច្រើន ដូចជា ដៃទ្វារ និងកៅអីបង់
- គោលការណ៍គ្រឹះនៃការលាងសម្អាត និងរម្ងាប់មេរោគត្រូវអនុវត្តទៅគ្រប់ផ្នែកថែទាំអ្នកជំងឺ។
- ត្រូវប្រាកដជានិច្ចថា បានសម្អាតឧបករណ៍ថែទាំអ្នកជំងឺ នៅក្រោយពេលប្រើប្រាស់ម្តងៗ។
- សូមផ្គត់ផ្គង់សម្ភារៈសម្អាតអោយបានគ្រាប់គ្រាន់ នៅក្នុងកន្លែងដែលមានហានិភ័យខ្ពស់ (ឧទាហរណ៍ នៅក្នុងបន្ទប់ដាច់ដោយឡែក បន្ទប់សម្រាល និងបន្ទប់វះកាត់)។
- ការផ្គត់ផ្គង់សម្ភារសម្អាតសម្រាប់បន្ទប់ដាច់ដោយឡែក ត្រូវរក្សាទុកសម្រាប់ប្រើប្រាស់តែនៅក្នុងបន្ទប់នោះ។
- ត្រូវសម្អាតពីតំបន់ស្អាតបំផុតទៅតំបន់ដែលកខ្វក់បំផុត។
- សម្អាតពីតំបន់ខ្ពស់ទៅតំបន់ទាប និងពីខាងក្រៅទៅផ្នែកខាងក្នុង។
- សម្អាតបន្ទប់ដាច់ដោយឡែកក្រោយគេ។
- ប្រើក្រណាត់ជូតសើម ដើម្បីសម្អាតធូលីដី
- ប្រើប្រព័ន្ធដាក់ធុង ៣ សម្រាប់សម្អាត និងរម្ងាប់មេរោគដូចខាងក្រោម៖
  1. ការលាងសម្អាត (ទឹក និង សាប៊ូ ឬdetergent)
  2. លាងជម្រះ ប្រើតែទឹកប៉ុណ្ណោះ
  3. រម្ងាប់មេរោគដោយប្រើ (Sodium hypochlorite at 0.5% or chlorine 0.5%)
- ទឹកសម្រាប់លាងសម្អាតត្រូវតែជាទឹកស្អាត។

- មានប្រទេសខ្លះដូចជាចិន ថៃ និងវៀតណាម បានប្រប់ប្រាស់សារធាតុបាញ់រម្ងាប់មេរោគនៅក្នុងខ្យល់ឡើយនៅតាមទីធ្លាសាធារណៈ។ ប៉ុន្តែមិនមានភ័ស្តុតាងដែលបង្ហាញថាការប្រើប្រាស់សារធាតុបាញ់រម្ងាប់មេរោគនៅក្នុងខ្យល់ឡើយមានប្រសិទ្ធភាព។ វីរុសដែលបង្កឱ្យមានជំងឺកូវីដ-១៩ ត្រូវបានចម្លងពីមនុស្សទៅមនុស្សតាមរយៈដំណក់តូចៗ ពីផ្លូវដង្ហើម និងការប៉ះពាល់ជាមួយមនុស្សឈឺ ឬផ្ទៃវត្ថុដែលមានមេរោគ។ ការឆ្លងតាមខ្យល់អាចមានលទ្ធភាពក្នុងកាលៈទេសៈជាក់លាក់ដូចជា ទម្រង់ការទាំងឡាយណា ដែលបង្កើតឲ្យមានការសាយភាយភាគតូចៗតាមខ្យល់ (Aerosol generating procedures)។

# ឧបសម្ព័ន្ធទី ៤៖ សំណួរដែលត្រូវបានសួរជាញឹកញាប់

## *១. តើស្ត្រីមានផ្ទៃពោះប្រឈមនឹងហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ-១៩ ដែរឬទេ? ប្រសិនបើពួកគេឆ្លងមេរោគនេះ តើពួកគេនឹងមានសភាពធ្ងន់ធ្ងរជាងមនុស្សទូទៅដែរឬទេ?*

ការមានផ្ទៃពោះផ្លាស់ប្តូរប្រព័ន្ធភាពស៊ាំរបស់ស្ត្រីដែលធ្វើឱ្យពួកគេងាយនឹងឆ្លងរោគ។ ទោះបីយ៉ាងណាក៏ដោយនាពេលបច្ចុប្បន្ននេះមិនមានភ័ស្តុតាងណាមួយដែលបញ្ជាក់ថាស្ត្រីមានផ្ទៃពោះទំនងជារងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ជាងមនុស្សទូទៅឬថាតើពួកគេទំនងជាមានសភាពធ្ងន់ធ្ងរជាងអ្នកដទៃទៀតឡើយ។

ស្ត្រីមានផ្ទៃពោះជួបប្រទះការផ្លាស់ប្តូរនៅក្នុងខ្លួនរបស់ពួកគេដែលអាចបង្កើនហានិភ័យនៃការឆ្លងរោគមួយចំនួន។ ជាការសំខាន់ណាស់សម្រាប់ស្ត្រីមានផ្ទៃពោះត្រូវការពារខ្លួនពីជំងឺនិងរាយការណ៍ពីរោគសញ្ញាដែលអាចកើតមាន ដូចជាគ្រុនក្តៅ ក្អកឬពិបាកដកដង្ហើម ទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ។

## *២. តើស្ត្រីមានផ្ទៃពោះអាចការពារខ្លួនពីការឆ្លងជំងឺកូវីដ-១៩ ដោយរបៀបណា?*

ស្ត្រីមានផ្ទៃពោះគួរតែធ្វើដូចគ្នានឹងមនុស្សទូទៅដែរដើម្បីចៀសវាងការឆ្លងរោគ។ ស្ត្រីមានផ្ទៃពោះដែលមិនមានរោគសញ្ញាក្អកឬគ្រុនក្តៅនិងមិនមានប្រវត្តិទាក់ទងនឹងករណីអ្នកមានផ្ទុកជំងឺកូវីដ-១៩ ត្រូវអនុវត្តតាមវិធីសាស្ត្រ ង្ការការឆ្លងរោគដូចខាងក្រោម៖

- លាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូនិងទឹក
- គ្របមាត់និងច្រមុះរបស់អ្នកដោយកន្សែងដៃឬក្រដាសឬដោយកែងដៃរបស់អ្នកពេលក្អកឬកណ្តាស់។ ប្រសិនបើអ្នកប្រើកន្សែងដៃ សូមបោកសម្អាតវាឱ្យបានញឹកញាប់។ ប្រសិនបើប្រើក្រដាសសូមបោះចោលវាបន្ទាប់ពីបានប្រើភ្លាមៗ។
- អនុវត្តការនៅដាច់ដោយឡែក កុំទៅកន្លែងដែលមានមនុស្សច្រើននិងចៀសវាងការប្រើមធ្យោបាយធ្វើដំណើរសាធារណៈ។
- ចៀសវាងការទាក់ទងជាមួយអ្នកដែលកំពុងក្តៅខ្លួន ក្អកឬកណ្តាស់
- ចៀសវាងប៉ះភ្នែកច្រមុះនិងមាត់របស់អ្នកតាមដែលអាចធ្វើទៅបាន
- សម្អាតលើផ្ទៃនៃវត្ថុ ដូចជា តុ ប្រកាន់ដៃទ្វារ ទូរស័ព្ទចល័តនិងវត្ថុប្រើប្រចាំថ្ងៃផ្សេងៗទៀត។
- ប្រសិនបើអ្នកក្អក គ្រុនក្តៅ ឬពិបាកដកដង្ហើម សូមទាក់ទងតាមការណែនាំរបស់ក្រសួងសុខាភិបាល។

### *៣. តើស្ត្រីមានផ្ទៃពោះគួរទៅទទួលការថែទាំផ្ទៃពោះមុនសម្រាល ឬចៀសវាងទៅមូលដ្ឋានសុខាភិបាល?*

ស្ត្រីមានផ្ទៃពោះគួរបន្តទទួលការថែទាំក្នុងអំឡុងពេលមានផ្ទៃពោះ និងទៅមូល ដ្ឋានសុខាភិបាលដើម្បីសម្រាលកូន ។ ទោះបីជាមានការរាតត្បាតនៃជំងឺកូវីដ-១៩ក៏ដោយ ស្ត្រីចាំបាច់ត្រូវទៅពិនិត្យផ្ទៃពោះមុនពេលសម្រាលនិងសម្រាលកូននៅមូលដ្ឋានសុខភិបាលដើម្បីសុខភាពរបស់ខ្លួននិងទារក។

### *៤. ប្រសិនបើស្ត្រីមានផ្ទៃពោះមានរោគសញ្ញាដូចជាក្អក ក្តៅខ្លួនឬពិបាកដកដង្ហើម តើស្ត្រីគួរធ្វើអ្វីខ្លះ?*

ស្ត្រីមានផ្ទៃពោះដែលមានរោគសញ្ញានៃការឆ្លងជំងឺកូវីដ-១៩ គួរទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតដោយ ៖

- ស្ត្រីគួរតែចៀសវាងការប្រើមធ្យោបាយធ្វើដំណើរសាធារណៈ ត្រូវទំនាក់ទំនងរថយន្តសង្គ្រោះបន្ទាន់ឬរថយន្តឯកជន។ ស្ត្រីត្រូវជូនដំណឹងដល់អ្នកបើកបររថយន្តសង្គ្រោះបន្ទាន់ដើម្បីឱ្យគាត់ចាត់វិធានការបង្ការសមស្របនិងជូនដំណឹងដល់មូលដ្ឋានសុខាភិបាលជាមុន។
- ស្ត្រីគួរតែប្រើម៉ាស់ឬបិទច្រមុះនិងមាត់របស់ពួកគេពេលមានទំនាក់ទំនងជាមួយអ្នកបើកបររថយន្តសង្គ្រោះឬបុគ្គលិកនៅមូលដ្ឋានសុខាភិបាល។
- ស្ត្រីគួរតែចៀសវាងការទាក់ទងជាមួយអ្នកជំងឺផ្សេងទៀតនិងសាច់ញ្ញាតិរបស់ពួកគេ ហើយត្រូវរង់ចាំការណែនាំរបស់បុគ្គលិកសុខាភិបាលអំពីកន្លែងដែលត្រូវទៅនិងអ្នកដែលត្រូវជួប
- ក្នុងករណីបន្ទាន់ដូចជា មានការឈឺចាប់ក្នុងអំឡុងពេលឈឺពោះសម្រាល មានបញ្ហាណាមួយដូចជាការធ្លាក់ឈាម ប្រកាច់ជាដើម ពួកគេត្រូវតែជូនដំណឹងដល់បុគ្គលិកសុខាភិបាលជាបន្ទាន់អំពីបញ្ហានេះ។

### *៥. តើជំងឺកូវីដ-១៩ អាចបង្កបញ្ហាដល់ការមានផ្ទៃពោះបានដែរឬទេ?*

មិនមានភ័ស្តុតាងណាដែលបង្ហាញថាជំងឺកូវីដ-១៩ នឹងបង្កបញ្ហាដល់ការមានផ្ទៃពោះទេ។

### *៦. តើជំងឺកូវីដ-១៩ អាចឆ្លងពីម្តាយដល់ទារកក្នុងផ្ទៃឬទារកទើបនឹងកើតដែរឬទេ?*

រហូតមកដល់បច្ចុប្បន្នជំងឺកូវីដ-១៩នេះមិនត្រូវបានគេរកឃើញនៅក្នុងទឹកភ្លោះឬទឹកដោះម្តាយទេ។

*៧. តើស្ត្រីមានផ្ទៃពោះដែលមានការសង្ស័យឬត្រូវបានបញ្ជាក់ថាមានជំងឺកូវីដ-១៩ ត្រូវការសម្រាលដោយការវះកាត់ដែរឬទេ?*

អង្គការសុខភាពពិភពលោកបានបញ្ជាក់ថា ការសម្រាលដោយការវះកាត់ ត្រូវធ្វើឡើងតែនៅពេលមានតម្រូវការផ្នែកវេជ្ជសាស្ត្រតែប៉ុណ្ណោះ។ ជំងឺកូវីដ-១៩មិនមានផលប៉ះពាល់អ្វីដល់របៀបនៃការសម្រាលឡើយ។

*៨. តើម្តាយដែលមានឬសង្ស័យថាមានជំងឺកូវីដ-១៩អាចបំបៅកូនដោយទឹកដោះម្តាយរបស់ខ្លួនបានឬទេ?*

ស្ត្រីបំបៅដោះកូនមិនគួរត្រូវបានបំបែកចេញពីទារកទើបនឹងកើតរបស់ពួកគេនោះទេ ព្រោះមិនមានភស្តុតាងណាមួយបង្ហាញថាជំងឺកូវីដ-១៩អាចចម្លងតាមរយៈទឹកដោះម្តាយបានទេ ហើយម្តាយអាចបន្តបំបៅកូនដោយទឹកដោះបាន។ ម្តាយដែលមានរោគសញ្ញាជំងឺកូវីដ-១៩អាចបំបៅដោះទារកបានលុះត្រាតែពួកគេត្រូវអនុវត្តការប្រុងប្រយ័ត្នដូចខាងក្រោម ៖

- ពាក់ម៉ាស់នៅពេលកំពុងបីទារកនិងបំបៅដោះកូន
- លាងដៃមុនពេលប៉ះពាល់ ឬបីទារក
- សម្អាតទីកន្លែងជាប្រចាំ

ប្រសិនបើស្ត្រីឈឺខ្លាំងមិនអាចបំបៅកូនបាន ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការច្របាច់ទឹកដោះដើម្បីផ្តល់ឱ្យទារក ដោយអនុវត្តការប្រុងប្រយ័ត្នដូចខាងលើនិងត្រូវសម្អាតពែង ស្លាបព្រាដែលត្រូវប្រើក្នុងការបញ្ចុក។

ឧបត្ថម្ភថវិកាដោយៈ